# អង្គការសហប្រជាជាតិ

# សេចក្តីពន្យល់ទូទៅលេខ៣៥

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ

# មាត្រា៩៖ សេរីភាព និងសន្តិសុខរបស់មនុស្ស

អនុម័តដោយគណៈកម្មាធិការសិទ្ធិមនុស្ស

ថ្ងៃទី១៦ ធ្នូ ២០១៤

អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

# អង្គការសហប្រជាជាតិ
# សេចក្តីពន្យល់ទូទៅលេខ៣៥

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ

*មាត្រា៩៖ សេរីភាព និងសន្តិសុខរបស់មនុស្ស*

អនុម័តដោយគណ:កម្មាធិការសិទ្ធិមនុស្ស

ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤

អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

ខែតុលា ឆ្នាំ២០១៥

# មាតិការឿង

ទំព័រ

សេចក្តីផ្តើម.....................................................................................៥

ខ្លឹមសារមាត្រា៩.........................................................................១១

I- ចំណាប់អារម្មណ៍ទូទៅ..........................................................១៣

II- ការឃុំខ្លួនតាមទំនើងចិត្ត និងការឃុំខ្លួន
ដោយមិនត្រឹមត្រូវតាមច្បាប់................................................២១

III- ការជូនដំណឹងអំពីមូលហេតុនៃការចាប់ខ្លួន និងការចោទ
ប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ.........................................៣៧

IV- ការគ្រប់គ្រងការឃុំខ្លួនដោយតុលាការ ទាក់ទងនឹង
បទចោទប្រកាន់ព្រហ្មទណ្ឌ................................................៤៣

V- សិទ្ធិក្នុងការធ្វើចំណាត់ការ ដើម្បីដោះលែងពីការ
ឃុំខ្លួនមិនត្រឹមត្រូវតាមច្បាប់ ឬតាមទំនើងចិត្ត........................៥៣

VI- សិទ្ធិទទួលបានសំណងចំពោះការចាប់ខ្លួន ឬការឃុំខ្លួន
ដែលមិនត្រឹមត្រូវតាមច្បាប់ ឬតាមទំនើងចិត្ត..........................៦១

VII- ទំនាក់ទំនងនៃមាត្រា៩ ជាមួយមាត្រាផ្សេងទៀត
នៃកតិកាសញ្ញា.............................................................................៦៥

# សេចក្តីផ្តើម

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា សូមផ្តល់ជូននូវការបោះពុម្ពផ្សាយនេះ ដល់អ្នកទាំងឡាយណាដែលមានឆន្ទៈមោះមុតក្នុងការបង្ការទារុណកម្ម និងការប្រព្រឹត្តមិនគប្បី ព្រមទាំងលើកស្ទួយនីតិរដ្ឋនៅកម្ពុជា។ សេចក្តីពន្យល់នេះ បំភ្លឺយ៉ាងច្បាស់អំពីការអនុវត្តជាក់ស្តែងនៃសិទ្ធិមួយក្នុងចំណោមសិទ្ធិមនុស្សជាសារវន្តបំផុតទាំងអស់៖ សិទ្ធិមានសេរីភាពនិងសន្តិសុខរបស់មនុស្ស។ សិទ្ធិនេះមានចែងនៅក្នុងមាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នកាលពីឆ្នាំ១៩៩២។

កូនសៀវភៅនេះ នឹងចែកជូនដល់អ្នកអានកម្ពុជាទាំងអស់ នូវគោលការណ៍ណែនាំ ដែលតាក់តែងដោយគណៈកម្មាធិការសិទ្ធិមនុស្សដល់រដ្ឋភាគីទាំងឡាយនៃកតិកាសញ្ញានេះ។ គណៈកម្មាធិការសិទ្ធិមនុស្ស គឺជាគណៈកម្មាធិការមួយដែលមានសមាជិក១៨រូប ជាអ្នកជំនាញការឯករាជ្យ បោះឆ្នោតជ្រើសតាំងដោយរដ្ឋភាគី ដើម្បីតាមឃ្លាំមើលការអនុវត្តកតិកាសញ្ញានេះ នៅគ្រប់រដ្ឋភាគី។ គណៈកម្មាធិការ ពិនិត្យមើលរបាយការណ៍ដែលរដ្ឋភាគីបានដាក់ជូនទៀងទាត់តាមកាលកំណត់។ រួចហើយគណៈកម្មាធិការអនុម័តសេចក្តីសង្កេតសន្និដ្ឋានលើរបាយការណ៍នោះ ដែលចាត់ទុកជាអនុ

សាសន៍របស់គណៈកម្មាធិការចំពោះរដ្ឋភាគីពាក់ព័ន្ធ អំពីរបៀបធ្វើឲ្យប្រសើរដល់ការគោរពតាមកាតព្វកិច្ចរបស់រដ្ឋភាគីនោះ ចំពោះកតិកាសញ្ញា។ ចំពោះរដ្ឋភាគីណា ដែលបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមទី១នៃកតិកាសញ្ញានេះដែរ គណៈកម្មាធិការនឹងមានសិទ្ធិពិនិត្យមើលបណ្តឹងដែលប្តឹងដោយបុគ្គលនានា ឬក្រុម ដែលបានចោទថាមានការបំពានលើសិទ្ធិរបស់ពួកគេ ដោយរដ្ឋភាគី។ វាមានសារៈសំខាន់ណាស់ដែលរដ្ឋភាគី ត្រូវយល់ពីទំហំនៃកាតព្វកិច្ចរបស់ខ្លួនក្រោមកតិកាសញ្ញានេះ។ ដើម្បីជួយដល់រដ្ឋភាគីលើករណីនេះ គណៈកម្មាធិការអនុម័តសេចក្តីពន្យល់ទូទៅដែលពន្យល់កាន់តែពិស្តារពីកាតព្វកិច្ចរបស់រដ្ឋភាគី តាមមាត្រានីមួយៗ នៃកតិកាសញ្ញានេះ។ សេចក្តីពន្យល់ទូទៅទាំងនេះ ធ្វើឡើងដោយឈរលើមូលដ្ឋាននៃបទពិសោធន៍យ៉ាងទូលាយរបស់គណៈកម្មាធិការ ក្នុងការតាមឃ្លាំមើលពីការអនុវត្តតាមកតិកាសញ្ញានេះ នៅទូទាំងពិភពលោក ដែលបានជាផ្លែផ្កាដល់គណៈកម្មាធិការ តាមរយៈសេចក្តីសង្កេតសន្និដ្ឋាន និងសេចក្តីសម្រេចរបស់គណៈកម្មាធិការលើរឿងក្តីនីមួយៗ ដែលបុគ្គលបានប្តឹងមក។

សិទ្ធិមានសេរីភាព និងសន្តិសុខរបស់មនុស្ស គឺមានសារៈសំខាន់ដល់ការបង្ការទារុណកម្ម និងការប្រព្រឹត្តមិនគប្បី ព្រមទាំងដល់កិច្ចការពារនីតិរដ្ឋទាំងមូលនៅក្នុងរដ្ឋភាគី។ ហេតុនេះហើយបានជាគណៈកម្មាធិការសិទ្ធិមនុស្ស បានអនុម័តសេចក្តីពន្យល់

ទូទៅលេខ៣៥ ស្តីពីមាត្រា៩ កាលពីខែធ្នូ ឆ្នាំ២០១៤ ដើម្បីផ្តល់ការណែនាំបន្ថែមទៀតថាតើសិទ្ធិដ៏សម្បុគស្មាញនេះ ជាក់ស្តែងពាក់ព័ន្ធនឹងអ្វីខ្លះទៅ។ រាល់កិច្ចធានាការពារមានចែងក្នុងមាត្រា៩ ត្រូវយកមកអនុវត្តនៅគ្រប់រដ្ឋភាគី ដោយមិនគិតថារដ្ឋនោះដើរតាមប្រព័ន្ធច្បាប់បារាំង ឬប្រព័ន្ធច្បាប់អង់គ្លេសឡើយ។

នៅក្នុងសេចក្តីពន្យល់ទូទៅនេះ គណៈកម្មាធិការសិទ្ធិមនុស្ស បានពន្យល់ពិស្តារអំពីកិច្ចធានាការពារ និងរក្សាកិច្ចការពារផ្សេងៗ ដល់សេរីភាព និងសន្តិសុខរបស់មនុស្សដូចមានចែងក្នុងមាត្រា៩។ សិទ្ធិមានសេរីភាពរបស់មនុស្សពាក់ព័ន្ធនឹងការរួចផុតពីការឃុំឃាំងរាងកាយ សិទ្ធិមានសន្តិសុខរបស់មនុស្សពាក់ព័ន្ធនឹងការរួចផុតពីការបង្ករបួសស្នាមលើរាងកាយ និងផ្លូវចិត្ត ឬបូរណភាពរាងកាយ និងផ្លូវចិត្ត។

គណៈកម្មាធិការសិទ្ធិមនុស្ស បានផ្តល់ការពន្យល់យ៉ាងក្បោះក្បាយអំពីសិទ្ធិមានសេរីភាពរបស់មនុស្ស។ ពាក្យ "ចាប់ខ្លួន / ឃាត់ខ្លួន" សំដៅដល់ការចាប់ខ្លួនមនុស្សណាម្នាក់ ដែលចាប់ផ្តើមពីការដកហូតសេរីភាព ហើយពាក្យ "ឃុំខ្លួន" សំដៅដល់ការដកហូតសេរីភាពចាប់ពីការចាប់ខ្លួន រហូតដល់ពេលដោះលែងវិញ។ គ្មានការដកហូតសេរីភាព អាចធ្វើតាមទំនើងចិត្តនោះទេ។ ការដូកហូតណាក៏ដោយត្រូវតែអនុវត្តដោយគោរពតាមនីតិរដ្ឋ។

គណៈកម្មាធិការសិទ្ធិមនុស្សក៏បានបំភ្លឺថារាល់ការការចាប់ខ្លួន ឃាត់ខ្លួនត្រូវតែប្រាប់ពីមូលហេតុ ហើយការចោទប្រកាន់ណាមួយចំពោះបុគ្គលណាមួយត្រូវតែធ្វើភ្លាមៗ។ បន្ទាប់មក បុគ្គលនោះអាចប្រើប្រាស់មូលហេតុដែលយកមកសំអាងនេះ ធ្វើជាមូលដ្ឋានសំរាប់ស្វែងរកការដោះលែង។ គណៈកម្មាធិការពន្យល់បន្ថែមទៀតថាជនណាក៏ដោយដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួនពីបទល្មើសព្រហ្មទណ្ឌត្រូវបាននាំខ្លួនភ្លាមៗទៅចំពោះមុខចៅក្រម ដែលជាការការពារយ៉ាងចំបងប្រឆាំងការធ្វើតាមទំនើងចិត្ត។ លក្ខខណ្ឌតម្រូវនេះត្រូវអនុវត្តចំពោះគ្រប់ករណី ដោយគ្មានការលើកលែង និងមិនអាស្រ័យលើជម្រើស ឬលទ្ធភាពរបស់ជនជាប់ឃុំលើកមកអះអាងនោះទេ។

គណៈកម្មាធិការសិទ្ធិមនុស្សពន្យល់ថា តាមមាត្រា៩ ជនណាដែលត្រូវបានដកហូតសេរីភាពដោយការចាប់ខ្លួន ឬឃុំខ្លួន មានសិទ្ធិតតាំងពីភាពត្រឹមត្រូវតាមច្បាប់ និងការធ្វើតាមទំនើងចិត្តនៃការចាប់ខ្លួន ឬការឃុំខ្លួន តាមនីតិវិធីតុលាការ។ សិទ្ធិនេះ អនុវត្តគ្រប់ការឃុំខ្លួន រួមទាំង ការឃុំខ្លួនដោយហេតុផលយោធា ការឃុំខ្លួនដោយហេតុផលសន្តិសុខ ការឃុំខ្លួនដោយហេតុផលប្រឆាំងនឹងភេរវកម្ម ការបង្ខំឲ្យដេកពេទ្យ ការឃុំខ្លួនដោយហេតុផលអន្តោប្រវេសន្ត ការឃុំខ្លួនដោយហេតុផលបត្យាប័ន ការឃុំខ្លួនដោយសារភាពអនាថា ឬការញៀនថ្នាំ ការឃុំខ្លួនសម្រាប់គោលបំណងអប់រំកុមារទំនាស់នឹងច្បាប់ ការចាប់ឃុំខ្លួននៅផ្ទះ ការឃុំខ្លួនដាច់តែឯង ព្រមទាំងការចាប់ខ្លួនដទៃទៀតដែលគ្មានមូលដ្ឋានទាល់តែសោះ។

គណៈកម្មាធិការពន្យល់បន្ថែមទៀតថា មាត្រា៩ ក៏ចែងពីការជួសជុលការខូចខាត និងសំណងផងដែរ ដល់អ្នកទាំងឡាយណាដែលទទួលរងពីការចាប់ខ្លួន ឬការឃុំខ្លួនដោយមិនត្រឹមត្រូវតាមច្បាប់ ឬតាមទំនើងចិត្ត។ រដ្ឋភាគីត្រូវបង្កើតក្របខ័ណ្ឌច្បាប់ ដែលមានចែងពីសំណងដល់ជនរងគ្រោះ ថាជាបញ្ហាមួយនៃសិទ្ធិដែលអាចអនុវត្តបាន មិនមែនជាបញ្ហានៃការប្រទាន ឬឆន្ទានុសិទ្ធិនោះទេ។ សំណងជាក់លាក់ទាំងនេះ មិនអាចជំនួសបាន តែត្រូវធ្វើជាមួយសំណងដទៃទៀត ដែលអាចតម្រូវតាមស្ថានភាពពិសេសមួយចំនួនដល់ជនរងគ្រោះពីការឃុំខ្លួនដោយមិនត្រឹមត្រូវតាមច្បាប់ ឬតាមទំនើងចិត្ត ក្រោមមាត្រា២ នៃកតិកាសញ្ញានេះ។

ជាទីបញ្ចប់ សេចក្តីពន្យល់ទូទៅលេខ៣៥នេះ បានផ្តល់នូវចំណុចសំខាន់ៗមួយចំនួនគួរឲ្យចងចាំ អំពីទំនាក់ទំនងរវាងមាត្រា ៩ និងបទប្បញ្ញត្តិដទៃទៀតនៃកតិកាសញ្ញា។ ជាពិសេស សេចក្តីពន្យល់នេះ រំលឹកថា ការពន្យារសវនាការដោយមិនត្រឹមត្រូវ មិនគ្រាន់តែជាការបំពានសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌នោះទេ តែក៏បំពានមាត្រា៩(៣) ដែលចែងថាជនណាក៏ដោយដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួនពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិទទួលបានសវនាការក្នុងពេលមួយសមហេតុផល បើមិនដូច្នេះទេ ត្រូវតែដោះលែង។ គណៈកម្មាធិការសិទ្ធិមនុស្សក៏ពន្យល់ផងដែរថា វិធីចំណាត់ការរឿងក្តីព្រហ្មទណ្ឌអាចធ្វើឲ្យប៉ះពាល់ដល់ការអនុវត្ត និង

ការទទួលបានសិទ្ធិដទៃទៀត ដែលត្រូវបានការពារដោយកតិកាសញ្ញានេះ។ គណៈកម្មាធិការផ្តល់ឧទាហរណ៍ពីបទបរិហារកេរ្តិ៍ដែលត្រូវបានគេទុកមិនចាត់ការអស់ជាច្រើនឆ្នាំ ហើយពន្យល់ថា ការពន្យារពេលនេះមានផលប៉ះពាល់យ៉ាងខ្លាំងដល់ជនត្រូវចោទ ហើយអាចរិតត្បិតមិនត្រឹមត្រូវ ដល់សិទ្ធិមានសេរីភាពនៃការបញ្ចេញមតិរបស់គាត់ ដែលត្រូវបានការពារតាមមាត្រា១៩ នៃកតិកាសញ្ញា។

សេចក្តីពន្យល់ទូទៅលេខ៣៥នេះ មានសារប្រយោជន៍ជាពិសេស ដោយយល់ឃើញពីភាពស្មុគស្មាញនៃមាត្រា៩។ នៅក្នុងឯកសារដ៏សំខាន់នេះ គណៈកម្មាធិការសិទ្ធិមនុស្សបានផ្តល់នូវការណែនាំយ៉ាងក្បោះក្បាយពីវិធីបកស្រាយមាត្រា៩ ដែលជាស្នូលដល់ការផ្តល់សេវាសាធារណៈដ៏សំខាន់បំផុតមួយក្នុងចំណោមសេវាកម្មសំខាន់ៗដទៃទៀត ដែលផ្តល់ដោយស្ថាប័ននានារបស់រដ្ឋាភិបាល ដូចជាក្រសួងយុត្តិធម៌ជាដើម។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សមានក្តីសោមនស្ស ក្នុងការពាំនាំនូវប្រភពដ៏មានតំលៃនេះដល់កម្ពុជា។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
កម្ពុជា
ខែតុលា ឆ្នាំ២០១៥

# *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ*

## មាត្រា ៩

១. ជនគ្រប់រូបមានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់។

២. ជនណាដែលត្រូវបានចាប់ខ្លួន ត្រូវមានសិទ្ធិឱ្យគេប្រាប់ឱ្យដឹងនៅពេលចាប់ខ្លួន អំពីមូលហេតុនៃការចាប់ខ្លួន និងត្រូវប្រាប់ឱ្យដឹងភ្លាមអំពីការចោទប្រកាន់។

៣. បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់ឱ្យបំពេញមុខងារតុលាការក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវបានជំនុំជំរះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។ ការឃុំខ្លួនមនុស្សដើម្បីរង់ចាំការជំនុំជំរះ គឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការឱ្យនៅក្រៅឃុំត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះនៅពេលសវនាការ ឬនៅគ្រប់ដំណាក់ការដទៃទៀតនៃនីតិវិធី ហើយត្រូវមានមុខក្នុងការអនុវត្តន៍សាលក្រម។

៤. ជនណាដែលត្រូវដកហូតសេរីភាព ដោយការឃាត់ខ្លួន ឬឃុំខ្លួន ត្រូវតែមានសិទ្ធិដាក់ពាក្យបណ្ដឹង ដើម្បីឱ្យតុលាការអាចសម្រេចដោយមិនពន្យារពេលអំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងការបង្គាប់ឱ្យនៅក្រៅឃុំ បើការឃុំខ្លួននោះមិនស្របច្បាប់។

៥. ជនណាដែលបានរងគ្រោះដោយសារការឃាត់ខ្លួន ឬឃុំខ្លួនដោយខុសច្បាប់ មានសិទ្ធិទាមទារសំណង។

# សេចក្តីពន្យល់ទូទៅលេខ៣៥

## *មាត្រា៩៖ សេរីភាព និងសន្តិសុខរបស់មនុស្ស*

## I. **ចំណាប់អារម្មណ៍ទូទៅ**

១. សេចក្តីពន្យល់ទូទៅនេះជំនួសឲ្យសេចក្តីពន្យល់ទូទៅលេខ៨(សម័យប្រជុំលើកទីដប់ប្រាំមួយ) ដែលបានអនុម័តកាលពីឆ្នាំ១៩៨២។

២. មាត្រា៩ ទទួលស្គាល់ និងការពារទាំងសេរីភាពរបស់មនុស្ស និងសន្តិសុខរបស់មនុស្ស។ នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា៣ ប្រកាសថា មនុស្សគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខរបស់មនុស្ស។ នេះគឺជាសិទ្ធិដ៏សំខាន់ទីមួយ ដែលត្រូវការពារដោយសេចក្តីប្រកាសជាសកលនេះ ដោយបង្ហាញពីសារៈសំខាន់យ៉ាងជ្រាលជ្រៅនៃមាត្រា៩ នៃកតិកាសញ្ញា ទាំងសម្រាប់បុគ្គល និងសង្គមទាំងមូល។ សេរីភាព និងសន្តិសុខរបស់មនុស្សមានតម្លៃខ្លាំងណាស់ សម្រាប់ជាផលប្រយោជន៍ផ្ទាល់របស់ពួកគេ និងដោយសារតែការដកហូតសេរីភាព និងសន្តិសុខរបស់មនុស្សកន្លងមក ធ្លាប់ជាដើមហេតុចំបងដល់ការធ្វើឲ្យខូចខាតដល់ការទទួលបានសិទ្ធិដទៃទៀត។

៣. សេរីភាពរបស់មនុស្ស ទាក់ទងនឹងការរួចផុតពីការឃុំឃាំងរាងកាយ មិនមែនជាសេរីភាពទូទៅចង់ធ្វើអ្វីតាមចិត្តនោះទេ។[១] សន្តិសុខរបស់មនុស្សទាក់ទងនឹងការរួចផុតពីការបង្ករបួសស្នាមលើរាងកាយ និងផ្លូវចិត្ត ឬបូរណភាពរាងកាយ និងផ្លូវចិត្ត ដូចដែលត្រូវបានពិភាក្សាបន្ថែម នៅក្នុងកថាខណ្ឌ៩ ខាងក្រោម។ មាត្រា៩ ធានាការពារសិទ្ធិទាំងនេះដល់ជនគ្រប់រូប។ "ជនគ្រប់រូប" រួមទាំង ក្នុងចំណោមអ្នកដទៃមានក្មេងស្រី និងក្មេងប្រុស ទាហាន ជនពិការ មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ ជនចម្លែក ជនភៀសខ្លួន ជនស្វែងរកសិទ្ធិជ្រកកោន ជនគ្មានសញ្ជាតិ ពលករទេសន្តរប្រវេសន៍ ជនដែលត្រូវបានដាក់ទោសពីបទឧក្រិដ្ឋ និងជនដែលពាក់ព័ន្ធនៅក្នុងសកម្មភាពភេរវកម្ម។

៤. កថាខណ្ឌ២ ដល់កថាខណ្ឌ៥ នៃមាត្រា៩ កំណត់ពីកិច្ចការពារជាក់លាក់ដល់ការការពារសេរីភាពនិងសន្តិសុខរបស់មនុស្ស។ បទប្បញ្ញត្តិខ្លះនៃមាត្រា៩ (មួយផ្នែកនៃកថាខណ្ឌ២ និងកថាខណ្ឌ៣ទាំងមូល) អនុវត្តចំពោះតែការដាក់បន្ទុកពីបទល្មើសព្រហ្មទណ្ឌប៉ុណ្ណោះ។ ប៉ុន្តែផ្នែកដែលនៅសល់ ជាពិសេស កិច្ចធានាការពារយ៉ាងសំខាន់ ដែលបានដាក់ចេញក្នុងកថាខណ្ឌ៤ តួយ៉ាង សិទ្ធិទទួលបានការពិនិត្យឡើងវិញដោយតុលាការ អំពីនីត្យានុកូលភាពនៃការឃុំខ្លួន អនុវត្តចំពោះបុគ្គលទាំងអស់ដែលត្រូវបានគេដកហូតសេរីភាព។

---

[១] បណ្តឹងលេខ៨៥៤/១៩៩៩ រវាង Wackenheim *និងប្រទេសបារាំង កថាខណ្ឌទី៦.៣។*

៥. ការដកហូតសេរីភាពពាក់ព័ន្ធនឹងការរឹតបន្តឹងកាន់តែធ្ងន់ធ្ងរថែមទៀតនៃចលនានៅក្នុងលំហកាន់តែតូច ជាជាងគ្រាន់តែការជ្រៀតជ្រែកដល់សេរីភាពនៃការដើរហើរ ក្រោមមាត្រា១២។[២] ឧទាហរណ៍នៃការដកហូតសេរីភាព រួមមាន ការឃាត់ខ្លួននៅនគរបាល "ការនាំខ្លួនមកឆ្លើយនៅមុខតុលាការ" [៣] ការបញ្ជូនទៅកន្លែងឃុំខ្លួនវិញបន្ទាប់ពីជំនុំជម្រះក្តីរួច ការដាក់ពន្ធនាគារបន្ទាប់ពីការកាត់ទោសរួច ការឃុំខ្លួនក្នុងផ្ទះ[៤] ការឃុំខ្លួនបែបរដ្ឋបាល ការដាក់ឲ្យសម្រាកពេទ្យដោយមិនស្ម័គ្រចិត្ត[៥] ការដាក់កុមារឲ្យស្ថិតនៅក្នុងការគ្រប់គ្រងជាស្ថាប័ន និងការបង្ខាំងនៅក្នុងកន្លែងដាក់កំហិតមួយនៃអាកាសយានដ្ឋាន[៦] និងរួមទាំងការដឹកជញ្ជូនដោយបង្ខំផងដែរ។[៧] ការដកហូតសេរីភាពក៏រួមបញ្ចូលផងដែរនូវការកំហិតបន្ថែមទៀតទៅលើបុគ្គល ដែលត្រូវបានឃុំខ្លួនរួចទៅហើយនោះ ឧទាហរណ៍ ការឃុំខ្លួនអ្នកទោសដាច់ដោយឡែកតែឯង ឬឧបករណ៍កំហិតផ្លូវកាយ។[៨] ក្នុងអំឡុងពេលបម្រើកងទ័ព ការដាក់កំហិតទាំងឡាយដែលក្លាយជាការដកហូតសេរីភាព

[២]. បណ្តឹងលេខ២៦៣/១៩៨៧ រវាង González del Río និងប្រទេសប៉េរូ កថាខណ្ឌ៥.១។ បណ្តឹងលេខ៨៣៣/១៩៩៨ រវាងKarker និងប្រទេសបារាំង កថាខណ្ឌ៨.៥។

[៣]. សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសម៉ិចស៊ីកូ ឆ្នាំ២០១០ កថាខណ្ឌ១៥។

[៤] បណ្តឹងលេខ១១៣៤/២០០២ រវាង Gorji-Dinka និងប្រទេសកាំមឺរូន កថាខណ្ឌ៥.៤។ សូមមើលផងដែរសេចក្តីសង្កេតសន្និដ្ឋានសំរាប់ចក្រភពអង់គ្លេស ឆ្នាំ២០០៨ កថាខណ្ឌ១៧ (បទបញ្ជាត្រួតពិនិត្យ រួមទាំងបំរាមគោចរលើសពី១៦ម៉ោង)។

[៥] បណ្តឹងលេខ៧៥៤/១៩៩៧ រវាង A និងប្រទេសណូវែលហ្សេឡង់ដ៍ កថាខណ្ឌ៧.២ (សុខភាពផ្លូវចិត្ត)។ សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសម៉ុលដូវ៉ា ឆ្នាំ២០០៩ កថាខណ្ឌ១៣ (ជំងឺឆ្លង)។

[៦]. សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសប៊ែលហ្ស៊ិក ឆ្នាំ២០០៤ កថាខណ្ឌ១៧ (ការឃុំខ្លួនជនអន្តោរប្រវេសន៍រង់ចាំការបញ្ជូនត្រឡប់ទៅវិញ)។

[៧]. បណ្តឹងលេខ R.12/52 រវាង Saldías de López និងប្រទេសអ៊ុយរុយហ្គាយ កថាខណ្ឌ១៣។

[៨]. សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់សាធារណរដ្ឋឆែក ឆ្នាំ២០០៧ កថាខណ្ឌ១៣។ និងសេចក្តីសង្កេតសន្និដ្ឋានសំរាប់សាធារណរដ្ឋកូរ៉េ ឆ្នាំ២០០៦ កថាខណ្ឌ១៣។

សម្រាប់ជនស៊ីវិលម្នាក់នោះ អាចមិនមែនជាការដកហូតសេរីភាពនោះទេ ប្រសិនបើការដាក់កំហិតទាំងនោះ មិនលើសពីភាពចាំបាច់នៃការបម្រើកងទ័ពជាធម្មតា ឬមិនខុសពីលក្ខខណ្ឌធម្មតានៃជីវិតនៅក្នុងកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋភាគីដែលពាក់ព័ន្ធនោះ។[៩]

៦. ការដកហូតសេរីភាពបុគ្គល គឺគ្មានការយល់ព្រមដោយសេរីនោះទេ។ បុគ្គលដែលទៅប៉ុស្តិ៍នគរបាលដោយស្ម័គ្រចិត្ត ដើម្បីចូលរួមក្នុងការស៊ើបអង្កេត និងបុគ្គលដែលដឹងថា ពួកគេមានសិទ្ធិទៅទៅវិញនៅពេលណាក៏បាន គឺមិនត្រូវបានគេដកហូតសេរីភាពរបស់ខ្លួនឡើយ។[១០]

៧. រដ្ឋភាគីមានករណីកិច្ចចាត់វិធានការសមស្រប ដើម្បីការពារសិទ្ធិមានសេរីភាពរបស់មនុស្ស ប្រឆាំងនឹងការដកហូតដោយបុគ្គលទីបី។[១១] រដ្ឋភាគីត្រូវការពារបុគ្គលពីការចាប់ជំរិត ឬការឃុំខ្លួនដោយឧក្រិដ្ឋជន ឬក្រុមមិនធម្មតានានា រួមទាំង ក្រុមប្រដាប់អាវុធ ឬក្រុមភេរវករដែលប្រតិបត្តិការនៅក្នុងទឹកដីរបស់ខ្លួន។ រដ្ឋក៏ត្រូវការពារបុគ្គលផងដែរពីការដកហូតសេរីភាពដោយមិនត្រឹមត្រូវ ដោយអង្គការមិនស្របច្បាប់នានា ដូចជា និយោជិក សាលារៀន និងមន្ទីរពេទ្យជាដើម។ រដ្ឋភាគីគួរខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ដើម្បីចាត់វិធានការសមស្របក្នុងការការពារបុគ្គលពីការដកហូតសេរីភាពដោយអំពើរបស់រដ្ឋដទៃទៀតនៅក្នុងដែនដីរបស់ខ្លួន។[១២]

---

[៩]. បណ្តឹងលេខ ២៦៥/១៩៨៧ រវាង Vuolanne និងប្រទេសហ្វាំងឡង់ កថាខណ្ឌ៩.៤។

[១០]. បណ្តឹងលេខ១៧៥៨/២០០៨ រវាង Jessop និងប្រទេសណូវែលហ្សេឡង់ត៍ កថាខណ្ឌ៧.៩-៧.១០។

[១១]. សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសយេម៉ែន ឆ្នាំ២០១២ កថាខណ្ឌ២៤។

[១២]. បណ្តឹងលេខ៣១៩/១៩៨៨ រវាង Cañón García និងប្រទេសអេក្វាទ័រ កថាខណ្ឌ៥.១-៥.២។

៨. នៅពេលបុគ្គលឯកជន ឬនីតិបុគ្គល ត្រូវបានផ្តល់សិទ្ធិអំណាចជូន ឬអនុញ្ញាតដោយរដ្ឋភាគី ដើម្បីប្រើប្រាស់អំណាចចាប់ខ្លួន ឬឃុំខ្លួន រដ្ឋភាគីនោះនៅតែទទួលខុសត្រូវលើការប្រកាន់ខ្ជាប់ និងធានាពីការប្រកាន់ខ្ជាប់តាមមាត្រា៩។ រដ្ឋភាគីត្រូវតែកំហិតអំណាចទាំងនោះដោយតឹងរឹងបំផុត ហើយត្រូវធ្វើការត្រួតពិនិត្យឲ្យបានតឹងរឹង និងមានប្រសិទ្ធភាពដើម្បីធានាថា អំណាចទាំងនោះមិនត្រូវបានយកទៅប្រើប្រាស់ខុស និងមិននាំទៅរកការចាប់ខ្លួន ឬឃុំខ្លួនដោយខុសច្បាប់ឬតាមទំនើងចិត្តឡើយ។ រដ្ឋភាគីត្រូវតែផ្តល់ផងដែរនូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាពដល់ជនរងគ្រោះ ប្រសិនបើការចាប់ខ្លួន ឬឃុំខ្លួនតាមទំនើងចិត្ត ឬដោយខុសច្បាប់នោះ កើតឡើង។[១៣]

៩. សិទ្ធិទទួលបានសន្តិសុខរបស់មនុស្ស ការពារបុគ្គលប្រឆាំងនឹងការបង្ករបួសដោយចេតនាដល់រាងកាយ ឬផ្លូវចិត្ត ដោយមិនគិតពីជនរងគ្រោះជាប់ឃុំ ឬមិនជាប់ឃុំនោះឡើយ។ ឧទាហរណ៍ មន្ត្រីរបស់រដ្ឋភាគី រំលោភសិទ្ធិទទួលបានសន្តិសុខផ្ទាល់ខ្លួន នៅពេលពួកគេបង្ករបួសផ្លូវកាយដោយគ្មានហេតុផល។[១៤] សិទ្ធិទទួលបានសន្តិសុខផ្ទាល់ខ្លួន ក៏តម្រូវផងដែរឲ្យរដ្ឋភាគី ចាត់វិធានការសមស្របក្នុងការឆ្លើយតបទៅនឹងការគំរាមសម្លាប់មនុស្ស នៅក្នុងទីសាធារណៈ និងកាន់តែទូទៅជាងនេះ ដើម្បីការពារបុគ្គលទាំងឡាយពីការគំរាមកំហែងដែលមើលឃើញជាមុន ចំពោះអាយុជីវិត ឬបូរណភាពរាង

[១៣] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសហ្កាតេម៉ាឡា ឆ្នាំ២០១២ កថាខណ្ឌ១៦។

[១៤] បណ្តឹងលេខ៦១៣/១៩៩៥ រវាង*Leehong និងប្រទេសចាម៉េកា កថាខ័ណ្ឌទី៩.៣។*

កាយដែលបង្កឡើងពីវិស័យណាមួយរបស់រដ្ឋាភិបាល ឬឯកជន។[១៥] រដ្ឋភាគីត្រូវចាត់វិធានការខាងមុខសមស្របនានា ដើម្បីបង្ការការបង្ករបួសនាពេលអនាគតនិងវិធានការប្រតិសកម្មនានា ដូចជាការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងការឆ្លើយតបទៅនឹងការបង្ករបួសកាលពីអតីត។ ឧទាហរណ៍ រដ្ឋភាគីត្រូវឆ្លើយតបដោយសមស្របទៅនឹងលំនាំនៃអំពើហិង្សាប្រឆាំងនឹងបុគ្គលនានា ដូចជាការបំភិតបំភ័យដល់អ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន ការសងសឹកដល់សាក្សី អំពើហិង្សាលើស្ត្រី រួមទាំងអំពើហិង្សាក្នុងគ្រួសារ ការដាក់ទណ្ឌកម្មលត់ដំដល់កូនទាហានដែលជាប់កំណែនថ្មី អំពើហិង្សាលើកុមារ អំពើហិង្សាលើមនុស្សដោយសារតែទំនោរផ្លូវភេទ ឬអត្តសញ្ញាណភេទ[១៦] និងអំពើហិង្សាលើជនពិការ។[១៧] រដ្ឋភាគីក៏គួរបង្ការនិងកែសម្រួលការប្រើប្រាស់កម្លាំងដោយមិនសមហេតុផល នៅក្នុងការអនុវត្តច្បាប់[១៨] និងការពារប្រជាជនរបស់ពួកគេពីការរំលោភបំពានដោយកម្លាំងសន្តិសុខឯកជន ព្រមទាំងប្រឆាំងនឹងហានិភ័យដែលបង្កឡើងដោយការ

---

[១៥] បណ្ដឹងលេខ១៥៦០/២០០៧ រវាង*Marcellana និង Gumanoy* ជាមួយប្រទេសហ្វីលីពីន កថាខ័ណ្ឌទី៧.៧។ រដ្ឋភាគីក៏បំពានសិទ្ធិទទួលបានសន្តិសុខរបស់មនុស្សដែរ ប្រសិនបើរដ្ឋនោះមានបំណងអនុវត្តយុត្តាធិការរបស់ខ្លួនទៅលើបុគ្គលម្នាក់នោះ នៅក្រៅដែនដីរបស់ខ្លួន ដោយការប្រើប្រាស់ទោសប្រហារជីវិត ជាភាសាដើម fatwa អនុញ្ញាតិឲ្យសំលាប់ជនរងគ្រោះ។ សូមមើលសេចក្ដីសង្កេតសន្និដ្ឋានសំរាប់សាធារណៈរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ ឆ្នាំ១៩៩៣ កថាខណ្ឌទី៩។ ក៏សូមមើលផងដែរកថាខ័ណ្ឌទី៦៣ នៃសេចក្ដីពន្យល់ទូទៅនេះ (ការពិភាក្សាពីការអនុវត្តក្រៅដែនដីយុត្តាធិការ)

[១៦] សូមមើលសេចក្ដីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអែលសាល់វ៉ាឌ័រ ឆ្នាំ២០០៣ កថាខណ្ឌទី១៦។

[១៧]. សូមមើលសេចក្ដីសង្កេតសន្និដ្ឋានសំរាប់ប្រទេសណ័រវេស ឆ្នាំ២០១១ កថាខណ្ឌទី១០។

[១៨]. បណ្ដឹងលេខ៦១៣/១៩៩៥ រវាងLeehong និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៩.៣។ និងសូមមើលផងដែរ គោលការណ៍ជាមូលដ្ឋានស្ដីពីការប្រើប្រាស់កំលាំង និងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ (១៩៩០)។

ប្រើប្រាស់អាវុធច្រើនហួសហេតុ។[១៩] សិទ្ធិទទួលបានសន្តិសុខរបស់មនុស្ស មិនមែនដោះស្រាយលើគ្រប់ហានិភ័យចំពោះសុខភាពផ្លូវកាយ ឬផ្លូវចិត្តនោះទេ ហើយក៏មិនពាក់ព័ន្ធនឹងផលប៉ះពាល់លើសុខភាពដោយប្រយោល ដោយសារតែបុគ្គលនោះ ជាគោលដៅនៃដំណើរការក្តីរដ្ឋប្បវេណី ឬព្រហ្មទណ្ឌនោះដែរ។[២០]

[១៩] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសហ្វីលីពីន ឆ្នាំ២០១២ កថាខណ្ឌទី១៤។

[២០.] បណ្តឹងលេខ១១២៤/២០០២ រវាងObodzinsky និងប្រទេសកាណាដា កថាខ័ណ្ឌទី៨.៥។

## II. ការឃុំខ្លួនតាមទំនើងចិត្ត និងការឃុំខ្លួនដោយមិនត្រឹមត្រូវតាមច្បាប់

១០. សិទ្ធិទទួលបានសេរីភាពរបស់មនុស្សមិនមែនជាសិទ្ធិដាច់ខាតនោះទេ។ មាត្រា៩ ទទួលស្គាល់ថា ជួនកាល ការដកហូតសេរីភាពត្រូវបានធ្វើយុត្តិកម្ម តួយ៉ាងនៅក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌ។ កថាខណ្ឌទី១ តម្រូវថា ការដកហូតសេរីភាពមិនត្រូវធ្វើតាមទំនើងចិត្តនោះទេ ហើយត្រូវអនុវត្តតាមគោលការណ៍នីតិរដ្ឋ។

១១. ប្រយោគទីពីរនៃកថាខណ្ឌទី១ ហាមឃាត់ការចាប់ខ្លួន និងការឃុំខ្លួនតាមទំនើងចិត្តរីឯប្រយោគទីបី ហាមឃាត់ការដកហូតសេរីភាពដោយមិនធ្វើត្រឹមត្រូវតាមច្បាប់ ពោលគឺការដកហូតសេរីភាពដែលមិនផ្អែកតាមហេតុផលបែបនេះ និងស្របតាមនីតិវិធីដែលមានកំណត់ក្នុងច្បាប់។ ការហាមឃាត់ទាំងពីរនេះមានន័យត្រួតគ្នាត្រង់ថា ការចាប់ខ្លួន ឬការឃុំខ្លួន អាចជាការរំលោភច្បាប់ដែលនៅជាធរមាន ប៉ុន្តែមិនតាមទំនើងចិត្ត ឬត្រូវបានច្បាប់អនុញ្ញាត ប៉ុន្តែតាមទំនើងចិត្ត ឬធ្វើទាំងតាមទំនើងចិត្ត និងមិនត្រឹមត្រូវតាមច្បាប់។ ការចាប់ខ្លួន ឬការឃុំខ្លួនដែលខ្វះមូលដ្ឋានច្បាប់ណាមួយ ក៏ជាការធ្វើតាមទំនើងចិត្តដែរ។[២១] ការឃុំខ្លួនអ្នកទោសដោយគ្មានការអនុញ្ញាតហួសពីរយៈពេលនៃការផ្តន្ទាទោសរបស់ពួកគេ គឺជាអំពើធ្វើតាមទំនើងចិត្ត ហើយក៏មិនត្រឹមត្រូវតាមច្បាប់ដែរ[២២] ក៏ដូចជាការ

[២១] បណ្តឹងលេខ៤១៤/១៩៩០ រវាង*Mika Miha និងប្រទេសហ្គីណេអេក្វាទ័រ កថាខ័ណ្ឌទី៦.៥។*

[២២] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសប្រេស៊ីល ឆ្នាំ២០០៥ កថាខ័ណ្ឌទី១៦។

ពន្យារពេលដោយគ្មានការអនុញ្ញាតនៃការឃុំខ្លួនតាមទម្រង់ផ្សេងៗទៀតដែរ។ ការបន្តឃុំខ្លួនជនជាប់ឃុំ ដោយរំលោភលើសេចក្តីបង្គាប់ឲ្យដោះលែងពីតុលាការ ក៏ជាការឃុំខ្លួនតាមទំនើងចិត្ត និងមិនត្រឹមត្រូវតាមច្បាប់ដែរ។[២៣]

**១២.** ការចាប់ខ្លួន ឬការឃុំខ្លួន អាចត្រូវបានអនុញ្ញាតដោយច្បាប់ជាតិ ប៉ុន្តែទោះជាយ៉ាងណា ក៏វានៅតែអាចធ្វើឡើងតាមទំនើងចិត្តដែរ។ សញ្ញាណនៃពាក្យ "ភាពតាមទំនើងចិត្ត" មិនត្រូវធ្វើន័យឲ្យស្មើគ្នានឹងពាក្យ "ប្រឆាំងនឹងច្បាប់" នោះទេ ប៉ុន្តែត្រូវយកមកបកស្រាយឲ្យបានទូលំទូលាយជាងនេះ ដើម្បីរួមបញ្ចូលធាតុផ្សំនានានៃភាពមិនសមស្រប អយុត្តិធម៌ កង្វះខាតភាពអាចព្យាករណ៍បាន និងដំណើរការត្រឹមត្រូវតាមនីតិវិធីច្បាប់[២៤] ក៏ដូចជាធាតុផ្សំនានានៃភាពសមហេតុផល ភាពចាំបាច់ និងសមាមាត្រ។ ឧទាហរណ៍ ការបញ្ជូនត្រឡប់ទៅឃុំខ្លួនវិញពីបទល្មើសព្រហ្មទណ្ឌ ត្រូវតែសមហេតុផល និងចាំបាច់ក្នុងគ្រប់កាលៈទេសៈ។[២៥] ក្រៅពីទោសដែលដាក់ដោយតុលាការសម្រាប់រយៈពេលកំណត់មួយ សេចក្តីសម្រេចរក្សាទុកជនណាម្នាក់នៅក្នុងឃុំតាមទម្រង់ណាក៏ដោយ គឺជាការធ្វើតាមទំនើងចិត្ត ប្រសិនបើការឃុំនេះ មិនស្ថិតក្រោមការវាយតម្លៃឡើងវិញជាទៀងទាត់អំពីយុត្តិកម្មនៃការបន្តឃុំខ្លួននេះ។[២៦]

---

[២៣]. បណ្តឹងលេខ៨៥៦/១៩៩៩ រវាង Chambala និងប្រទេសហ្សំបៀ កថាខ័ណ្ឌទី៧.៣។

[២៤]. បណ្តឹងលេខ១១៣៤/២០០២ រវាង Gorji-Dinka និងប្រទេសកាំម៉េរូន កថាខ័ណ្ឌទី៥.១។ និងបណ្តឹងលេខ៣០៥/១៩៨៨ រវាង Van Alphen និងប្រទេសហុលឡង់ដ៍ កថាខណ្ឌទី៥.៨។

[២៥]. បណ្តឹងលេខ១៣៦៩/២០០៥ រវាង Kulov និងប្រទេសកៀកជីស្ថាន កថាខណ្ឌទី៨.៣។ ការឃុំខ្លួនបណ្តោះអាសន្នក្នុងរឿងក្តីព្រហ្មទណ្ឌ ត្រូវយកមកពិភាក្សាគ្នាបន្ថែមទៀត នៅក្នុងផ្នែកទី៤ ខាងក្រោម នៃសេចក្តីពន្យល់ទូទៅនេះ។

[២៦]. សូមមើលឧទាហរណ៍នៃបណ្តឹងលេខ១៣២៤/២០០៤ រវាង Shafiq និងប្រទេសអូស្ត្រាលី កថាខណ្ឌទី៧.២។

១៣. ពាក្យ "ចាប់ខ្លួន" សំដៅដល់ការចាប់ខ្លួនមនុស្សណាម្នាក់ ដែលចាប់ផ្តើមពីការដកហូតសេរីភាព ហើយពាក្យ "ឃុំខ្លួន" សំដៅដល់ការដកហូតសេរីភាពដែលចាប់ផ្តើមដោយការចាប់ខ្លួន និងដែលបន្តក្នុងពេលចាប់ពីការចាប់ខ្លួន រហូតដល់ពេលដោះលែងវិញ។[២៧] ការចាប់ខ្លួននៅក្នុងអត្ថន័យនៃមាត្រា៩ មិនចាំបាច់ពាក់ព័ន្ធនឹងការចាប់ខ្លួនផ្លូវការ ដូចចែងក្នុងច្បាប់ជាតិនោះទេ។[២៨] នៅពេលមានការដកហូតសេរីភាពបន្ថែមទៀត ត្រូវបានធ្វើឡើងចំពោះមនុស្សម្នាក់ដែលស្ថិតក្នុងការឃុំខ្លួនរួចទៅហើយនោះ ដូចជា ការឃុំខ្លួនដោយសារបទព្រហ្មទណ្ឌដែលមិនពាក់ព័ន្ធ ការចាប់ផ្តើមនៃការដកហូតសេរីភាពនោះ ក៏មានន័យថាជាការចាប់ខ្លួនដែរ។[២៩]

១៤. កតិកាសញ្ញានេះ មិនចែងពីការរៀបរាប់អំពីហេតុផលដែលអាចធ្វើបានសម្រាប់ការដកហូតសេរីភាពរបស់មនុស្សម្នាក់ឡើយ។ មាត្រា ៩ ទទួលស្គាល់យ៉ាងច្បាស់ថា បុគ្គលនានាអាចត្រូវបានឃុំខ្លួនពីបទព្រហ្មទណ្ឌ ហើយមាត្រា១១ ហាមឃាត់យ៉ាងច្បាស់ពីការដាក់ពន្ធនាគារដោយមូលហេតុនៃការមិនអាចបំពេញបានតាមលក្ខខណ្ឌនៃកិច្ចសន្យា។[៣០] បទប្បញ្ញត្តិដទៃទៀតដែលពាក់ព័ន្ធនឹងការដកហូត

[២៧]. សូមមើលបណ្តឹងលេខ៦៣១/១៩៩៥ រវាង*Spakmo និងប្រទេសណ័រវេស* កថាខ័ណ្ឌទី៦.៣។

[២៨]. បណ្តឹងលេខ១៤៦០/២០០៦ រវាង Yklymova និងប្រទេសតៀកមេនីស្ថាន កថាខណ្ឌ៧.២-៧.៣ (ការចាប់ខ្លួនឃុំនៅផ្ទះតាមព្រឹត្តិហេតុ) បណ្តឹងលេខ១០៩៦/២០០២ រវាង Kurbanova និងប្រទេសតាជីគីស្ថាន កថាខណ្ឌទី៧.២ (ការឃុំខ្លួន មុនមានដីកាចាប់ខ្លួន)។

[២៩]. បណ្តឹងលេខ៦៣៥/១៩៩៨ រវាង Morrison និងប្រទេសចាម៉ៃកា កថាខណ្ឌទី២២.២-២២.៣។ និងបណ្តឹងលេខ១៣៩៧/២០០៥ រវាង Engo និងប្រទេសកាំមេរូន កថាខណ្ឌទី៧.៣។

[៣០]. ការឃុំខ្លួនក្នុងបទល្មើសព្រហ្មទណ្ឌ ដូចជាបទឆបោក ដែលពាក់ព័ន្ធនឹងបំណុលនៃច្បាប់រដ្ឋប្បវេណី មិនបំពានមាត្រា១១ទេ ហើយក៏មិនក្លាយជាការឃុំខ្លួនតាមទំនើងចិត្តដែរ។ បណ្តឹងលេខ១៣៤២/២០០៥ រវាង Gavrilin និងប្រទេសបេលឡារូស កថាខណ្ឌ៧.៣

សេរីភាព ក៏ត្រូវកំណត់ដោយច្បាប់ដែរ ហើយត្រូវតែអមដោយនីតិវិធីដែលទប់ស្កាត់ការឃុំខ្លួនតាមទំនើងចិត្ត។ មូលដ្ឋាន និងនីតិវិធីដែលកំណត់ដោយច្បាប់ មិនត្រូវបំផ្លាញសិទ្ធិមានសេរីភាពរបស់មនុស្សឡើយ។[៣១] បទប្បញ្ញត្តិនេះមិនត្រូវក្លាយជាការគេចចេញពីព្រំដែនកំណត់នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដោយការផ្តល់សមមូលនៃទណ្ឌកម្មព្រហ្មទណ្ឌ ដោយគ្មានការការពារជាធរមាននោះឡើយ។[៣២] ទោះបីជាលក្ខខណ្ឌនៃការឃុំខ្លួន ត្រូវបានបញ្ជាក់ជាបឋមដោយមាត្រា៧ និងមាត្រា១០ ក៏ដោយ ក៏ការឃុំខ្លួនអាចមានតាមទំនើងចិត្តដែរ ប្រសិនបើលក្ខណៈនៃការប្រព្រឹត្តិទៅលើជនជាប់ឃុំមិនត្រូវគ្នានឹងគោលបំណងនៃការឃុំខ្លួននោះ។[៣៣] ការដាក់ទោសដ៏ធ្ងន់ធ្ងរហួសហេតុឲ្យជាប់ពន្ធនាគារ ពីបទប្រមាថតុលាការដោយមិនមានការពន្យល់គ្រប់គ្រាន់ និងដោយគ្មានកិច្ចការពារតាមនីតិវិធីឯករាជ្យនោះ គឺមានន័យថា ធ្វើតាមទំនើងចិត្តហើយ។[៣៤]

១៥. នៅពេលណាដែលរដ្ឋភាគីធ្វើការឃុំខ្លួន ដោយហេតុផលសន្តិសុខ (ជូនកាលត្រូវបានស្គាល់ថាជាការឃុំខ្លួនផ្នែករដ្ឋបាល ឬការឃុំខ្លួន

---

[៣១]. បណ្តឹងលេខ១៦២៩/២០០៧ រវាង Fardon និងប្រទេសអូស្ត្រាលី កថាខណ្ឌទី៧.៣។

[៣២]. ដូចករណីខាងលើ កថាខណ្ឌទី៧.៤(ក)-៧.៤(គ)។ សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់សហរដ្ឋអាមេរិច ឆ្នាំ២០០៦ កថាខ័ណ្ឌទី១៩។ និងសេចក្តីពន្យល់ទូទៅលេខ៣២ កថាខណ្ឌទី១៥ និង១៨។

[៣៣] បណ្តឹងលេខ១៦២៩/២០០៧ រវាង Fardon និងប្រទេសអូស្ត្រាលី កថាខណ្ឌទី៧.៤(ក)។ សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសប៉ែលហ្ស៊ិក ឆ្នាំ២០០៤ កថាខណ្ឌទី១៦ (ការដាក់ឲ្យស្ថិតក្នុងពន្ធនាគារឧបសម្ពន្ធនៃអ្នកវិកលចារិក)។ សេចក្តីសង្កេតសន្និដ្ឋានសំរាប់ចក្រភពអង់គ្លេស ឆ្នាំ២០០១ កថាខណ្ឌ១៦ (ការឃុំខ្លួនអ្នកសុំសិទ្ធិជ្រកកោនក្នុងពន្ធនាគារ)

[៣៤]. បណ្តឹងលេខ១១៨៩/២០០៣ រវាង Fernando និងប្រទេសស្រីលង្កា កថាខណ្ឌទី៩.២។ និងបណ្តឹងលេខ១៣៧៣/២០០៥ រវាង Dissanakye និងប្រទេសស្រីលង្កា កថាខណ្ឌទី៨.៣។

ដោយសារហេតុផលគំរាមកំហែងដល់សន្តិសុខ) មិនមែនជាការផ្តន្ទាទោសពីបទព្រហ្មទណ្ឌ[៣៥] គណៈកម្មាធិការពិចារណាថា ការឃុំខ្លួនបែបនេះ បង្កជាហានិភ័យធ្ងន់ធ្ងរ ចំពោះការដកហូតសេរីភាពតាមទំនើងចិត្ត។[៣៦] ជាធម្មតា ការឃុំខ្លួនបែបនេះ គឺស្មើនឹងការឃុំខ្លួនតាមទំនើងចិត្ត ពីព្រោះថា មានវិធានការប្រកបដោយប្រសិទ្ធភាពផ្សេងទៀតសម្រាប់អនុវត្តដើម្បីដោះស្រាយបញ្ហាគំរាមកំហែងនោះ រួមទាំងតាមប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌផងដែរ។ ប្រសិនបើក្រោមកាលៈទេសៈពិសេសបំផុត មានការលើកឡើងថាមានការគំរាមកំហែងបច្ចុប្បន្ន ដោយផ្ទាល់ និងជាក់លាក់ ដើម្បីធ្វើយុត្តិកម្មពីការឃុំខ្លួនមនុស្ស ដែលត្រូវបានចាត់ទុកថា បង្កការគំរាមកំហែងបែបនេះ នោះបន្ទុកនៃភ័ស្តុតាងត្រូវស្ថិតលើរដ្ឋភាគីដែលត្រូវបង្ហាញថា បុគ្គលនោះបង្កការគំរាមកំហែងបែបនេះ ហើយថាគេមិនអាចមានវិធានការអ្វីផ្សេងឡើយ ហើយបន្ទុកនេះនឹងកើនឡើងជាមួយនឹងរយៈពេលនៃការឃុំខ្លួន។ រដ្ឋភាគីក៏ត្រូវបង្ហាញផងដែរថា ការឃុំខ្លួន មិនត្រូវលើសពីរយៈពេលចាំបាច់ជាដាច់ខាត ហើយរយៈពេលសរុបនៃការឃុំខ្លួនដែលអាចធ្វើឡើងត្រូវមានកម្រិត ព្រមទាំងថា ខ្លួនគោរពយ៉ាងពេញលេញនូវកិច្ចធានាការពារដូចមានចែងក្នុងមាត្រា៩ ក្នុងគ្រប់ករណី។ ការពិនិត្យឡើងវិញជាបន្ទាន់ និងទៀង

[៣៥]. កថាខណ្ឌនេះពាក់ព័ន្ធនឹងការឃុំខ្លួនដោយសារហេតុផលសន្តិសុខ គឺមិនមែនជាទម្រង់នៃការឃុំខ្លួនដើម្បីបង្ការក្រោយការផ្តន្ទាទោស ដូចមានរៀបរាប់នៅក្នុងកថាខណ្ឌទី២១ ខាងក្រោមនោះទេ ឬការឃុំខ្លួនសំរាប់ហេតុផលបត្យាប័ន ឬការត្រួតពិនិត្យអន្តោរប្រវេសន៍។ សូមមើលកថាខណ្ឌទី១៨ ខាងក្រោម នៃសេចក្តីពន្យល់ទូទៅនេះ។

[៣៦]. សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសកូឡំប៊ី ឆ្នាំ២០១០ កថាខណ្ឌទី២០ សំរាប់ប្រទេសហ្សកដង់ ឆ្នាំ២០១០ កថាខណ្ឌទី១១។

ទាត់ដោយតុលាការ ឬសាលាជម្រះក្តីដទៃទៀតដែលមានលក្ខណៈសម្បត្តិដូចគ្នា ទាំងឯករាជ្យភាព និងអនាគតិទៅនឹងតុលាការ គឺជាកិច្ចធានាការពារចាំបាច់មួយសម្រាប់លក្ខខណ្ឌទាំងនេះ ក៏ដូចជាការទទួលបានជំនួយផ្នែកច្បាប់ឯករាជ្យ ជាពិសេស ដែលជ្រើសរើសដោយជនជាប់ឃុំ និងការបង្ហាញដល់ជនជាប់ឃុំ យ៉ាងហោចណាស់ នូវភ័ស្តុតាងស្នូលដល់ការធ្វើសេចក្តីសម្រេចបែបនោះ។[៣៧]

១៦. ឧទាហរណ៍យ៉ាងច្បាស់នៃការឃុំខ្លួនតាមទំនើងចិត្ត រួមមាន ការឃុំខ្លួនសមាជិកគ្រួសាររបស់ឧក្រិដ្ឋជនជាប់ចោទ ដែលមិនត្រូវបានគេចោទប្រកាន់ពីការប្រព្រឹត្តខុសណាមួយ ការចាប់ជាចំណាប់ខ្មាំង និងការចាប់ខ្លួនសម្រាប់គោលបំណងជំរិតទារសំណូក ឬសំរាប់គោលបំណងឧក្រិដ្ឋកម្មស្រដៀងគ្នាដទៃទៀត។

១៧. ការចាប់ ឬការឃុំខ្លួន ទុកជាការដាក់ទណ្ឌកម្មចំពោះការប្រើប្រាស់សិទ្ធិស្របច្បាប់ដូចត្រូវបានធានាការពារដោយកតិកាសញ្ញានេះ គឺជាការធ្វើតាមទំនើងចិត្ត រួមទាំងសេរីភាពនៃគំនិត និងការបញ្ចេញមតិ (មាត្រា១៩)[៣៨] សេរីភាពនៃការប្រមូលផ្តុំ (មាត្រា២១) សេរីភាពសមាគម (មាត្រា២២) សេរីភាពសាសនា (មាត្រា១៨) និងសិទ្ធិជាឯកជន (មាត្រា១៧)។ ការចាប់ខ្លួន ឬការឃុំខ្លួនដោយសារការរើសអើង ដែលរំលោភលើមាត្រា២ កថាខណ្ឌទី១ មាត្រា៣ ឬ

---

[៣៧] អំពីទំនាក់ទំនងរវាងមាត្រា៩ និងមាត្រា៤ នៃកតិកាសញ្ញានេះ និងច្បាប់មនុស្សធម៌អន្តរជាតិ សូមមើលកថាខណ្ឌទី៦៤ និង៦៧ ខាងក្រោមនៃសេចក្តីពន្យល់ទូទៅនេះ។

[៣៨] បណ្តឹងលេខ៣២៨/១៩៨៨ រវាង Zelaya Blanco និងប្រទេសនីការ៉ាហ្គ័រ កថាខណ្ឌទី១០.៣។

មាត្រា២៦ ក៏ជាការធ្វើតាមទំនើងចិត្តដែរជាគោលការណ៍។[៣៩] ការដាក់ទោសព្រហ្មទណ្ឌប្រតិសកម្មដោយការឃុំខ្លួន ដែលរំលោភលើមាត្រា១៥ ក៏ជាការឃុំខ្លួនតាមទំនើងចិត្ត។[៤០] ការបាត់ខ្លួនដោយបង្ខំបំពានបទប្បញ្ញត្តិសំខាន់ និងនីតិវិធីជាច្រើននៃកតិកាសញ្ញា និងបង្កើតជាទម្រង់ធ្ងន់ធ្ងរដោយឡែកមួយនៃការឃុំខ្លួនតាមទំនើងចិត្ត។ ការដាក់ពន្ធនាគារ បន្ទាប់ពីការជំនុំជម្រះដោយមិនយុត្តិធម៌យ៉ាងច្បាស់ក្រឡែត គឺជាការធ្វើតាមទំនើងចិត្ត ប៉ុន្តែមិនមែនរាល់ការរំលោភលើការធានាតាមនីតិវិធីជាក់លាក់ សម្រាប់ចុងចោទនៃបទព្រហ្មទណ្ឌក្នុងមាត្រា១៤ ក្លាយជាការឃុំខ្លួនតាមទំនើងចិត្តនោះឡើយ។[៤១]

១៨. ការឃុំខ្លួនក្នុងពេលដំណើរការក្តីសម្រាប់ការគ្រប់គ្រងអន្តោរប្រវេសន៍មិនមែនជាការធ្វើតាមទំនើងចិត្ត*ដោយផ្ទាល់នោះទេ* ប៉ុន្តែការឃុំខ្លួនត្រូវតែមានហេតុផលសមស្រប ចាំបាច់ និងសមាមាត្រទៅតាមកាលៈទេសៈ និងធ្វើការវាយតម្លៃឡើងវិញទៅតាមពេលវេលា។[៤២]

---

៣៩. បណ្តឹងលេខ១៣១៤/២០០៤ រវាង O'Neill & Quinn និងប្រទេសអៀកឡង់ដ៍ កាថាខណ្ឌទី៨.៥ (រកមិនឃើញមានការរំលោភបំពាន)។ សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសហុងឧុយរ៉ាស់ ឆ្នាំ២០០៦ កថាខណ្ឌ ទី១៣ (ការឃុំខ្លួនដោយសារនិន្នាការផ្លូវភេទ)។ សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសកាំមីរូន ឆ្នាំ២០១០ កថាខណ្ឌទី១២ (ការដាក់ពន្ធនាគារចំពោះអ្នកពេញវ័យដែលស្រលាញ់ភេទដូចគ្នាដោយស្ម័គ្រចិត្ត)។

៤០. បណ្តឹងលេខ១៦២៩/២០០៧ រវាង Fardon និងប្រទេសអូស្ត្រាលី កថាខណ្ឌទី៧.៤(ខ)។

៤១. បណ្តឹងលេខ១០០៧/២០០១ រវាង Sineiro Fernández និងប្រទេសអេស្ប៉ាញ កថាខណ្ឌទី៦.៣ (អវត្តមាននៃការពិនិត្យឡើងវិញអំពីការផ្តន្ទាទោស ដោយតុលាការជាន់ខ្ពស់ បានបំពានកថាខណ្ឌ៥ នៃមាត្រា១៤ មិនមែនកថាខណ្ឌទី១ នៃមាត្រា៩ទេ)

៤២. បណ្តឹងលេខ៥៦០/១៩៩៣ រវាងA និងប្រទេសអូស្ត្រាលី កថាខណ្ឌទី៩.៣-៩.៤។ បណ្តឹងលេខ៧៩៤/១៩៩៨ រវាង Jalloh និងប្រទេសហូឡង់ដ៍ កថាខណ្ឌទី៨.២។ និងបណ្តឹងលេខ១៥៥៧/២០០៧ រវាង Nystrom និងប្រទេសអូស្ត្រាលី កថាខណ្ឌទី៧.២-៧.៣

អ្នកសុំសិទ្ធិជ្រកកោន ដែលចូលមកក្នុងទឹកដីរបស់រដ្ឋភាគីដោយមិនស្របច្បាប់ អាចត្រូវបានឃុំខ្លួនមួយរយៈពេលខ្លីជាដំបូង ដើម្បីធ្វើកំណត់ហេតុពីការចូលរបស់ពួកគេ កត់ត្រាទុកនូវការទាមទាររបស់ពួកគេ ហើយកំណត់ពីអត្តសញ្ញាណរបស់ពួកគេ ប្រសិនបើមានការសង្ស័យ។[៤៣] ការឃុំខ្លួនពួកគេបន្ថែមទៀត ខណៈដែលកំពុងដោះស្រាយការទាមទាររបស់ពួកគេ គឺជាការឃុំខ្លួនតាមទំនើងចិត្តដែរ ដោយហេតុថាពុំមានហេតុផលដោយឡែកៗ ជាក់លាក់សម្រាប់បុគ្គលម្នាក់ៗ ដូចជា ភាពដូចគ្នាជាបុគ្គលនៃការរត់គេច គ្រោះថ្នាក់នៃអំពើល្មើសចំពោះអ្នកដទៃ ឬហានិភ័យនៃអំពើប្រឆាំងសន្តិសុខជាតិ។[៤៤] សេចក្តីសម្រេច ត្រូវតែពិចារណាទៅលើកត្តាពាក់ព័ន្ធនានា ម្តងមួយករណីៗ និងមិនផ្អែកលើវិធានជាកាតព្វកិច្ចសម្រាប់ប្រភេទទូលាយមួយឡើយ ត្រូវពិចារណាអំពីមធ្យោបាយដែលមិនមានលក្ខណៈប្រទូស្តរាយ ចំពោះការសម្រេចបានគោលដៅដូចគ្នា ដូចជា កាតព្វកិច្ចរាយការណ៍ សិទ្ធិប្រត្យក្ស ឬលក្ខខណ្ឌផ្សេងទៀត ដើម្បីទប់ស្កាត់ការរត់គេច និងត្រូវស្ថិតក្រោមការវាយតម្លៃឡើងវិញ និងការពិនិត្យឡើងវិញតាមផ្លូវតុលាការ ឱ្យបានទៀងទាត់ ។[៤៥]

---

[៤៣]. បណ្តឹងលេខ១០៦៩/២០០២ រវាង Bakhtiyari និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៩.២-៩.៣។

[៤៤]. បណ្តឹងលេខ១៥៥១/២០០៧ រវាង Tarlue និងប្រទេសកាណាដា កថាខ័ណ្ឌទី៣.៣-៧.៦។ បណ្តឹងលេខ១០៥១/២០០២ រវាងAhani និងប្រទេសកាណាដា កថាខ័ណ្ឌទី១០.២។

[៤៥]. បណ្តឹងលេខ១០១៤/២០០១ រវាង Baban និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៧.២។ បណ្តឹងលេខ១០៦៩/២០០២ រវាង Bakhtiyari និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៩.២-៩.៣។ សូមមើលគោលការណ៍ណែនាំរបស់ឧត្តមស្នងការជនភៀសខ្លួន ស្តីពីលក្ខណៈវិនិច្ឆ័យ និងបទដ្ឋានដែលអាចអនុវត្តបាន ទាក់ទងនឹងការឃុំខ្លួនជនស្វែងរកសិទ្ធិជ្រកកោន និងជំរើសផ្សេងក្រៅពីការឃុំខ្លួន(២០១២) គោលការណ៍ណែនាំ៤.៣ និងឧបសម្ព័ន្ធ **ក** (ការបរិយាយពីជំរើសផ្សេងក្រៅពីការឃុំខ្លួន)។

សេចក្តីសម្រេចអំពីការឃុំខ្លួនជនទេសន្តរប្រវេសន៍ ត្រូវយកចិត្តទុកដាក់អំពីផលប៉ះពាល់នៃការឃុំខ្លួន លើសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគេ។[៤៦] រាល់ការឃុំខ្លួនណាមួយដែលចាំបាច់ គួរតែធ្វើឡើងនៅក្នុងទីកន្លែងដែលសមស្រប អនាម័យ មិនដាក់ទណ្ឌកម្ម ហើយមិនគួរដាក់នៅក្នុងពន្ធនាគារឡើយ។ ការមិនមានលទ្ធភាពរបស់រដ្ឋភាគី ដើម្បីបញ្ជូនជនណាមួយ ដោយសារតែភាពគ្មានរដ្ឋ ឬឧបសគ្គផ្សេងៗទៀត មិនត្រូវយកធ្វើយុត្តិកម្មនៃការឃុំខ្លួនមិនកំណត់នោះទេ។[៤៧] កុមារមិនត្រូវបានដកហូតសេរីភាពនោះទេ លើកលែងតែនោះជាវិធានការចុងក្រោយបំផុត និងសម្រាប់តែរយៈពេលសមស្របខ្លីបំផុត ដោយពិចារណាអំពីឧត្តមប្រយោជន៍របស់កុមារ ថាជាការពិចារណាបឋម ទាក់ទងទៅនឹងរយៈពេល និងលក្ខខណ្ឌនៃការឃុំខ្លួន ក៏ដូចជាពិចារណាអំពីភាពងាយរងគ្រោះហួសហេតុ និងតម្រូវការថែទាំអនីតិជនដែលគ្មានមនុស្សពេញវ័យនៅជាមួយ។[៤៨]

១៩. រដ្ឋភាគីគួរកែសម្រួលច្បាប់ និងការអនុវត្តន៍នានាដែលហួសសម័យនៅក្នុងវិស័យសុខភាពផ្លូវចិត្ត ដើម្បីបញ្ចៀសការឃុំខ្លួនតាមទំនើងចិត្ត។ គណៈកម្មាធិការគូសបញ្ជាក់ពីគ្រោះថ្នាក់ដែលមានជាប់ជា

[៤៦]. បណ្តឹងលេខ១៣២៤/២០០៤ រវាងShafiq និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៧.៣។ បណ្តឹងលេខ ៩០០/១៩៩៩ រវាង C និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៨.២-៨.៤។

[៤៧]. បណ្តឹងលេខ២០៩៤/២០១១ រវាង F.K.A.G និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៩.៣។

[៤៨]. បណ្តឹងលេខ១០៥០/២០០២ រវាង D. & E. និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៧.២។ បណ្តឹងលេខ ៧៩៤/១៩៩៨ រវាង Jalloh និងប្រទេសហូឡង់ដ៏ កថាខ័ណ្ឌទី៨.២-៨.៣។ សូមមើលផងដែរអនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា៣(១) និងមាត្រា៣៧(ខ)។

មួយនឹងការដកហូតសេរីភាពណាមួយ និងគួសបញ្ជាក់ផងដែរពីគ្រោះថ្នាក់ដោយឡែក ដែលអាចបណ្តាលឲ្យទៅជាស្ថានភាពនៃការសម្រាកពេទ្យដោយមិនស្ម័គ្រចិត្ត។ រដ្ឋភាគីគួរតែរៀបចំឲ្យមានសេវាថែទាំសង្គមនៅតាមសហគមន៍ ឬជាជម្រើសនានាឲ្យបានគ្រប់គ្រាន់ដល់ជនពិការផ្នែកចិត្តសង្គម ដើម្បីផ្តល់ជាជម្រើសជំនួសដែលមានលក្ខណៈស្រាលជាងការឃុំខ្លួន។[៤៩] ពិការភាពមិនត្រូវប្រើប្រាស់ជាហេតុផលដើម្បីដកហូតសេរីភាពនោះទេ ប៉ុន្តែការដកហូតសេរីភាព ត្រូវតែមានលក្ខណៈចាំបាច់ និងសមាមាត្រ សម្រាប់គោលបំណងការពារបុគ្គលដែលពាក់ព័ន្ធនោះ ពីគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬបង្ការពីការបង្ករបួសស្នាមដល់អ្នកដទៃ។[៥០] គេត្រូវតែអនុវត្តវាជាវិធានការចុងក្រោយបំផុតប៉ុណ្ណោះ និងសម្រាប់រយៈពេលខ្លីសមរម្យ និងត្រូវតែអមដោយកិច្ចធានាការពារចំបងៗ និងតាមនីតិវិធីគ្រប់គ្រាន់ដែលបង្កើតដោយច្បាប់។[៥១] នីតិវិធីគួរធានាដល់ការគោរពទស្សនៈរបស់បុគ្គល និងគួរធានាថា អ្នកតំណាងណាក៏ដោយ ត្រូវតែជាអ្នកតំណាងយ៉ាងពិតប្រាកដ និងការពារបំណងប្រាថ្នា និងផលប្រយោជន៍របស់បុគ្គលនោះ។[៥២] រដ្ឋភាគីត្រូវផ្តល់កម្មវិធីឲ្យទៅជាស្ថាប័ននៃការព្យាបាល និងការស្តារនីតិសម្បទាដល់បុគ្គលនោះ

[៤៩] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសឡាតវី ឆ្នាំ២០១៤ កថាខ័ណ្ឌទី១៦។

[៥០] បណ្តឹងលេខ១០៦២/២០០២ រវាង Fijalkowska និងប្រទេសប៉ូឡូញ កថាខ័ណ្ឌទី៨.៣។ បណ្តឹងលេខ១៦២៩/២០០៧ រវាង Fardon និងប្រទេសអូស្ត្រាលី កថាខណ្ឌទី៧.៣។ សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់សហព័ន្ធរុស្ស៊ី ឆ្នាំ២០០៩ កថាខ័ណ្ឌទី១៩។ អនុសញ្ញាស្តីពីសិទ្ធិជនពិការ មាត្រា១៤(១)(ខ)។

[៥១] បណ្តឹងលេខ១០៦២/២០០២ រវាង Fijalkowska និងប្រទេសប៉ូឡូញ កថាខ័ណ្ឌទី៨.៣។

[៥២] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់សាធារណៈរដ្ឋឆែក ឆ្នាំ២០០៧ កថាខ័ណ្ឌទី១៤។ សូមមើលផងដែរសេចក្តីពន្យល់ទូទៅលេខ៩ របស់គណៈកម្មាធិការសិទ្ធិកុមារ កថាខ័ណ្ឌទី៤៨។

ដែលបម្រើឲ្យគោលបំណងនានាដែលត្រូវបានអះអាង ដើម្បីធ្វើយុត្តិកម្មដល់ការឃុំខ្លួន។[៥៣] ការដកហូតសេរីភាព ត្រូវតែធ្វើការវាយតម្លៃឡើងវិញឲ្យបានទៀងទាត់ សមស្របទាក់ទងទៅនឹងភាពចាំបាច់នៃការបន្តឃុំខ្លួននោះ។[៥៤] បុគ្គលត្រូវទទួលបានការគាំទ្រក្នុងការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាពសម្រាប់ថែរក្សាសិទ្ធិរបស់ពួកគេ រួមទាំងការពិនិត្យឡើងវិញដំបូង និងទៀងទាត់តាមផ្លូវតុលាការពីភាពស្របច្បាប់នៃការឃុំខ្លួន និងដើម្បីបង្ការលក្ខខណ្ឌនៃការឃុំខ្លួន មិនផ្ទុយនឹងកតិកាសញ្ញានេះ។[៥៥]

២០. កតិកាសញ្ញានេះ មានសង្គតិភាពជាមួយភាពផ្សេងៗនៃគំរោងដាក់ទោសព្រហ្មទណ្ឌ។ អ្នកទោសដែលបានកាត់ទោសរួច ត្រូវទទួលទោសតាមរយៈពេលនៃការផ្តន្ទាទោស ដែលបានកំណត់ស្របតាមច្បាប់ជាតិ។ ការពិចារណាសម្រាប់ការដោះលែងដោយមានលក្ខខណ្ឌ ឬទម្រង់ផ្សេងទៀតនៃការដោះលែងមុនពេលកំណត់ ត្រូវតែស្របតាមច្បាប់[៥៦] ហើយការដោះលែងបែបនេះ មិនត្រូវបានបដិសេធ ដោយហេតុផលដែលមានលក្ខណៈតាមទំនើងចិត្តនៅក្នុងអត្ថន័យនៃមាត្រា៩ នោះឡើយ។ ប្រសិនបើការដោះលែងបែប

[៥៣] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសប៊ុលហ្គារី ឆ្នាំ២០១១ កថាខ័ណ្ឌទី១០។

[៥៤] បណ្តឹងលេខ៧៥៤/១៩៩៧ រវាង A និងប្រទេសណូវែលហ្សេឡង់ដ៏ កថាខ័ណ្ឌទី៧.២។ សូមមើលផងដែរសេចក្តីពន្យល់ទូទៅលេខ៩ របស់គណៈកម្មាធិការសិទ្ធិកុមារ កថាខ័ណ្ឌទី៥០។

[៥៥] បណ្តឹងលេខ១០៦២/២០០២ រវាង Fijalkowska និងប្រទេសប៉ូឡូញ កថាខ័ណ្ឌទី៨.៣-៨.៤។ បណ្តឹងលេខ៧៥៤/១៩៩៧ រវាង A និងប្រទេសណូវែលហ្សេឡង់ដ៏ កថាខ័ណ្ឌទី៧.៣។ សូមមើលផងដែរសេចក្តីពន្យល់ទូទៅលេខ៣១ កថាខ័ណ្ឌទី១៥។

[៥៦] បណ្តឹងលេខ១៣៨៨/២០០៥ រវាង De Léon Castro និងប្រទេសអេស្ប៉ាញ កថាខ័ណ្ឌទី៩.៣។

នេះត្រូវបានផ្តល់ឲ្យដោយមានលក្ខខណ្ឌ ហើយក្រោយ ការដោះលែងត្រូវបានលុបចោល ដោយសារតែមានការចោទប្រកាន់ថាមានការបំពានលក្ខខណ្ឌ ពេលនោះការលុបចោលនោះក៏ត្រូវធ្វើឡើងស្របតាមច្បាប់ដែរ ហើយមិនត្រូវធ្វើតាមទំនើងចិត្ត និងជាពិសេស មិនត្រូវមិនសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃការបំពាននោះឡើយ។ ការព្យាករណ៍ពីឥរិយាបថអនាគតរបស់អ្នកទោស អាចជាកត្តាពាក់ព័ន្ធមួយនៅក្នុងការសម្រេច ថាតើត្រូវផ្តល់ការដោះលែងមុនពេលកំណត់ឬទេ។[៥៧]

២១. នៅពេលដែលការផ្តន្ទាទោសព្រហ្មទណ្ឌមួយ រួមបញ្ចូលរយៈពេលដាក់ទណ្ឌកម្មបន្ទាប់ពីរយៈពេលមិនមែនទណ្ឌកម្ម មានបំណងការពារសុវត្ថិភាពរបស់បុគ្គលដទៃទៀត[៥៨] បន្ទាប់មក នៅពេលដែលរយៈពេលទណ្ឌកម្មឲ្យជាប់ពន្ធនាគារ ត្រូវបានអនុវត្តចប់ ដើម្បីបញ្ចៀសភាពតាមទំនើងចិត្តនោះ ការឃុំខ្លួនបន្ថែមត្រូវតែធ្វើយុត្តិកម្ម ដោយមានហេតុផលច្បាស់លាស់កើតចេញពីភាពធ្ងន់ធ្ងរនៃបទល្មើសដែលបានប្រព្រឹត្ត និងភាពដូចគ្នានៃការប្រព្រឹត្តិបទល្មើសស្រដៀងគ្នាក្នុងពេលអនាគត។ រដ្ឋគួរប្រើការឃុំខ្លួនបែបនេះសំរាប់តែជាដំណោះស្រាយចុងក្រោយប៉ុណ្ណោះ ហើយការពិនិត្យឡើងវិញតាមពេលកំណត់ជាទៀងទាត់ដោយស្ថាប័នឯករាជ្យ ត្រូវតែធ្វើ

[៥៧]. បណ្តឹងលេខ១៤៩២/២០០៦ រវាង Van der Plaat និងប្រទេសណូវែលហ្សេឡង់ដ៍ កថាខណ្ឌទី៦.៣។

[៥៨]. នៅក្នុងប្រព័ន្ធច្បាប់ផ្សេងៗ ការឃុំខ្លួនបែបនេះ ត្រូវបានដឹងថាជាការឃុំខ្លួនតាមភាសាបារាំង "Rétention sûreté" ឬភាសាអាឡឺម៉ង់ត៍ "Sicherungsverwahrung" ឬជាភាសាអង់គ្លេស "preventive detention"។ សូមមើលបណ្តឹងលេខ១០៩០/២០០២ រវាង Rameka និងប្រទេសណូវែលហ្សេឡង់ដ៍។

ឡើង ដើម្បីសម្រេចថាតើការឃុំខ្លួនបន្តមានហេតុផលសមស្របឬទេ។[៥៩] រដ្ឋភាគីត្រូវប្រុងប្រយ័ត្ន និងផ្តល់ការធានាសមស្របនៅក្នុងការវាយតម្លៃពីគ្រោះថ្នាក់នាពេលអនាគត។[៦០] លក្ខខណ្ឌក្នុងការឃុំខ្លួនបែបនេះ ត្រូវតែខុសគ្នាពីលក្ខខណ្ឌសម្រាប់ទណ្ឌិតដែលបំរើទោសបែបទណ្ឌកម្ម និងត្រូវមានគោលដៅស្តារនីតិសម្បទា និងសមាហរណកម្មរបស់ជនជាប់ឃុំ ទៅក្នុងសង្គមវិញ។[៦១] ប្រសិនបើអ្នកទោសម្នាក់ បានបំរើទោសពេញលេញហើយ មាត្រា៩ និង១៥ ហាមឃាត់ការបង្កើនទោសដោយប្រតិសកម្ម ហើយរដ្ឋភាគីមិនត្រូវគេចចេញពីការហាមឃាត់នេះ ដោយធ្វើការឃុំខ្លួនមួយដែលស្មើគ្នានឹងការដាក់ពន្ធនាគារពីបទព្រហ្មទណ្ឌ ក្រោមស្លាកឃុំខ្លួនរដ្ឋប្បវេណីឡើយ។[៦២]

២២. ប្រយោគទីបីនៃកថាខណ្ឌទី១ ចែងថា គ្មានជនណាម្នាក់ត្រូវបានគេដកហូតសេរីភាពឡើយ លើកលែងតែផ្អែកលើមូលដ្ឋានបែបនេះ និងធ្វើស្របតាមនីតិវិធីដូចដែលបានកំណត់ដោយច្បាប់។ មូលដ្ឋានសារធាតុណាមួយសម្រាប់ការចាប់ខ្លួន ឬឃុំខ្លួន ត្រូវតែចែងដោយច្បាប់ ហើយគួរត្រូវបានកំណត់ដោយមានភាពច្បាស់លាស់គ្រប់គ្រាន់ ដើម្បីជៀសវាងការបកស្រាយ ឬការអនុវត្តតាមទំនើង

---

[៥៩]. ដូចខាងលើ កថាខណ្ឌទី៧.៣។

[៦០]. សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអាលឺម៉ង់ ឆ្នាំ២០១២ កថាខណ្ឌទី១៤។

[៦១]. បណ្តឹងលេខ១៥១២/២០០៦ រវាងDean និងប្រទេសណូវែលហ្សេឡង់ដ៏ កថាខណ្ឌទី៧.៥។

[៦២]. បណ្តឹងលេខ១៦២៩/២០០៧ រវាង Fardon និងប្រទេសអូស្រ្តាលី កថាខណ្ឌទី៧.៤។

ចិត្ត ឬទូលំទូលាយពេក។[៦៣] ការដកហូតសេរីភាពដោយគ្មានការអនុញ្ញាតតាមផ្លូវច្បាប់បែបនេះ គឺមិនត្រឹមត្រូវតាមច្បាប់ទេ។[៦៤] ការឃុំខ្លួនបន្ត ទោះបីជាមានសេចក្តីបង្គាប់ឲ្យប្រតិបត្តិពីតុលាការពីការដោះលែង ឬការលើកលែងទោសដែលមានសុពលភាពក៏ដោយក៏មិនត្រឹមត្រូវតាមច្បាប់ដែរ។[៦៥]

២៣. មាត្រា៩ ចែងថា នីតិវិធីសម្រាប់អនុវត្តការដកហូតសេរីភាពដោយមានការអនុញ្ញាតតាមច្បាប់ គួរត្រូវបានកំណត់ដោយច្បាប់ ហើយរដ្ឋភាគីគួរធានាការអនុវត្តតាមនីតិវិធីដែលមានចែងតាមផ្លូវច្បាប់។ មាត្រា៩ តម្រូវបន្ថែមឲ្យមានការអនុវត្តតាមវិធានក្នុងស្រុក ដែលកំណត់ពីនីតិវិធីសម្រាប់ការចាប់ខ្លួន ដោយកំណត់អត្តសញ្ញាណមន្ត្រីដែលមានអំណាចចាប់ខ្លួន[៦៦] ឬដោយបញ្ជាក់ពីពេលវេលាដែលត្រូវការដីកា។[៦៧] មាត្រានេះក៏តម្រូវឲ្យអនុវត្តតាមច្បាប់ជាតិដែលកំណត់ឲ្យបន្តការឃុំខ្លួន ប្រសិនបើអនុញ្ញាតិ ត្រូវតែទទួល

---

៦៣. សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសហ្វីលីពីនឆ្នាំ២០០៣ កថាខណ្ឌទី១៤ (ច្បាប់គ្រប់គ្រងជនអនាថាទូលំទូលាយពេក) សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់កោះម៉ូរីស ឆ្នាំ២០០៥ កថាខណ្ឌទី១២ (ច្បាប់ប្រឆាំងភេរវកម្ម) សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់សហព័ន្ធរុស្ស៊ី ឆ្នាំ២០០៩ កថាខណ្ឌទី២៥ (សកម្មភាពរបស់ក្រុមជ្រុលនិយម) សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសហុងឌុយរ៉ាស់ ឆ្នាំ២០០៦ កថាខណ្ឌទី១៣ (ការបង្កើតសមាគមដែលមិនត្រឹមត្រូវតាមផ្លូវច្បាប់)។

៦៤. បណ្តឹងលេខ៧០២/១៩៩៦ រវាង McLawrence និងប្រទេសចាម៉ៃកា កថាខណ្ឌទី៥.៥ (គោលការណ៍នីត្យានុកូល ត្រូវបានបំពាន ប្រសិនបើបុគ្គលណាមួយត្រូវបានចាប់ខ្លួន ឬឃុំខ្លួន ដោយឈរលើមូលដ្ឋានដែលមិនមានចែងច្បាស់លាស់នៅក្នុងច្បាប់ជាតិ)។

៦៥. បណ្តឹងលេខ៨៥៦/១៩៩៩ រវាង Chambala និងប្រទេសហ្សំប៊ី កថាខណ្ឌទី៧.៣។ បណ្តឹងលេខ១៣៨/១៩៨១ រវាង Mpandanjila et al និងប្រទេសហ្សាអៀ កថាខណ្ឌទី១០។

៦៦. បណ្តឹងលេខ៤៦១/២០០៦ et al រវាង Maksudov et al និងប្រទេសកៀកជីស្ថាន កថាខណ្ឌទី១២.២។

៦៧. បណ្តឹងលេខ១១១០/២០០២ រវាង Rolando និងប្រទេសហ្វីលីពីន កថាខណ្ឌទី៥.៥។

បានពីចៅក្រម ឬមន្ត្រីផ្សេងទៀត[៦៨] ដែលអាចឃុំខ្លួនបុគ្គលនោះ[៦៩] នៅពេលដែលបុគ្គលជាប់ឃុំនោះ ត្រូវបាននាំខ្លួនទៅតុលាការ[៧០] និងកំហិតតាមផ្លូវច្បាប់ទៅលើរយៈពេលនៃការឃុំខ្លួន។[៧១] មាត្រានេះក៏តម្រូវផងដែរឲ្យគោរពតាមច្បាប់ជាតិ ដែលផ្តល់កិច្ចការពារសំខាន់ៗដល់បុគ្គលជាប់ឃុំ ដូចជា ការធ្វើកំណត់ត្រាអំពីការចាប់ខ្លួន[៧២] និងការអនុញ្ញាតឲ្យមានទីប្រឹក្សាច្បាប់។[៧៣] ការរំលោភលើវិធាននីតិវិធីក្នុងស្រុក ដែលមិនទាក់ទងនឹងបញ្ហាបែបនេះ អាចមិនសុទ្ធតែចោទជាបញ្ហានោះទេ នៅក្រោមមាត្រា៩។[៧៤]

---

៦៨. បណ្តឹងលេខ៧៧០/១៩៩៧ រវាង Gridin និងសហព័ន្ធរុស្ស៊ី កថាខណ្ឌទី៨.១។

៦៩. បណ្តឹងលេខ១៤៤៩/២០០៦ រវាង Umarov និងប្រទេសអ៊ុយបេគីស្ថាន កថាខណ្ឌទី៨.៤។

៧០. បណ្តឹងលេខ៩៨១/២០០១ រវាង Gómez Casafranca និងប្រទេសប៉េរូ កថាខណ្ឌទី៧.២។

៧១. បណ្តឹងលេខ២០២៤/២០១១ រវាង Israil និងប្រទេសកាហ្សាក់ស្ថាន កថាខណ្ឌទី៩.២។

៧២. បណ្តឹងលេខ១២០៨/២០០៣ រវាង Kurbonov និងប្រទេសតាជីគីស្ថាន កថាខណ្ឌទី៦.៥។

៧៣. បណ្តឹងលេខ១៤១២/២០០៥ រវាង Butovenko និងប្រទេសអ៊ុយក្រែន កថាខណ្ឌទី៧.៦។

៧៤. សូមមើលបណ្តឹងលេខ១៤២៥/២០០៥ រវាង Marz និងសហព័ន្ធរុស្ស៊ី កថាខណ្ឌទី៥.៣ ជាឧទាហរណ៍។

# III. ការជូនដំណឹងអំពីមូលហេតុនៃការចាប់ខ្លួន និងការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ

២៤. កថាខណ្ឌទី២ នៃមាត្រា៩ ដាក់លក្ខខណ្ឌតម្រូវពីរសម្រាប់ជាអត្ថប្រយោជន៍ដល់ជនដែលត្រូវបានគេដកហូតសេរីភាព។ ទីមួយ ពួកគេត្រូវបានជូនដំណឹងអំពីមូលហេតុនៃការចាប់ខ្លួន នៅពេលមានការចាប់ខ្លួន។ ទីពីរ ពួកគេត្រូវបានដឹងភ្លាមៗអំពីការចោទប្រកាន់ណាមួយប្រឆាំងនឹងពួកគេ។ លក្ខខណ្ឌតម្រូវទីមួយ អនុវត្តជាទូទៅចំពោះហេតុផលនៃការដកហូតសេរីភាព។ ដោយសារតែ "ការចាប់ខ្លួន" មានន័យថាជាការចាប់ផ្ដើមនៃការដកហូតសេរីភាព លក្ខខណ្ឌតម្រូវនេះត្រូវអនុវត្ត ដោយមិនគិតពីភាពត្រឹមត្រូវតាមទម្រង់ ឬមិនតាមទម្រង់នៃការចាប់ខ្លួននោះទេ និងដោយមិនគិតពីមូលហេតុស្របច្បាប់ ឬមិនត្រឹមត្រូវនៃការចាប់ខ្លួននោះដែរ។[៧៥] ទីពីរ លក្ខខណ្ឌតម្រូវបន្ថែមអនុវត្តចំពោះតែព័ត៌មានអំពីការចោទប្រកាន់បទព្រហ្មទណ្ឌ។[៧៦] ប្រសិនបើមនុស្សម្នាក់ដែលត្រូវបានឃុំខ្លួនរួចទៅហើយពីបទចោទព្រហ្មទណ្ឌមួយ ត្រូវបានបញ្ជាឲ្យឃុំ

[៧៥] បណ្ដឹងលេខ១៤៦០/២០០៦ រវាង Yklymova និងប្រទេសទៀកមេនីស្ថាន កថាខណ្ឌទី៧.២ (ការចាប់ខ្លួនឃុំនៅផ្ទះតាមព្រឹត្តិហេតុ)។ បណ្ដឹងលេខ៤១៤/១៩៩០ រវាង Mika Miha និងប្រទេសអេក្វាទ័រហ្គីណេ កថាខណ្ឌទី៦.៥ (បទបញ្ជាប្រធានាធិបតី)។

[៧៦] សូមមើល ជាឧទាហរណ៍ ករណីពាក់ព័ន្ធនឹង Ahmadou Dadio Diallo (រវាងសាធារណៈរដ្ឋហ្គីណេ និងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ។ របាយការណ៍ ICJ ឆ្នាំ២០១០ ទំព័រទី៦៣៩ កថាខណ្ឌទី៧៧ (សម្រង់សេចក្ដីពន្យល់ទូទៅលេខ៨ របស់គណៈកម្មាធិការសិទ្ធិមនុស្ស។

ខ្លួនដើម្បីប្រឈមមុខនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ដែលមិនពាក់ព័ន្ធមួយ គេត្រូវតែផ្តល់ដំណឹងភ្លាមៗ អំពីការចោទប្រកាន់ដែលមិនពាក់ព័ន្ធនោះ។[៧៧]

២៥. គោលបំណងធំមួយដែលតម្រូវថា ត្រូវប្រាប់ពីមូលហេតុនៃការចាប់ខ្លួនដល់ជនដែលត្រូវបានចាប់ខ្លួនទាំងអស់នោះ គឺដើម្បីជួយពួកគេស្វែងរកការដោះលែង ប្រសិនបើពួកគេជឿថា មូលហេតុដែលផ្តល់ឲ្យ មិនមានសុពលភាពឬគ្មានមូលដ្ឋាន។[៧៨] មូលហេតុត្រូវតែបញ្ចូល មិនត្រឹមតែមូលដ្ឋានច្បាប់ទូទៅនៃការចាប់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានសេចក្តីជាក់លាក់ពិតប្រាកដគ្រប់គ្រាន់ដើម្បីបង្ហាញពីសារធាតុនៃបណ្តឹង ដូចជាអំពើខុសឆ្គង និងអត្តសញ្ញាណរបស់ជនដែលបានអះអាងថារងគ្រោះ។[៧៩] "មូលហេតុ" គឺទាក់ទងទៅនឹងមូលដ្ឋានផ្លូវការសម្រាប់ការចាប់ខ្លួន មិនមែនកត្តាជំរុញអត្តនោម័តរបស់មន្ត្រីទទួលបន្ទុកខាងការចាប់ខ្លួននោះទេ។[៨០]

២៦. ការជូនដំណឹងដោយផ្ទាល់មាត់អំពីមូលហេតុសម្រាប់ការចាប់ខ្លួនគឺស្របតាមលក្ខខណ្ឌតម្រូវ។ មូលហេតុត្រូវតែផ្តល់ជាភាសាដែលជនត្រូវបានចាប់ខ្លួននោះ យល់បាន។[៨១]

---

[៧៧]. បណ្តឹងលេខ៦៣៥/១៩៩៨ រវាង Morrison និងប្រទេសចាម៉ៃកា កថាខណ្ឌទី២២.២-២២.៣។ បណ្តឹងលេខ១៣៩៧/២០០៥ រវាង Engo និងប្រទេសកាមេរូន កថាខណ្ឌទី៧.៣។

[៧៨]. បណ្តឹងលេខ២៤៨/១៩៨៧ រវាង Cambell និងប្រទេសចាម៉ៃកា កថាខណ្ឌទី៦.៣។

[៧៩]. បណ្តឹងលេខ១១៧៧/២០០៣ រវាង Wenga & Shandwe និងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ កថាខណ្ឌទី៦.២។

[៨០]. បណ្តឹងលេខ១៨១២/២០០៨ រវាង Levinov និងប្រទេសបេឡារុស កថាខណ្ឌទី៧.៥។

[៨១]. បណ្តឹងលេខ៨៦៨/១៩៩៩ រវាង Wilson និងប្រទេសហ្វីលីពីន កថាខណ្ឌទី៣.៣ និង៧.៥។

២៧. ព័ត៌មាននេះ ត្រូវតែផ្តល់ភ្លាមៗបន្ទាប់ពីការចាប់ខ្លួន។ ប៉ុន្តែនៅក្នុងកាលៈទេសៈពិសេស ការផ្តល់ព័ត៌មានភ្លាមៗបែបនេះអាចធ្វើមិនបានទេ។ ឧទាហរណ៍ គេអាចត្រូវការពន្យារពេល មុនពេលអ្នកបកប្រែភាសាមកដល់ ប៉ុន្តែការពន្យារពេលបែបនេះត្រូវតែមានលក្ខណៈចាំបាច់បំផុតតែប៉ុណ្ណោះ។[៨២]

២៨. សម្រាប់ជនងាយរងគ្រោះប្រភេទខ្លះ ការផ្តល់ព័ត៌មានដោយផ្ទាល់ចាំបាច់ត្រូវតែធ្វើដល់ជនដែលត្រូវបានចាប់ខ្លួន ប៉ុន្តែនៅមិនទាន់គ្រាប់គ្រាន់នៅឡើយទេ។ នៅពេលកុមារត្រូវបានចាប់ខ្លួន គេគួរតែជូនដំណឹងដោយផ្ទាល់អំពីការចាប់ខ្លួន និងមូលហេតុនៃការចាប់ខ្លួន ទៅឪពុកម្តាយ អាណាព្យាបាល ឬតំណាងស្របច្បាប់របស់ពួកគេ។[៨៣] សម្រាប់បុគ្គលខ្លះដែលពិការផ្លូវចិត្ត ការជូនដំណឹងអំពីការចាប់ខ្លួន និងមូលហេតុ គួរផ្តល់ដោយផ្ទាល់ទៅជនដែលត្រូវបានចាត់តាំង ឬសមាជិកគ្រួសារទាមការសមស្រប។ គេអាចត្រូវការពេលវេលាបន្ថែមទៀត ដើម្បីកំណត់ និងទាក់ទងតតិយជនដែលពាក់ព័ន្ធ ប៉ុន្តែការជូនដំណឹងគួរផ្តល់ឲ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន។

២៩. លក្ខខណ្ឌតម្រូវទីពីរនៃកថាខណ្ឌទី២ ទាក់ទងនឹងការជូនដំណឹងអំពីបទចោទប្រកាន់ព្រហ្មទណ្ឌ។ ជនដែលត្រូវបានចាប់ខ្លួន

---

[៨២] បណ្តឹងលេខ៥២៦/១៩៩៣ រវាង Hill & Hill និងប្រទេសអេស្ប៉ាញ កថាខណ្ឌទី១២.២។

[៨៣] បណ្តឹងលេខ១៤០២/២០០៥ រវាង Krasnova និងប្រទេសកៀកជីស្ថាន កថាខណ្ឌទី៨.៥។ សេចក្តីពន្យល់ទូទៅលេខ៣២ កថាខណ្ឌទី៤២។ សូមមើលផងដែរសេចក្តីពន្យល់ទូទៅលេខ១០ កថាខណ្ឌទី៤៨ របស់គណៈកម្មាធិការសិទ្ធិកុមារ។

សម្រាប់គោលបំណងនៃការស៊ើបអង្កេតបទល្មើស ដែលពួកគេបានប្រព្រឹត្ត ឬសម្រាប់គោលបំណងឃុំខ្លួនពួកគេដើម្បីជំនុំជម្រះក្តីព្រហ្មទណ្ឌ ត្រូវតែជូនដំណឹងភ្លាមៗអំពីបទល្មើសដែលពួកគេជាប់សង្ស័យ ឬត្រូវចោទប្រកាន់។ សិទ្ធិនេះអនុវត្តទាក់ទងទៅនឹងការផ្តន្ទាទោសព្រហ្មទណ្ឌធម្មតា និងទាក់ទងផងដែរទៅនឹងការផ្តន្ទាទោសដោយតុលាការយោធា ឬរបបពិសេសផ្សេងទៀតសំដៅដល់ការផ្តន្ទាទោសព្រហ្មទណ្ឌ។[៩៤]

៣០. កថាខណ្ឌទី២ ចែងថា ជនដែលត្រូវបានចាប់ខ្លួនត្រូវតែបានទទួលព័ត៌មាន "ភ្លាមៗ" អំពីបទចោទប្រកាន់ណាមួយ ដែលមិនចាំបាច់តែ "នៅពេលចាប់ខ្លួននោះទេ"។ ប្រសិនបើបទចោទប្រកាន់ត្រូវបានពិចារណារួចទៅហើយ មន្ត្រីខាងចាប់ខ្លួនអាចជូនដំណឹងដល់ជននោះអំពីមូលហេតុចោទ និងបទចោទប្រកាន់ ឬអាជ្ញាធរអាចពន្យល់អំពីមូលដ្ឋានច្បាប់នៃការឃុំខ្លួន ក្នុងរយៈពេលប៉ុន្មានម៉ោងក្រោយមកទៀត។ មូលហេតុត្រូវធ្វើជាភាសាមួយដែលជនដែលត្រូវបានចាប់ខ្លួននោះ អាចយល់បាន។[៩៥] ការជូនដំណឹងអំពីបទចោទប្រកាន់ក្រោមកថាខណ្ឌទី២ មានគោលបំណងសម្រួលដល់

[៩៤] បណ្តឹងលេខ១៧៨២/២០០៨ រវាង Aboufaied និងប្រទេសលីប៊ី កថាខណ្ឌទី៧.៦។ លក្ខខណ្ឌតម្រូវពីការត្រូវជូនដំណឹងអំពីបទចោទប្រកាន់ណាមួយ អនុវត្តចំពោះការឃុំខ្លួនដោយសារការចោទប្រកាន់ពីបទល្មើសយោធាដែលអាចមាន ដោយមិនគិតថាតើសវនាការកាត់ទោសជនជាប់ចោទដោយតុលាការយោធានឹងត្រូវបានហាមឃាត់ដោយមាត្រា១៤ នៃកតិកាសញ្ញានេះ។ បណ្តឹងលេខ១៦៤៩/២០០៧ រវាង El Abani និងប្រទេសអាល់ហ្សេរី កថាខណ្ឌទី៧.៦ និង៧.៨។

[៩៥] បណ្តឹងលេខ៤៩៣/១៩៩២ រវាង Griffin និងប្រទេសអេស្ប៉ាញ កថាខណ្ឌទី៩.២។

ការកំណត់ពីភាពត្រឹមត្រូវនៃការឃុំខ្លួនបណ្តោះអាសន្ន ដូច្នេះ កថាខណ្ឌទី២ មិនតម្រូវឲ្យមានសេចក្តីពិស្តារថែមទៀតអំពីបទចោទប្រកាន់ទាំងនេះនោះទេ ដោយសារតែតម្រូវការនៃព័ត៌មានលំអិតទាំងនេះគង់តែត្រូវមាននៅពេលក្រោយមកទៀត ដើម្បីរៀបចំសម្រាប់សវនាការ[៨៦] ប្រសិនបើអាជ្ញាធរបានប្រាប់ដល់បុគ្គលណាម្នាក់អំពីបទចោទប្រកាន់ដែលកំពុងត្រូវបានស៊ើបអង្កេត មុនធ្វើការចាប់ខ្លួន ពេលនោះកថាខណ្ឌទី២ មិនតម្រូវឲ្យធ្វើការបញ្ជាក់ឡើងវិញភ្លាមៗអំពីបទចោទប្រកាន់ជាផ្លូវការនោះទេ ដរាបណាអាជ្ញាធរផ្តល់ព័ត៌មានអំពីការចាប់ខ្លួននោះ។[៨៧] ការពិចារណាដូចគ្នានៅក្នុងកថាខណ្ឌទី២៨ អនុវត្តចំពោះការផ្តល់ព័ត៌មានភ្លាមៗទាក់ទងទៅនឹងបទចោទប្រកាន់ព្រហ្មទណ្ឌណាមួយ នៅពេលអនីតិជន ឬជនងាយរងគ្រោះដទៃទៀតត្រូវបានចាប់ខ្លួន។

[៨៦] សេចក្តីពន្យល់ទូទៅលេខ៣២ កថាខណ្ឌទី៣២។ បណ្តឹងលេខ៧០២/១៩៩៦ រវាង McLawrence និងប្រទេសចាម៉ៃកា កថាខណ្ឌទី៥.៩។

[៨៧] បណ្តឹងលេខ៧១២/១៩៩៦ រវាង Smirnova និងសហព័ន្ធរុស្ស៊ី កថាខណ្ឌទី១០.៣។

## IV. ការគ្រប់គ្រងការឃុំខ្លួនដោយតុលាការទាក់ទងនឹងបទចោទប្រកាន់ព្រហ្មទណ្ឌ

៣១. ប្រយោគទីមួយនៃកថាខណ្ឌទី៣ អនុវត្តចំពោះជន "ដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ" រីឯប្រយោគទីពីរទាក់ទងទៅនឹងជន "ដែលរង់ចាំការជំនុំជម្រះក្តី" ពីបទព្រហ្មទណ្ឌ។ កថាខណ្ឌទី៣ អនុវត្តទាក់ទងទៅនឹងការផ្តន្ទាទោសព្រហ្មទណ្ឌធម្មតា ការផ្តន្ទាទោសយោធា និងបទប្បញ្ញត្តិពិសេសផ្សេងទៀតដែលសំដៅលើការដាក់ទោសព្រហ្មទណ្ឌ។[៨៨]

៣២. កថាខណ្ឌទី៣ តម្រូវឲ្យ ទីមួយ ត្រូវនាំខ្លួនភ្លាមៗជនដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ មកកាន់តុលាការ ឬមន្ត្រីផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់ឲ្យប្រើអំណាចតុលាការ។ លក្ខខណ្ឌតម្រូវនេះអនុវត្តចំពោះគ្រប់ករណី ដោយគ្មានការលើកលែង និងមិនអាស្រ័យលើការជ្រើសរើស ឬសមត្ថភាពរបស់ជនជាប់ឃុំបញ្ជាក់អះអាងឡើយ។[៨៩] លក្ខខណ្ឌតម្រូវនេះអនុវត្ត សូម្បីតែមុន

[៨៨] បណ្តឹងលេខ១៧៨២/២០០៨ រវាង Aboufaied និងប្រទេសលីប៊ី កថាខណ្ឌទី៧.៦។ កថាខណ្ឌទី៣ អនុវត្តចំពោះការឃុំខ្លួន ដោយសារការចោទប្រកាន់ពីបទល្មើសយោធាដែលអាចមាន ដោយមិនគិតថាតើសវនាការកាត់ទោសជនជាប់ចោទដោយតុលាការយោធានឹងត្រូវបានហាមឃាត់ដោយមាត្រា១៤ នៃកតិកាសញ្ញានេះ។ បណ្តឹងលេខ១៨១៣/២០០៨ រវាង Akwanga និងប្រទេសអាល់បានី កថាខណ្ឌទី៧.៤-៧.៥។ នៅក្នុងជំលោះប្រដាប់អាវុធអន្តរជាតិ វិធានពិស្តារនៃច្បាប់មនុស្សធម៌អន្តរជាតិ ស្តីពីការចោទប្រកាន់បទល្មើសយោធា ក៏ពាក់ព័ន្ធនឹងការបកស្រាយមាត្រា៩ កថាខណ្ឌទី៣ ដែលត្រូវបន្តអនុវត្ត។ សូមមើលផងដែរ កថាខណ្ឌទី៦៤ ខាងក្រោម នៃសេចក្តីពន្យល់ទូទៅនេះ។

[៨៩] បណ្តឹងលេខ១៧៨៧/២០០៨ រវាង Kovsh និងប្រទេសបេឡារូស កថាខណ្ឌទី៧.៣-៧.៥។

ពេលការចោទប្រកាន់ជាផ្លូវការត្រូវបានបញ្ជាក់ ដរាបណាជននោះ ត្រូវបានចាប់ខ្លួន ឬឃុំខ្លួនដោយសង្ស័យថាបានប្រព្រឹត្តសកម្មភាព ព្រហ្មទណ្ឌ។[៩០] សិទ្ធិនេះ មានបំណងយកការឃុំខ្លួនជនណាម្នាក់ មកស៊ើបអង្កេត ឬផ្តន្ទាទោសព្រហ្មទណ្ឌ ក្រោមការត្រួតពិនិត្យ របស់តុលាការ។[៩១] ប្រសិនបើជនម្នាក់ត្រូវបានជាប់ឃុំរួចទៅហើយ ពីបទព្រហ្មទណ្ឌមួយ ហើយត្រូវបានបញ្ជាឲ្យឃុំខ្លួនផងដែរពីបទ ចោទប្រកាន់ព្រហ្មទណ្ឌមួយដែលមិនពាក់ព័ន្ធ ជននោះត្រូវបាននាំ ខ្លួនភ្លាមៗមកកាន់តុលាការ ដើម្បីត្រួតពិនិត្យពីការឃុំខ្លួនជាលើក ទីពីរនេះ។[៩២] វាស្ថិតនៅលើការប្រើប្រាស់ដោយត្រឹមត្រូវនូវអំណាច តុលាការ ដែលត្រូវអនុវត្តដោយអាជ្ញាធរមួយដែលឯករាជ្យ មាន គោលដៅជាក់លាក់ និងមិនលំអៀងទាក់ទងទៅនឹងបញ្ហាដែល កំពុងត្រូវបានធ្វើការដោះស្រាយ។[៩៣] ដូចគ្នានេះដែរ អយ្យការមិន អាចត្រូវបានចាត់ទុកជាមន្ត្រីម្នាក់ ដែលប្រើអំណាចតុលាការក្រោម កថាខណ្ឌទី៣ នោះឡើយ។[៩៤]

---

[៩០] បណ្តឹងលេខ១១២៨/២០០២ រវាង Marques de Morais និងប្រទេសអង់ហ្គោឡា កថាខណ្ឌទី៦.៣-៦.៤។ បណ្តឹងលេខ១០៩៦/២០០២ រវាង Kurbanova និងប្រទេសតាជីគីស្ថាន កថាខណ្ឌទី៧.២។

[៩១] បណ្តឹងលេខ១៩១៤/២០០៩ រវាង Musaev និងប្រទេសអ៊ុយបេគីស្ថាន កថាខណ្ឌទី៩.៣។

[៩២] បណ្តឹងលេខ៦៣៥/១៩៩៨ រវាង Morrison និងប្រទេសចាម៉ៃកា កថាខណ្ឌទី២២.២-២២.៣។ បណ្តឹងលេខ ៧៦២/១៩៩៧ រវាង Jensen និងប្រទេសអូស្ត្រាលី កថាខណ្ឌទី៦.៣។

[៩៣] បណ្តឹងលេខ៥២១/១៩៩២ រវាង Kulomin និងប្រទេសហុងគ្រី កថាខណ្ឌទី១១.៣។

[៩៤] ដូចខាងលើ។ បណ្តឹងលេខ១៥៤៧/២០០៧ រវាង Torobekov និងប្រទេសកៀកជីស្ថាន កថាខណ្ឌទី៦.២។ បណ្តឹងលេខ១២៧៨/២០០៤ រវាង Reshetnikov និងសហព័ន្ធរុស្ស៊ី កថាខណ្ឌទី៨.២។ សូមមើលសេចក្តីសង្កេត សន្និដ្ឋានសំរាប់ប្រទេសតាជីគីស្ថាន ឆ្នាំ២០០៥ កថាខណ្ឌទី១២។

៣៣. ខណៈដែលអត្ថន័យពិតប្រាកដនៃ"ភ្លាមៗ"អាចប្រែប្រួល អាស្រ័យលើកាលៈទេសៈ[៩៥] ការពន្យារពេលមិនគួរលើសពីពីរបីថ្ងៃចាប់ពីពេលចាប់ខ្លួនឡើយ។[៩៦] គណៈកម្មាធិការយល់ឃើញថារយៈពេល ៤៨ម៉ោង ជាធម្មតាគឺគ្រប់គ្រាន់ដើម្បីដឹកជញ្ជូនជននោះ និងរៀបចំសវនាការតុលាការ[៩៧] រាល់ការពន្យារណាមួយលើសពី៤៨ម៉ោង ត្រូវតែមានលក្ខណៈពិសេសដាច់ខាត និងត្រូវមានហេតុផលសមស្របតាមកលៈទេសៈនោះ។[៩៨] ការឃុំខ្លួនយូរជាងនេះដោយមន្ត្រីអនុវត្តច្បាប់ដោយគ្មានការត្រួតពិនិត្យពីតុលាការ បង្កើនហានិភ័យនៃការប្រព្រឹត្តិមិនគប្បី ដែលមិនគួរកើតឡើង។[៩៩] ច្បាប់នៅក្នុងរដ្ឋភាគីភាគច្រើន កំណត់ពីការកំរិតពេលវេលាជាក់លាក់ ជួនកាលខ្លីជាង៤៨ម៉ោងផង ហើយមិនគួរលើសពីរយៈពេលនេះឡើយ។ ស្តង់ដារនៃភាពបន្ទាន់ដ៏តឹងរឹងពិសេសមួយ ដូចជារយៈពេល២៤ ម៉ោង ក៏ត្រូវអនុវត្តនៅក្នុងករណីអនីតិជនដែរ។[១០០]

---

[៩៥]. បណ្តឹងលេខ៧០២/១៩៩៦ រវាង McLawrence និងប្រទេសចាម៉ៃកា កថាខណ្ឌទី៥.៦។ បណ្តឹងលេខ ២១២០/២០១១ រវាង Kovalev និងប្រទេសបេលារុស កថាខណ្ឌទី១១.៣។

[៩៦]. បណ្តឹងលេខ១១២៨/២០០២ រវាង Marques de Morais និងប្រទេសអង់ហ្គោឡា កថាខណ្ឌទី៦.៣។ បណ្តឹងលេខ២៧៧/១៩៨៨ រវាង Terán Jijón និងប្រទេសអេក្វាទ័រ (៥ថ្ងៃ មិនមានន័យថាភ្លាមៗទេ)។ បណ្តឹងលេខ៦២៥/១៩៩៥ រវាង Freemantle និងប្រទេសចាម៉ៃកា កថាខណ្ឌទី៧.៤ (៤ថ្ងៃ មិនមានន័យថាភ្លាមៗទេ)។

[៩៧]. បណ្តឹងលេខ១៧៨៧/២០០៨ រវាង Kovsh និងប្រទេសបេលារុស កថាខណ្ឌទី៧.៣-៧.៥។

[៩៨]. ដូចខាងលើ។ សូមមើលបណ្តឹងលេខ៣៣៦/១៩៨៨ រវាង Fillastre និងប្រទេសបូលីវី កថាខណ្ឌទី៦.៤ (ដោយសារកង្វះថវិកា មិនអាចធ្វើយុត្តិកម្មពន្យាពេល១០ថ្ងៃបានទេ)។

[៩៩]. សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសហុងគ្រី ឆ្នាំ២០០២ កថាខណ្ឌទី៨។

[១០០]. សូមមើលសេចក្តីពន្យល់ទូទៅលេខ១០ កថាខណ្ឌទី៨៣ របស់គណៈកម្មាធិការសិទ្ធិកុមារ។

៣៤. ជននោះត្រូវបាននាំមកបង្ហាញខ្លួននៅចំពោះមុខចៅក្រម ឬមន្ត្រីផ្សេងទៀតដែលត្រូវបានអនុញ្ញាតដោយច្បាប់ ដើម្បីប្រើប្រាស់អំណាចតុលាការ។[១០១] វត្តមានរបស់ជនជាប់ឃុំនៅសវនាការផ្តល់ឱកាសឲ្យមានការសាកសួរអំពីការប្រព្រឹត្តិនានា ដែលជននោះបានទទួលនៅកន្លែងឃុំខ្លួន[១០២] និងជួយសម្រួលដល់ការផ្ទេរភ្លាមៗទៅកាន់មណ្ឌលឃុំខ្លួនឡើងវិញ ប្រសិនបើមានបញ្ជាឲ្យឃុំខ្លួនបន្ត។ ដូច្នេះ នេះគឺជាកិច្ចការពារមួយដល់សិទ្ធិទទួលបានសន្តិសុខរបស់មនុស្ស និងការហាមឃាត់មិនឲ្យធ្វើទារុណកម្ម និងការប្រព្រឹត្តិឃោរឃៅ អមនុស្សធម៌ ឬបន្ទាប បន្ថោក។ នៅក្នុងសវនាការដែលធ្វើឡើងក្នុងពេលបន្ទាប់ ក៏ដូចជានៅក្នុងសវនាការក្នុងពេលខាងមុខ ដែលចៅក្រមធ្វើការវាយតម្លៃពីនីត្យានុកូលភាព ឬភាពចាំបាច់នៃការឃុំខ្លួន ជននោះមានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ ដែលតាមគោលការណ៍ គឺជាមេធាវីតាមការជ្រើសរើសរបស់ខ្លួន។[១០៣]

---

[១០១] បណ្តឹងលេខ២៨៩/១៩៨៨ រវាង Wolf និងប្រទេសប៉ាណាម៉ា កថាខណ្ឌទី៦.២។ បណ្តឹងលេខ ៦១៣/១៩៩៥ រវាង Leehong និងប្រទេសចាម៉ៃកា កថាខណ្ឌទី៩.៥។ ចំពោះឃ្លា " មន្ត្រីដទៃទៀតដែលអនុញ្ញាតិដោយច្បាប់ ដើម្បីអនុវត្តអំណាចតុលាការ" មើលកថាខ័ណ្ឌទី៣២ ខាងលើនៃសេចក្តីពន្យល់ទូទៅនេះ។

[១០២] សូមមើលកម្រងគោលការណ៍សំរាប់ការការពារជនគ្រប់រូបពីការឃុំខ្លួន ឬការដាក់ពន្ធនាគារតាមគ្រប់ទម្រង់ គោលការណ៍៣៧ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ៤៣/១៧៣។

[១០៣] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសកេនយ៉ា ឆ្នាំ២០១២ កថាខណ្ឌទី១៩។ សូមមើលផងដែរ មាត្រា១៤ កថាខណ្ឌ៣(ឃ)។ កម្រងគោលការណ៍ (សំគាល់ លេខយោង១០២ខាងលើ) គោលការណ៍១១។

៣៥. ការឃុំខ្លួនដាច់ដោយឡែកពីអ្នកដទៃ ដែលរារាំងមិនឲ្យមានការបង្ហាញខ្លួនភ្លាមៗនៅចំពោះចៅក្រម ជាធម្មតា បំពានកថាខណ្ឌទី៣។[១០៤] អាស្រ័យលើរយៈពេលរបស់វា និងអង្គហេតុដទៃទៀត ការឃុំខ្លួនដាច់ដោយឡែកពីអ្នកដទៃ ក៏អាចរំលោភសិទ្ធិផ្សេងទៀត ក្រោមកតិកាសញ្ញានេះដែរ រួមទាំងមាត្រា៦ ៧ ១០ និងមាត្រា១៤។[១០៥] រដ្ឋភាគីគួរអនុញ្ញាត និងសម្រួលឲ្យមានការទទួលបានជំនួយផ្នែកច្បាប់ដល់ជនជាប់ឃុំ នៅក្នុងរឿងក្តីព្រហ្មទណ្ឌ តាំងពីពេលចាប់ផ្តើមឃុំខ្លួនម្ល៉េះ។[១០៦]

៣៦. នៅពេលជននោះត្រូវបាននាំខ្លួនមកចំពោះមុខចៅក្រម ចៅក្រមត្រូវតែសម្រេចថាតើជននោះគួរត្រូវបានដោះលែង ឬបញ្ជូនត្រឡប់ទៅឃុំខ្លួនវិញ ដើម្បីធ្វើការស៊ើបអង្កេតបន្ថែម ឬត្រូវរង់ចាំជំនុំជម្រះក្តី។ ប្រសិនបើគ្មានមូលដ្ឋានស្របច្បាប់សម្រាប់បន្តការឃុំខ្លួនទេ ចៅក្រមត្រូវបញ្ជាឲ្យដោះលែង។[១០៧] ប្រសិនបើត្រូវធ្វើការស៊ើបអង្កេតបន្ថែម ឬជំនុំជម្រះក្តី ចៅក្រមត្រូវសម្រេចថាតើជននោះ គួរត្រូវបានដោះលែង (ដោយមាន ឬគ្មានលក្ខខណ្ឌ) ខណៈពេលរង់ចាំដំណើរការក្តីបន្តទៀត ពីព្រោះការឃុំខ្លួនគឺជារឿងមិនចាំបាច់។ នេះគឺជាបញ្ហា

[១០៤]. បណ្តឹងលេខ១២៩៧/២០០៤ រវាង Medjnoune និងប្រទេសអាល់ហ្សេរី កថាខ័ណ្ឌទី៨.៧។

[១០៥]. បណ្តឹងលេខ១៧៨១/២០០៨ រវាង Berzig និងប្រទេសអាល់ហ្សេរី កថាខ័ណ្ឌទី៨.៤-៨.៥-៨.៨។ បណ្តឹងលេខ១៧៦/១៩៨៤ រវាង Lafuente Peñarrieta និងប្រទេសបូលីវី កថាខ័ណ្ឌទី១៦។

[១០៦]. សូមមើលសេចក្តីពន្យល់ទូទៅលេខ៣២ កថាខណ្ឌទី៣២ ៣៤ និង៣៨។ សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសតូហ្គូ ឆ្នាំ២០១១ កថាខណ្ឌទី១៩។ សូមមើលកថាខណ្ឌទី៥៨ ខាងក្រោមនៃសេចក្តីពន្យល់នេះ។

[១០៧]. សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសតាជីគីស្ថាន ឆ្នាំ២០០៥ កថាខណ្ឌ១២។ បណ្តឹងលេខ៦៤៧/១៩៩៥ រវាង Pennant និងប្រទេសចាម៉ៃកា កថាខណ្ឌទី៨.២។

មួយដែលមានចែងពេញលេញបន្ថែមទៀត នៅក្នុងប្រយោគទីពីរនៃកថាខណ្ឌទី៣។ គណៈកម្មាធិការយល់ឃើញថា ការឃុំខ្លួនឡើងវិញ មិនគួរពាក់ព័ន្ធនឹងការវិលត្រឡប់ទៅកាន់កន្លែងឃុំខ្លួនរបស់នគរបាលនោះឡើយ ប៉ុន្តែគួរបញ្ជូនទៅកាន់កន្លែងដាច់ដោយឡែកមួយស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរផ្សេង ជាកន្លែងដែលមិនសូវមានហានិភ័យដល់សិទ្ធិរបស់ជនជាប់ឃុំ។

៣៧. លក្ខខណ្ឌតម្រូវទីពីរដែលចែងនៅក្នុងប្រយោគទី១ នៃកថាខណ្ឌទី៣ គឺថាជនជាប់ឃុំមានសិទ្ធិទទួលបានការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប ប្រសិនបើមិនដូច្នេះទេ ត្រូវដោះលែង។ លក្ខខណ្ឌតម្រូវនេះ អនុវត្តយ៉ាងជាក់លាក់ចំពោះរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន គឺជាការឃុំខ្លួនរវាងពេលចាប់ខ្លួន និងពេលចេញសាលក្រមនៅសាលាដំបូង។[១០៨] ការឃុំខ្លួនបណ្តោះអាសន្នយូរពេក អាចធ្វើឲ្យខូចខាតដល់សច្ចាធារណ៍នៃភាពគ្មានទោសក្រោមមាត្រា១៤ កថាខណ្ឌទី២។[១០៩] ជនដែលមិនត្រូវបានដោះលែងដោយរង់ចាំការជំនុំជម្រះក្តី ត្រូវតែជំនុំជម្រះឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ក្នុងកម្រិតដែលមានសង្គតិភាពជាមួយសិទ្ធិទទួលបានការការពារក្តីរបស់ពួកគេ។[១១០] ភាពសមហេតុផលនៃ

---

[១០៨] បណ្តឹងលេខ១៣៩៧/២០០៥ រវាង Engo និងប្រទេសកាមេរូន កថាខណ្ឌទី៧.២។ អំពីទំនាក់ទំនងរវាងមាត្រា៩ កថាខណ្ឌទី៣ និងមាត្រា១៤ កថាខណ្ឌទី៣(គ) ក្នុងករណីនេះ សូមមើលសេចក្តីពន្យល់ទូទៅលេខ៣២ កថាខណ្ឌទី៦១។

[១០៩] បណ្តឹងលេខ៧៨៨/១៩៩៧ រវាង Cagas និងប្រទេសហ្វីលីពីន កថាខណ្ឌទី៧.៣។

[១១០] សេចក្តីពន្យល់ទូទៅលេខ៣២ កថាខណ្ឌទី៣៥។ បណ្តឹងលេខ៨១៨/១៩៩៨ រវាង Sextus និងប្រទេសទ្រីនីដាត កថាខណ្ឌទី៧.២។

ការពន្យារពេលក្នុងការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ត្រូវយកមកវាយតម្លៃទៅតាមកាលៈទេសៈនៃករណីនីមួយៗ ដោយពិចារណាអំពីភាពសាំញ៉ាំនៃសំណុំរឿង ចរិយាមាយាទរបស់ជនជាប់ចោទក្នុងអំឡុងពេលដំណើរការក្តី និងវិធីនៃចំណាត់ការទៅលើបញ្ហានោះដោយអាជ្ញាធរនីតិប្រតិបត្តិ និងតុលាការ។[១១១] ឧបសគ្គដល់ការបញ្ចប់ការស៊ើបអង្កេត អាចធ្វើយុត្តិកម្មឲ្យមានរយៈពេលបន្ថែម[១១២] ប៉ុន្តែលក្ខខណ្ឌទូទៅនៃការខ្វះខាតបុគ្គលិក ឬថវិកាមិនអាចធ្វើជាយុត្តិកម្មបាន។[១១៣] នៅពេលការពន្យារពេលក្លាយជាការចាំបាច់ ចៅក្រមត្រូវពិចារណាឡើងវិញពីជម្រើសផ្សេងៗក្រៅពីការឃុំខ្លួនបណ្តោះអាសន្ន។[១១៤] ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនគួរតែជៀសវាង ប៉ុន្តែបើជៀសមិនបាន ពួកគេមានសិទ្ធិត្រូវបាននាំខ្លួនមកជំនុំជម្រះទោសដោយឆាប់បំផុត ក្រោមមាត្រា១០ កថាខណ្ឌទី២(ខ)។[១១៥]

---

[១១១]. បណ្តឹងលេខ១០៨៥/២០០២ រវាង Taright និងប្រទេសអាល់ហ្សេរី កថាខណ្ឌទី៨.២-៨.៤។ បណ្តឹងលេខ៣៨៦/១៩៨៩ រវាង Koné និងប្រទេសសេណេហ្គាល់ កថាខណ្ឌទី៨.៦។ បណ្តឹងលេខ៧៧៧/១៩៩៦ រវាង Teesdale និងប្រទេសទ្រីនីដាត&តូបាហ្គូ កថាខណ្ឌទី៩.៣ (ការពន្យារពេល១៧ខែ បានបំពានកថាខណ្ឌទី៣)។ បណ្តឹងលេខ៦១៤/១៩៩៥ រវាង Thomas និងប្រទេសចាម៉ៃកា កថាខណ្ឌទី៩.៦ (ការពន្យារពេលស្ទើរតែ១៤ខែ មិនបានបំពានកថាខណ្ឌទី៣ទេ)។ សេចក្តីពន្យល់ទូទៅលេខ៣២ កថាខណ្ឌទី៣៥ (ការពិភាក្សាកត្តានានាពាក់ព័ន្ធនឹងភាពសមហេតុផលនៃការពន្យារពេលនៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ)។

[១១២]. បណ្តឹងលេខ៧២១/១៩៩៧ រវាង Boodoo និងប្រទេសទ្រីនីដាត&តូបាហ្គូ កថាខណ្ឌទី៦.២។

[១១៣]. បណ្តឹងលេខ៣៣៦/១៩៨៨ រវាងFillastre និងប្រទេសបូលីវី កថាខណ្ឌទី៦.៥។ បណ្តឹងលេខ៨១៨/១៩៩៨ រវាង Sextus និងប្រទេសទ្រីនីដាត&តូបាហ្គូ កថាខណ្ឌទី៤.២&៧.២។

[១១៤]. បណ្តឹងលេខ១០៨៥/២០០២ រវាង Taright និងប្រទេសអាល់ហ្សេរី កថាខណ្ឌទី៨.៣។

[១១៥]. សេចក្តីពន្យល់ទូទៅលេខ២១ កថាខណ្ឌទី១៣។ សេចក្តីពន្យល់ទូទៅលេខ៣២ កថាខណ្ឌទី៤៥។ សេចក្តីពន្យល់ទូទៅលេខ១០ កថាខណ្ឌទី៨៣ របស់គណៈកម្មាធិការសិទ្ធិកុមារ។

៣៨. ប្រយោគទីពីរនៃកថាខណ្ឌទី៣ តម្រូវថា ការឃុំខ្លួនមនុស្សរង់ចាំការជំនុំជម្រះក្តី ត្រូវតែជាករណីលើកលែង មិនមែនជាវិធាននោះទេ។ មាត្រានេះក៏ចែងផងដែរថា ការដោះលែងពីការឃុំខ្លួនបែបនេះអាចត្រូវមានការធានាពីការបង្ហាញខ្លួន រួមទាំងការបង្ហាញខ្លួននៅពេលសវនាការ ការបង្ហាញខ្លួននៅតាមដំណាក់កាលផ្សេងៗទៀតនៃដំណើរការនីតិវិធីតាមផ្លូវតុលាការ និង(ប្រសិនបើវាកើតឡើង) ការបង្ហាញខ្លួននៅពេលអនុវត្តសាលក្រម។ ប្រយោគនេះអនុវត្តចំពោះជនដែលរង់ចាំការជំនុំជម្រះពីបទព្រហ្មទណ្ឌ ពោលគឺ បន្ទាប់ពីចុងចោទត្រូវបានចោទប្រកាន់ ប៉ុន្តែលក្ខខណ្ឌតម្រូវស្រដៀងគ្នាមុនពេលចោទប្រកាន់ កើតចេញពីបំរាមនៃការឃុំខ្លួនតាមទំនើងចិត្តក្នុងកថាខណ្ឌទី១។[១១៦] ការឃុំខ្លួនចុងចោទបណ្តោះអាសន្ន មិនគួរជាការអនុវត្តទូទៅនោះឡើយ។ ការឃុំខ្លួនរង់ចាំជំនុំជម្រះក្តី ត្រូវតែផ្អែកលើការកំណត់ទៅតាមករណីនីមួយៗ ដោយមានសំអាងហេតុ និងចាំបាច់ ក្នុងគ្រប់កាលៈទេសៈ ក្នុងគោលបំណងដើម្បីបង្ការការរត់គេច ការជ្រៀតជ្រែកភស្តុតាង និងបទល្មើសកើតឡើងវិញ។[១១៧] កត្តាពាក់ព័ន្ធគួរមានបញ្ញាក់ក្នុងច្បាប់ ហើយមិនគួរដាក់បញ្ចូលបទដ្ឋានមិនច្បាស់លាស់ និងទូលំទូលាយពេក ដូចជា "សន្តិសុខសាធារណៈ"។[១១៨] ការឃុំខ្លួនបណ្តោះអាសន្ន មិនគួរជាកាតព្វកិច្ចដល់ចុងចោទគ្រប់រូប ដែលត្រូវចោទប្រកាន់ពីបទល្មើសជាក់លាក់មួយ

[១១៦]. បណ្តឹងលេខ១១២៨/២០០២ រវាង Marques de Morais និងប្រទេសអង់ហ្គោឡា កថាខណ្ឌទី៦.១-៦.៤។

[១១៧]. បណ្តឹងលេខ១៥០២/២០០៦ រវាង Marinich និងប្រទេសបេលឡារូស កថាខណ្ឌទី១០.៤។ បណ្តឹងលេខ១៩៤០/២០១០ រវាង Cedeño និងប្រទេសវេណេហ្ស៊ុយអេឡា កថាខណ្ឌទី៧.១០។ បណ្តឹងលេខ១៥៤៧/២០០៧ រវាង Torobekov និងប្រទេសគៀកជីស្ថាន កថាខណ្ឌទី៦.៣។

[១១៨]. សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសបូស្នៀ និងអែហ្សេហ្គោវីណា ឆ្នាំ២០០៦ កថាខណ្ឌទី១៨។

ដោយមិនគិតទៅតាមកាលៈទេសៈនីមួយៗនោះឡើយ[១១៩] ហើយការឃុំខ្លួនបណ្ដោះអាសន្ន ក៏មិនត្រូវបានបញ្ជាឲ្យធ្វើឡើងសំរាប់រយៈពេលមួយដោយផ្អែកលើទោសដែលជននោះអាចនឹងទទួលចំពោះបទល្មើសដែលត្រូវចោទប្រកាន់នោះដែរ ប៉ុន្តែត្រូវផ្អែកលើការកំណត់ពីភាពចាំបាច់។ តុលាការត្រូវពិនិត្យថាតើជម្រើសផ្សេងក្រៅពីការឃុំខ្លួន ដូចជាការដោះលែងដោយមានប្រាក់ធានា ខ្សែដៃអេឡិចត្រូនិក ឬលក្ខខណ្ឌដទៃទៀត នឹងដាក់ការឃុំខ្លួនទៅជាមិនចាំបាច់ក្នុងករណីជាក់លាក់ដែរឬទេ។[១២០] ប្រសិនបើចុងចោទគឺជាជនបរទេស គេមិនត្រូវចាត់ទុកអង្គហេតុនេះថាគ្រប់គ្រាន់ ដើម្បីកំណត់ថាចុងចោទនោះអាចគេចខ្លួនពីយុត្តាធិការនោះឡើយ។[១២១] បន្ទាប់ពីមានការកំណត់បឋមថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាការចាំបាច់ គួរតែមានការពិនិត្យឡើងវិញទៀងទាត់ទៅលើ ថាតើវានៅតែសមហេតុផល និងចាំបាច់ដែរឬទេ ប្រសិនបើអាចមានជម្រើសផ្សេង។[១២២] ប្រសិនបើរយៈពេលដែលចុងចោទត្រូវបានឃុំខ្លួន ឈានដល់រយៈពេលអតិបរិមានៃទោស ដែលអាចត្រូវផ្តន្ទាសម្រាប់បទល្មើសដែលត្រូវចោទ ចុងចោទគួរតែត្រូវបានដោះលែង។ ការឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជនគួរត្រូវជៀសវាងឲ្យបានច្រើនបំផុតតាមតែអាចធ្វើបាន។[១២៣]

[១១៩] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអាហ្សង់ទីន ឆ្នាំ២០០០ កថាខណ្ឌទី១០។ សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសស្រីលង្កា ឆ្នាំ២០០៣ កថាខណ្ឌទី១៣។

[១២០] បណ្តឹងលេខ១១៧៨/២០០៣ រវាង Smantser និងប្រទេសបេលឡារុស កថាខណ្ឌទី១០.៣។

[១២១] បណ្តឹងលេខ៥២៦/១៩៩៣ រវាង Hill & Hill និងប្រទេសអេស្ប៉ាញ កថាខណ្ឌទី១២.៣។

[១២២] បណ្តឹងលេខ១០៨៥/២០០២ រវាង Taright និងប្រទេសអាល់ហ្សេរី កថាខណ្ឌទី៨.៣-៨.៤។

[១២៣] សេចក្តីពន្យល់ទូទៅលេខ៣២ កថាខណ្ឌទី៤២ និងសេចក្តីពន្យល់ទូទៅលេខ១០ កថាខណ្ឌទី៨០ របស់គណៈកម្មាធិការសិទ្ធិកុមារ។

## V. សិទ្ធិក្នុងការធ្វើចំណាត់ការ ដើម្បីដោះលែងពីការឃុំខ្លួនមិនត្រឹមត្រូវតាមច្បាប់ ឬតាមទំនើងចិត្ត

៣៩. កថាខណ្ឌទី៤ ផ្តល់សិទ្ធិដល់ជនណាដែលត្រូវបានដកហូតសេរីភាព ដោយការចាប់ខ្លួន ឬឃុំខ្លួន ឲ្យចាត់ការរឿងក្តីរបស់ខ្លួនទៅតុលាការ ដើម្បីឲ្យតុលាការអាចសម្រេចដោយគ្មានការពន្យារពេល អំពីភាពត្រឹមត្រូវតាមច្បាប់នៃការឃុំខ្លួននោះ និងបញ្ជាឲ្យដោះលែង ប្រសិនបើការឃុំខ្លួននោះមិនស្របច្បាប់។ កថាខណ្ឌនេះតំកល់គោលការណ៍ *habeas corpus*។[១២៤] ការពិនិត្យឡើងវិញលើមូលដ្ឋានអង្គហេតុនៃការឃុំខ្លួន នៅក្នុងកាលៈទេសៈសមស្រប អាចត្រូវបានកម្រិតត្រឹមការពិនិត្យឡើងវិញលើភាពសមហេតុផលនៃការកំណត់ពីមុន។[១២៥]

៤០. សិទ្ធិនេះអនុវត្តចំពោះគ្រប់ការឃុំខ្លួនដោយវិធានការផ្លូវការ ឬយោងតាមការអនុញ្ញាតជាផ្លូវការ រួមទាំងការឃុំខ្លួនដែលទាក់ទងនឹងដំណើរការក្តីព្រហ្មទណ្ឌ ការឃុំខ្លួនដោយយោធា ការឃុំខ្លួនដោយហេតុផលសន្តិសុខ ការឃុំខ្លួនដោយហេតុផលប្រឆាំងភេរវកម្ម ការបង្ខំឲ្យសម្រាកពេទ្យ ការឃុំខ្លួនដោយហេតុផលអន្តោរប្រវេសន៍ ការឃុំខ្លួនសម្រាប់ធ្វើបត្យាប័ន និងការចាប់ខ្លួនដោយគ្មានមូលដ្ឋានទាំង

[១២៤] បណ្តឹងលេខ១៣៤២/២០០៥ រវាង Gavrilin និងប្រទេសបេលឡារូស កថាខណ្ឌទី៧.៤។

[១២៥] បណ្តឹងលេខ១០៥១/២០០២ រវាង Ahani និងប្រទេសកាណាដា កថាខណ្ឌទី១០.២។ បណ្តឹងលេខ ៧៥៤/១៩៩៧ រវាង A និងប្រទេសណូវែលហ្សេឡង់ដ៍ កថាខណ្ឌទី៧.៣។

ស្រុង។[១២៦] សិទ្ធិនេះក៏អនុវត្តផងដែរចំពោះការឃុំខ្លួនដោយសារភាពអនាថា ឬការញៀនថ្នាំ និងការឃុំខ្លួនសម្រាប់គោលបំណងអប់រំកុមារទំនាស់នឹងច្បាប់[១២៧] និងទម្រង់ផ្សេងទៀតនៃការឃុំខ្លួនបែបរដ្ឋបាល។[១២៨] ការឃុំខ្លួននៅក្នុងអត្ថន័យនៃកថាខណ្ឌទី៤ ក៏រួមបញ្ចូលផងដែរការឃាត់ខ្លួនក្នុងផ្ទះ និងការបង្ខាំងឲ្យនៅតែឯង។[១២៩] នៅពេលអ្នកទោសម្នាក់ កំពុងបំរើទោសជាប់ពន្ធនាគារបានរយៈពេលអប្បបរមា តាមការសម្រេចពីតុលាការបន្ទាប់ពីការផ្តន្ទាទោស ទោះជាទោសសម្រាប់រយៈពេលកំណត់មួយ ឬជាផ្នែកមួយនៃទោសវែងជាងនេះ កថាខណ្ឌទី៤ មិនបានតម្រូវឲ្យមានការពិនិត្យឡើងវិញពីការឃុំខ្លួននោះទេ នៅពេលក្រោយមកទៀត។[១៣០]

---

១២៦. បណ្តឹងលេខ២៤៨/១៩៨៧ រវាង Campbell និងប្រទេសចាម៉ៃកា កថាខណ្ឌទី៦.៤។ បណ្តឹងលេខ៩៦២/២០០១ រវាង Mulezi និងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ កថាខណ្ឌទី៥.២។ បណ្តឹងលេខ១០៥១/២០០២ រវាង Ahani និងប្រទេសកាណាដា កថាខណ្ឌទី១០.២។ បណ្តឹងលេខ១០៦២/២០០២ រវាង Fijalkowska និងប្រទេសប៉ូឡូញ កថាខ័ណ្ឌទី៨.៤។ បណ្តឹងលេខ២៩១/១៩៨៨ រវាង Torres និងប្រទេសហ្វាំងឡង់ កថាខណ្ឌទី៧.៤។ បណ្តឹងលេខ៤១៤/១៩៩០ រវាង Mika Miha និងប្រទេសអេក្វាទ័រហ្គីណេ កថាខណ្ឌទី៦.៥។

១២៧ បណ្តឹងលេខ២៦៥/១៩៨៧ រវាង Vuolanne និងប្រទេសហ្វាំងឡង់ កថាខ័ណ្ឌទី៩.៥។ សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសរ៉ាំន់ដា ឆ្នាំ២០០៩ កថាខណ្ឌទី១៦ (ដែលបានផ្តល់អនុសាសន៍ឲ្យលប់ចោលការឃុំខ្លួនពីភាពអារ៉ាំសែ)។

១២៨. សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសម៉ុលដូវ៉ា ឆ្នាំ២០០២ កថាខណ្ឌទី១១។

១២៩. បណ្តឹងលេខ១១៧២/២០០៣ រវាង Madani និងប្រទេសអាល់ហ្សេរី កថាខ័ណ្ឌទី៨.៥។ បណ្តឹងលេខ២៦៥/១៩៨៧ រវាង Vuolanne និងប្រទេសហ្វាំងឡង់ កថាខ័ណ្ឌទី៩.៥។

១៣០. បណ្តឹងលេខ៩៥៤/២000 រវាង Minogue និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៦.៤។ បណ្តឹងលេខ១៣៤២/២០០៥ រវាង Gavrilin និងប្រទេសបែលឡារូស កថាខណ្ឌទី៧.៤។ ទោះយ៉ាងណាក៏ដោយ មាត្រា១៤ កថាខ័ណ្ឌទី៥ ធានាដល់ជនជាប់ចោទពីសិទ្ធិប្តឹងឧទ្ធរណ៍ម្តងពីការផ្តន្ទាទោសនៅសាលាក្តីថ្នាក់ដំបូង ទៅតុលាការជាន់ខ្ពស់មួយ។ សេចក្តីពន្យល់ទូទៅលេខ៣២ កថាខណ្ឌទី៤៥។

៤១. កម្មវត្ថុនៃសិទ្ធិនេះ គឺការដោះលែង (ទោះជាគ្មានលក្ខខណ្ឌក្តី ឬមានលក្ខខណ្ឌក្តី)[១៣១] ពីការឃុំខ្លួនបន្តដែលមិនត្រឹមត្រូវតាមច្បាប់ សំណងសម្រាប់ការឃុំខ្លួនមិនត្រឹមត្រូវតាមច្បាប់ដែលបានបញ្ជាប់ មានចែងក្នុងកថាខណ្ឌទី៥។ កថាខណ្ឌទី៤ តម្រូវថាតុលាការដែលមានតួនាទីពិនិត្យឡើងវិញ ត្រូវមានអំណាចបញ្ជាឲ្យដោះលែងពីការឃុំខ្លួនមិនត្រឹមត្រូវតាមច្បាប់។[១៣២] នៅពេលដីកាបង្គាប់តុលាការឲ្យដោះលែងក្រោមកថាខណ្ឌទី៤ អាចអនុវត្តបាន ដីកានេះត្រូវតែអនុវត្តភ្លាមៗ បើមិនដូច្នេះទេ ការឃុំខ្លួនបន្តនឹងក្លាយជាតាមទំនើងចិត្ត ដោយរំលោភបំពានមាត្រា៩ កថាខណ្ឌទី១។[១៣៣]

៤២. សិទ្ធិប្តឹងឲ្យមានដំណើរការក្តីអនុវត្តតាមគោលការណ៍ ចាប់ពីពេលចាប់ខ្លួន និងរយៈពេលរង់ចាំសំខាន់ៗណាមួយមុនពេលជនជាប់ឃុំអាចប្តឹងជាលើកទី១ ពីការឃុំខ្លួន មិនអាចអនុញ្ញាតិបានទេ។[១៣៤] ជាទូទៅ ជនជាប់ឃុំមានសិទ្ធិបង្ហាញមុខនៅតុលាការ ជាពិសេសនៅពេលដែលវត្តមានបែបនេះ អាចជួយដល់ការស៊ើបសួរពីភាពត្រឹមត្រូវតាមច្បាប់នៃការឃុំខ្លួន ឬនៅពេលកើតមានបញ្ហាទាក់ទងនឹងការប្រព្រឹត្តមិនគប្បីទៅលើជនជាប់ឃុំ។[១៣៥] តុលាការត្រូវមានអំណាចបញ្ជាឲ្យនាំជនជាប់ឃុំចូលមកតុលាការ ដោយមិនគិតថាតើជនជាប់ឃុំបានស្នើសុំចូលខ្លួន ឬមិនចូលខ្លួនក៏ដោយ។

---

[១៣១]. បណ្តឹងលេខ៤៧៣/១៩៩១ រវាង Barroso និងប្រទេសប៉ាណាម៉ា កថាខណ្ឌទី២.៤ និង៨.២។

[១៣២]. បណ្តឹងលេខ១៣២៤/២០០៤ រវាង Shafiq និងប្រទេសអូស្រ្តាលី កថាខណ្ឌទី៧.៤។

[១៣៣]. បណ្តឹងលេខ៨៥៦/១៩៩៩ រវាង Chambala និងប្រទេសហ្សំប៊ី កថាខណ្ឌទី៧.២។

[១៣៤]. បណ្តឹងលេខ២៩១/១៩៨៨ រវាង Torres និងប្រទេសហ្វាំងឡង់ កថាខណ្ឌទី៧.២ (ប្រាំពីរថ្ងៃ)។

[១៣៥]. សូមមើលកម្រងគោលការណ៍ (កំណត់សំគាល់ក្នុងលេខ១០២ ខាងលើ) គោលការណ៍៣២(២)។ សេចក្តីពន្យល់ទូទៅលេខ២៩ កថាខ័ណ្ឌទី១៦។

៤៣. ការឃុំខ្លួនមិនត្រឹមត្រូវតាមច្បាប់ រួមមាន ការឃុំខ្លួនដែលពីដំបូងទីត្រឹមត្រូវតាមច្បាប់ ប៉ុន្តែបានក្លាយជាមិនត្រឹមត្រូវតាមច្បាប់វិញពីព្រោះជននោះបានបំរើទោសគុករួចរាល់ហើយ ឬពីព្រោះកាលៈទេសៈដែលធ្វើយុត្តិកម្មដល់ការឃុំខ្លួននោះបានផ្លាស់ប្តូរ។[១៣៦] បន្ទាប់ពីតុលាការបានសម្រេចថា កាលៈទេសៈតម្រូវឲ្យមានការឃុំខ្លួននោះរយៈពេលសមស្របមួយអាចកន្លងផុតទៅ អាស្រ័យលើចរិកលក្ខណៈនៃកាលៈទេសៈពាក់ព័ន្ធ មុនពេលបុគ្គលនោះមានសិទ្ធិប្តឹងឲ្យមានដំណើរការក្តីម្តងទៀតដោយផ្អែកលើមូលដ្ឋានស្រដៀងគ្នា។[១៣៧]

៤៤. ការឃុំខ្លួន "មិនត្រឹមត្រូវតាមច្បាប់" រួមបញ្ចូលទាំងការឃុំខ្លួនដែលរំលោភលើច្បាប់ជាតិ និងការឃុំខ្លួនដែលមិនស្របតាមលក្ខខណ្ឌតម្រូវនៃមាត្រា៩ កថាខណ្ឌទី១ ឬបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀតនៃកតិកាសញ្ញានេះ។[១៣៨] ខណៈដែលប្រព័ន្ធច្បាប់ជាតិអាចបង្កើតវិធីសាស្រ្តខុសគ្នា ដើម្បីធានាឲ្យតុលាការពិនិត្យឡើងវិញអំពីការឃុំខ្លួនកថាខណ្ឌទី៤ តម្រូវឲ្យមានដំណោះស្រាយមួយពីតុលាការសម្រាប់ការឃុំខ្លួនណាដែលមិនត្រឹមត្រូវតាមច្បាប់ ដោយផ្អែកលើមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋានទាំងនេះ។[១៣៩] ឧទាហរណ៍ អំណាចរបស់តុលាការគ្រួសារ បញ្ជាឲ្យដោះលែងកុមារម្នាក់ ពីការឃុំខ្លួនដែលមិនមែនជាឧត្តមប្រយោជន៍របស់កុមារ អាចបំពេញលក្ខខណ្ឌតម្រូវ

[១៣៦]. បណ្តឹងលេខ១០៩០/២០០២ រវាង Rameka និងប្រទេសណូវែលហ្សេឡង់ដ៍ កថាខណ្ឌទី៧.៣-៧.៤។

[១៣៧]. ដូចខាងលើ។ បណ្តឹងលេខ៧៥៤/១៩៩៧ រវាង A និងប្រទេសណូវែលហ្សេឡង់ដ៍ កថាខណ្ឌទី៧.៣។ បណ្តឹងលេខ២៩១/១៩៨៨ រវាង Torres និងប្រទេសហ្វាំងឡង់ កថាខណ្ឌទី៧.៤ (ការពិនិត្យរៀងរាល់ពីរសប្តាហ៍អំពីការឃុំខ្លួនសំរាប់ការធ្វើបត្យាប័ន)។

[១៣៨]. បណ្តឹងលេខ១២៥៥/២០០៤ et al., រវាង Shams et al និងប្រទេសអូស្រ្តាលី កថាខណ្ឌទី៧.៣។

[១៣៩]. ដូចខាងលើ។

នៃកថាខណ្ឌទី៤ នៅក្នុងករណីពាក់ព័ន្ធនានា។[១៤០]

៤៥. កថាខណ្ឌទី៤ ផ្តល់សិទ្ធិឲ្យជននោះ ចាត់ការតាមនីតិវិធីនៅចំពោះមុខ "តុលាការ" ដែលជាធម្មតាគួរតែជាតុលាការមួយនៅក្នុងប្រព័ន្ធយុត្តិធម៌។ ក្នុងករណីពិសេស សម្រាប់ទម្រង់ខ្លះនៃការឃុំខ្លួន ច្បាប់អាចអនុញ្ញាតឲ្យមានដំណើរការក្តី នៅចំពោះមុខសាលាក្តីឯកទេសមួយ ដែលត្រូវបង្កើតឡើងដោយច្បាប់ និងត្រូវតែឯករាជ្យពីអង្គនីតិប្រតិបត្តិ និងអង្គនីតិបញ្ញត្តិ ឬត្រូវតែមានឯករាជ្យភាពតុលាការក្នុងការសម្រេចពីបញ្ហាច្បាប់ ក្នុងដំណើរការក្តីដែលមានចរិកលក្ខណៈជាយុត្តាធិការសុទ្ធសាធ។[១៤១]

៤៦. កថាខណ្ឌទី៤ ផ្តល់ជម្រើសនៃការចាត់ការតាមនីតិវិធីទៅឲ្យជនដែលកំពុងជាប់ឃុំ ឬអ្នកដែលធ្វើការក្នុងនាមពួកគេ មិនដូចកថាខណ្ឌទី៣ទេ វាមិនតម្រូវឲ្យមានការផ្តួចផ្តើមដោយស្វ័យប្រវត្តិ នៃការពិនិត្យឡើងវិញដោយអាជ្ញាធរដែលមានអំណាចឃុំខ្លួននោះទេ។[១៤២] ច្បាប់ដែលផាត់ចេញជនជាប់ឃុំប្រភេទខ្លះ ពីការពិនិត្យឡើងវិញ ដែលតម្រូវដោយកថាខណ្ឌទី៤ បំពានកតិកាសញ្ញានេះ។[១៤៣] ការអនុវត្ត

---

[១៤០] បណ្តឹងលេខ១០៦៩/២០០២ រវាង Bakhtiyari និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៩.៥។

[១៤១] បណ្តឹងលេខ១០៩០/២០០២ រវាង Rameka និងប្រទេសណូវែលហ្សេឡង់ដ៍ កថាខណ្ឌទី៧.៤។ បណ្តឹងលេខ២៩១/១៩៨៨ រវាង Torres និងប្រទេសហ្វាំងឡង់ កថាខណ្ឌទី៧.២។ បណ្តឹងលេខ២៦៥/១៩៨៧ រវាង Vuolanne និងប្រទេសហ្វាំងឡង់ កថាខ័ណ្ឌទី៩.៦។ សូមមើលសេចក្តីពន្យល់ទូទៅលេខ៣២ កថាខណ្ឌទី១៨-២២។

[១៤២] បណ្តឹងលេខ៣៧៣/១៩៨៩ រវាង Stephens និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៩.៧។

[១៤៣] បណ្តឹងលេខR.1/4 រវាង Torres Ramírez និងប្រទេសអ៊ុយរុយហ្គាយ កថាខ័ណ្ឌទី១៨។ បណ្តឹងលេខ១៤៤៩/២០០៦ រវាង Umarov និងប្រទេសអ៊ុយបេគីស្ថាន កថាខ័ណ្ឌទី៨.៦។

ដែលផ្តល់ឲ្យមានការពិនិត្យឡើងវិញដ៏មានប្រសិទ្ធភាព មិនអាចមានដល់បុគ្គលណាមួយ រួមទាំងការឃុំខ្លួនដាច់ដោយឡែកពីអ្នកដទៃផង ក៏មានន័យថាជាការរំលោភបំពានដែរ។[១៤៤] ដើម្បីសម្រួលដល់ការពិនិត្យឡើងវិញដ៏មានប្រសិទ្ធភាព ជនជាប់ឃុំគួរតែអាចស្វែងរកមេធាវីបានភ្លាមៗ និងទៀងទាត់។ ជនជាប់ឃុំគួរត្រូវបានជូនដំណឹងតាមភាសាមួយដែលខ្លួនយល់ អំពីសិទ្ធិចាត់ការតាមនីតិវិធីដើម្បីឲ្យមានការសម្រេចអំពីភាពត្រឹមត្រូវតាមច្បាប់នៃការឃុំខ្លួនពួកគេ។[១៤៥]

៤៧. ជនដែលត្រូវបានដកហូតសេរីភាព មានសិទ្ធិមិនត្រឹមតែចាត់ការតាមនីតិវិធីនោះទេ ប៉ុន្តែមានសិទ្ធិទទួលបានសេចក្តីសម្រេចមួយពីបញ្ហានេះ ដោយគ្មានការពន្យារពេល។ ការបដិសេធរបស់តុលាការមានសមត្ថកិច្ច ក្នុងការចេញសេចក្តីសម្រេចលើបណ្តឹងសុំដោះលែងរបស់ជនជាប់ឃុំ រំលោភលើកថាខណ្ឌទី៤។[១៤៦] ការវិនិច្ឆ័យលើសំណុំរឿងនេះគួរតែចាត់ការឲ្យបានរហ័សបំផុតតាមតែអាចធ្វើបាន។[១៤៧] ការពន្យារពេលដោយសារតែអ្នកប្តឹង មិនត្រូវបានចាត់ទុកថាជាការពន្យារពេលរបស់តុលាការឡើយ។[១៤៨]

[១៤៤]. បណ្តឹងលេខR.1/5 រវាង Hernández Valentini de Bazzano និងប្រទេសអ៊ុយរុយហ្គាយ កថាខ័ណ្ឌទី១០។ បណ្តឹងលេខ១៧៥១/២០០៨ រវាង Aboussedra និងប្រទេសស៊ីរី អារ៉ាប់ កថាខ័ណ្ឌទី៧.៦។ បណ្តឹងលេខ១០៦២/២០០២ រវាង Fijalkowska និងប្រទេសប៉ូឡូញ កថាខ័ណ្ឌទី៨.៤។

[១៤៥]. កម្រងគោលការណ៍ (សំគាល់ លេខយោង១០២ខាងលើ) គោលការណ៍១៣-១៤។

[១៤៦]. បណ្តឹងលេខ១១២៨/២០០២ រវាង Marques de Morais និងប្រទេសអង់ហ្គោឡា កថាខណ្ឌទី៦.៥។

[១៤៧]. បណ្តឹងលេខ២៩១/១៩៨៨ រវាង Torres និងប្រទេសហ្វាំងឡង់ កថាខណ្ឌទី៧.៣។

[១៤៨]. បណ្តឹងលេខ១០៥១/២០០២ រវាង Ahani និងប្រទេសកាណាដា កថាខណ្ឌទី១០.៣។

៤៨. កតិកាសញ្ញានេះ មិនបានតម្រូវថា សេចក្ដីសម្រេចរបស់តុលាការដែលតម្កល់ភាពត្រឹមត្រូវតាមច្បាប់នៃការឃុំខ្លួន អាចប្ដឹងឧទ្ធរណ៍នោះទេ។ ប្រសិនបើរដ្ឋភាគី អនុញ្ញាតឲ្យមានបណ្ដឹងឧទ្ធរណ៍ ឬបញ្ជូនទៅតុលាការមួយកម្រិតទៀត ការពន្យារពេលអាចឆ្លុះបញ្ចាំងពីការផ្លាស់ប្ដូរចរិកលក្ខណៈនៃដំណើរការក្ដី ហើយទោះក្នុងករណីណាក៏ដោយ ក៏មិនត្រូវមានលក្ខណៈហួសហេតុពេកដែរ។[១៤៩]

[១៤៩] បណ្ដឹងលេខ១៧៥២/២០០៨ រវាង J.S និងប្រទេសណូវ៉ែលហ្សេឡង់ដ៍ កថាខណ្ឌទី៦.៣-៦.៤។

## VI. សិទ្ធិទទួលបានសំណងចំពោះការចាប់ខ្លួន ឬការឃុំខ្លួនដែលមិនត្រឹមត្រូវតាមច្បាប់ ឬតាមទំនើងចិត្ត

៤៩. កថាខណ្ឌទី៥ មាត្រា៩ នៃកតិកាសញ្ញា ចែងថា ជនណាដែលបានក្លាយជាជនរងគ្រោះនៃការចាប់ខ្លួន ឬការឃុំខ្លួនដោយមិនត្រឹមត្រូវតាមច្បាប់ ត្រូវមានសិទ្ធិទទួលបានសំណង។ ដូចកថាខណ្ឌទី៤ ដែរ កថាខណ្ឌទី៥ ចែងអំពីឧទាហរណ៍ជាក់លាក់នៃសំណងប្រកបដោយប្រសិទ្ធភាពមួយចំពោះអំពើរំលោភសិទ្ធិមនុស្ស ដែលរដ្ឋភាគីត្រូវផ្តល់ជូន។ សំណងជាក់លាក់ទាំងនេះ ត្រូវរួមបញ្ចូលជាមួយសំណងដទៃទៀត មិនជំនួសឲ្យសំណងផ្សេងទៀតដែលអាចតម្រូវ នៅក្នុងស្ថានភាពពិសេសមួយដល់ជនរងគ្រោះនៃការចាប់ខ្លួន ឬការឃុំខ្លួនដោយមិនត្រឹមត្រូវតាមច្បាប់ ឬតាមទំនើងចិត្ត តាមមាត្រា២ កថាខណ្ឌទី៣ នៃកតិកាសញ្ញានេះឡើយ។[១៥០] ខណៈកថាខណ្ឌទី៤ចែងអំពីសំណងភ្លាមៗមួយ សម្រាប់ការដោះលែងពីការបន្តការឃុំខ្លួនដោយមិនត្រឹមត្រូវតាមច្បាប់ កថាខណ្ឌទី៥ បញ្ជាក់ថា ជនរងគ្រោះនៃការចាប់ខ្លួន ឬការឃុំខ្លួនដោយមិនត្រឹមត្រូវតាមច្បាប់ ក៏មានសិទ្ធិទទួលបានសំណងហិរញ្ញវត្ថុដែរ។

---

[១៥០] សេចក្តីពន្យល់ទូទៅលេខ៣១ កថាខណ្ឌទី១៦ និង១៨។ បណ្តឹងលេខ២៣៨/១៩៨៧ រវាង Bolaños និងប្រទេសអេក្វាទ័រ កថាខណ្ឌទី១០។ បណ្តឹងលេខ៩៦២/២០០១ រវាង Mulezi និងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ កថាខណ្ឌទី៧។

៥០. កថាខណ្ឌទី៥ តម្រូវឲ្យរដ្ឋភាគី បង្កើតក្របខ័ណ្ឌច្បាប់សម្រាប់ផ្តល់សំណងដល់ជនរងគ្រោះ ទៅជាបញ្ហានៃសិទ្ធិដែលអាចអនុវត្តបាន និងមិនមែនជាបញ្ហានៃការប្រទានឬឆន្ទានុសិទ្ធិនោះឡើយ។ សំណងមិនត្រូវមានតែក្នុងទ្រឹស្តីនោះទេ ប៉ុន្តែត្រូវអនុវត្តដោយប្រសិទ្ធភាព និងត្រូវបង់ប្រាក់នៅក្នុងរយៈពេលសមស្របមួយ។ កថាខណ្ឌទី៥ មិនបានបញ្ជាក់ពីទម្រង់ជាក់លាក់នៃនីតិវិធី ដែលអាចរួមបញ្ចូលទាំងសំណងនានាពីរដ្ឋផ្ទាល់ឬពីមន្ត្រីម្នាក់ៗរបស់រដ្ឋដែលទទួលខុសត្រូវចំពោះការរំលោភនោះ ធ្វើយ៉ាងណាឲ្យមានប្រសិទ្ធភាព។[១៥១] កថាខណ្ឌទី៥ មិនតម្រូវថា ត្រូវតែបង្កើតនីតិវិធីតែមួយសំរាប់សំណងចំពោះគ្រប់ទម្រង់នៃការចាប់ខ្លួនដោយមិនត្រឹមត្រូវតាមច្បាប់នោះទេ ប៉ុន្តែគ្រាន់តែតម្រូវឲ្យមានប្រព័ន្ធនីតិវិធីប្រកបដោយប្រសិទ្ធភាពមួយ ដែលផ្តល់សំណងក្នុងគ្រប់ករណីដែលមានចែងក្នុងកថាខណ្ឌទី៥។ កថាខណ្ឌទី៥ មិនតម្រូវឲ្យរដ្ឋភាគី ផ្តល់សំណងដល់ជនរងគ្រោះ *តាមឆន្ទៈរបស់គេនោះទេ* ប៉ុន្តែអនុញ្ញាតឲ្យពួកគេទុកការចាប់ផ្តើមនៃដំណើរការទាមទារសំណងឲ្យជនរងគ្រោះជាអ្នកផ្តួចផ្តើម។[១៥២]

---

[១៥១]. សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសកាំមីរូន ឆ្នាំ២០១០ កថាខណ្ឌ១៩។ សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសហ្គុយយ៉ាណា ឆ្នាំ២០០០ កថាខណ្ឌ១៥។ សេចក្តីសង្កេតសន្និដ្ឋានសំរាប់សហរដ្ឋអាមេរិច ឆ្នាំ១៩៩៥ កថាខណ្ឌ៣៤។ សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអាហ្សង់ទីន ឆ្នាំ១៩៩៥ A/50/40 កថាខណ្ឌ១៥៣។ បណ្តឹងលេខ១៨៨៥/២០០៩ រវាង Horvath និងប្រទេសអូស្ត្រាលី កថាខណ្ឌទី៨.៧។ បណ្តឹងលេខ១៤៣២/២០០៥ រវាង Gunaratna និងប្រទេសស្រីលង្កា កថាខណ្ឌទី៧.៤។ សេចក្តីពន្យល់ទូទៅលេខ៣២ កថាខណ្ឌទី៥២។

[១៥២]. បណ្តឹងលេខ៤១៤/១៩៩០ រវាង Mika Miha និងប្រទេសអេក្វាទ័រហ្គីណេ កថាខណ្ឌទី៦.៥។ បណ្តឹងលេខ៩៦២/២០០១ រវាង Mulezi និងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ កថាខណ្ឌទី៥.២។

៥១. ការចាប់ខ្លួន និងការឃុំខ្លួនដោយមិនត្រឹមត្រូវតាមច្បាប់ នៅក្នុងអត្ថន័យនៃកថាខណ្ឌទី៥ រួមបញ្ចូលទាំងការចាប់ខ្លួន ឬការឃុំខ្លួនដែលកើតឡើងនៅក្នុងដំណើរការក្តីព្រហ្មទណ្ឌ ឬមិនមែនព្រហ្មទណ្ឌ ឬគ្មានដំណើរការក្តីសោះតែម្តង។[១៥៣] ចរិកលក្ខណៈ "មិនត្រឹមត្រូវតាមច្បាប់" នៃការចាប់ខ្លួន ឬការឃុំខ្លួន អាចបណ្តាលមកពីការរំលោភច្បាប់ជាតិ ឬរំលោភកតិកាសញ្ញានេះតែម្តង ដូចជា ការឃុំខ្លួនតាមទំនើងចិត្តជាសារធាតុ និងការឃុំខ្លួនដែលបំពានលក្ខខណ្ឌតម្រូវតាមនីតិវិធីនៃកថាខណ្ឌដទៃទៀតនៃមាត្រា៩។[១៥៤] ទោះជាយ៉ាងណាក្តី ការដែលថាចុងចោទម្នាក់នៃបទព្រហ្មទណ្ឌនៅទីបំផុតត្រូវបានដោះលែង ទោះនៅសាលាដំបូង ឬនៅសាលាឧទ្ធរណ៍ មិនមានន័យថា ការឃុំខ្លួនពីមុនណាមួយ ឬការសម្រេចដោយខ្លួនឯងពីការឃុំខ្លួនពីមុនណាមួយ"មិនត្រឹមត្រូវតាមច្បាប់"នោះឡើយ។[១៥៥]

---

[១៥៣]. បណ្តឹងលេខ៧៥៤/១៩៩៧ រវាង A និងប្រទេសណូវែលហ្សេឡង់ដ៍ កថាខណ្ឌទី៦.៧ និង៧.៤។ បណ្តឹងលេខ១៨៨/១៩៨៤ រវាង Martínez Portorreal និងសាធារណៈរដ្ឋដូមីនិចកាំង កថាខណ្ឌទី១១។ បណ្តឹងលេខ៩៦២/២០០១ រវាង Mulezi និងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ កថាខណ្ឌទី៥.២។

[១៥៤]. បណ្តឹងលេខ១១២៨/២០០២ រវាង Marques de Morais និងប្រទេសអង់ហ្គោឡា កថាខណ្ឌទី៦.៦។ បណ្តឹងលេខ៣២៨/១៩៨៨ រវាង Zelaya Blanco និងប្រទេសនីការ៉ាហ្គ័រ កថាខណ្ឌទី១០.៣ (ការឃុំខ្លួនតាមទំនើងចិត្ត)។ បណ្តឹងលេខ៧២៨/១៩៩៦ រវាង Sahadeo និងប្រទេសហ្គីយ៉ាណា កថាខណ្ឌទី១១ (ការបំពានមាត្រា៩(៣))។ បណ្តឹងលេខ R.2/9 រវាង Santullo Valcada និងប្រទេសអ៊ុយរុយហ្គាយ កថាខណ្ឌទី១៣ (ការបំពានមាត្រា៩(៤))។

[១៥៥]. បណ្តឹងលេខ៤៣២/១៩៩០ រវាង W.B.E និងប្រទេសហូឡង់ដ៍ កថាខណ្ឌទី៦.៥។ បណ្តឹងលេខ៩៦៣/២០០១ រវាង Uebergang និងប្រទេសអូទ្រីស កថាខណ្ឌទី៤.៤។

៥២. សំណងផ្នែកហិរញ្ញវត្ថុដែលតម្រូវដោយកថាខណ្ឌទី៥ ទាក់ទងជាក់លាក់ទៅនឹងការខូចខាតដែលពាក់ព័ន្ធនឹងប្រាក់កាស និងមិនមែនប្រាក់កាស ដែលកើតចេញពីការចាប់ខ្លួន ឬការឃុំខ្លួនដោយមិនត្រឹមត្រូវតាមច្បាប់។[១៥៦] នៅពេលដែលភាពមិនត្រឹមត្រូវតាមច្បាប់នៃការចាប់ខ្លួនកើតចេញពីការរំលោភសិទ្ធិមនុស្សផ្សេងទៀត ដូចជាសេរីភាពនៃការសំដែងមតិ រដ្ឋភាគីអាចមានកាតព្វកិច្ចបន្ថែមទៀតក្នុងការផ្តល់សំណង ឬការជួសជុលការខូចខាតផ្សេងទៀត ទាក់ទងនឹងអំពើរំលោភទាំងនោះ ដូចដែលតម្រូវដោយមាត្រា២ កថាខណ្ឌទី៣ នៃកតិកាសញ្ញានេះ។[១៥៧]

---

[១៥៦] បណ្តឹងលេខ១១៥៧/២០០៣ រវាង Coleman និងប្រទេសអូស្រ្តាលី កថាខណ្ឌទី៦.៣។

[១៥៧] ដូចខាងលើ កថាខណ្ឌទី៩។ បណ្តឹងលេខ១១២៨/២០០២ រវាង Marques de Morais និងប្រទេសអង់ហ្គោឡា កថាខណ្ឌទី៨។ សេចក្តីពន្យល់ទូទៅលេខ៣១ កថាខណ្ឌទី១៦។

# VII. ទំនាក់ទំនងនៃមាត្រា៩ ជាមួយមាត្រាផ្សេងទៀតនៃកតិកាសញ្ញា

៥៣. ការធានាផ្នែកនីតិវិធី និងសារធាតុនៃមាត្រា៩ ត្រួតគ្នា និងមានអន្តរកម្មជាមួយការធានាផ្សេងទៀតនៃកតិកាសញ្ញានេះ។ ទម្រង់នៃការប្រតិបត្តិខ្លះ ក៏ក្លាយជាការរំលោភបំពានមាត្រា៩ និងមាត្រាមួយទៀតដោយឯកឯង ដូចជា ការពន្យារពេលក្នុងការនាំខ្លួនចុងចោទនៃបទព្រហ្មទណ្ឌដែលជាប់ឃុំទៅជំនុំជម្រះក្តី ដែលអាចបំពានកថាខណ្ឌទី៣ នៃមាត្រា៩ និងកថាខណ្ឌទី៣(គ) នៃមាត្រា១៤។ នៅពេលខ្លឹមសារនៃមាត្រា៩ កថាខណ្ឌទី១ ត្រូវបានជ្រួតជ្រាបតាមខ្លឹមសារនៃមាត្រាផ្សេងទៀត ឧទាហរណ៍ ការឃុំខ្លួនអាចមានលក្ខណៈតាមទំនើងចិត្ត ដោយហេតុថា វាគឺជាតំណាងឲ្យការដាក់ទណ្ឌកម្មចំពោះសេរីភាពនៃការសំដែងមតិ ដោយរំលោភលើមាត្រា១៩។[១៥៨]

៥៤. មាត្រា៩ ក៏ពង្រឹងកាតព្វកិច្ចរបស់រដ្ឋភាគីផងដែរ ក្រោមកតិកាសញ្ញា និងក្រោមពិធីសារបន្ថែម ដើម្បីការពារបុគ្គលពីការសងសឹក ចំពោះការសហការ ឬទាក់ទងជាមួយគណៈកម្មាធិការ ដូចជា ការបំផិតបំភ័យឬគំរាមកំហែងផ្លូវកាយ ទៅលើសេរីភាពបុគ្គល។[១៥៩]

---

[១៥៨] សូមមើលកថាខណ្ឌទី១៧ ខាងលើ នៃសេចក្តីពន្យល់ទូទៅនេះ។

[១៥៩] សេចក្តីពន្យល់ទូទៅលេខ៣៣ កថាខណ្ឌទី៤។ បណ្តឹងលេខ២៤១/១៩៨៧ និងបណ្តឹងលេខ២៤២/១៩៨៧ រវាង Birindwa ci Birhashwirwa & Tshisekedi wa Mulumba និងប្រទេសហ្សាអៀ កថាខណ្ឌទី១២.៥។ សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់កោះម៉ាល់ឌីវ ឆ្នាំ២០១២ កថាខណ្ឌទី២៦។

៥៥. សិទ្ធិរស់រានមានជីវិត ដែលត្រូវបានធានាការពារដោយមាត្រា៦ នៃកតិកាសញ្ញា រួមទាំងសិទ្ធិទទួលបានការការពារអាយុជីវិត ក្រោមមាត្រា៦ កថាខណ្ឌទី១ អាចត្រួតគ្នាជាមួយសិទ្ធិទទួលបានសន្តិសុខរបស់មនុស្ស ដែលធានាការពារដោយមាត្រា៩ កថាខណ្ឌទី១។ សិទ្ធិទទួលបានសន្តិសុខផ្ទាល់ខ្លួន អាចត្រូវបានពិចារណាកាន់តែទូលាយ រហូតដល់កម្រិតដែលមាត្រានេះដោះស្រាយផងដែរនូវរបួសស្នាមទាំងឡាយ ដែលមិនបង្កការគំរាមកំហែងអាយុជីវិត។ ទម្រង់ធ្ងន់ធ្ងរនៃការឃុំខ្លួនតាមទំនើងចិត្ត ដែលមានលក្ខណៈគំរាមកំហែងដល់ជីវិត រំលោភលើសិទ្ធិទទួលបានសេរីភាពផ្ទាល់ខ្លួន និងសន្តិសុខផ្ទាល់ខ្លួន ក៏ដូចជា សិទ្ធិទទួលបានការការពារជីវិត ជាពិសេស នៅក្នុងស្ថានភាពបាត់ខ្លួនដោយបង្ខំ។[១៦០]

៥៦. ការឃុំខ្លួនតាមទំនើងចិត្ត បង្កើតហានិភ័យនៃការធ្វើទារុណកម្ម និងការប្រព្រឹត្តិមិនគប្បី និងការធានានៃនីតិវិធីជាច្រើននៅក្នុងមាត្រា៩ ជួយកាត់បន្ថយភាពដូចគ្នានៃហានិភ័យបែបនេះ។ ការឃុំខ្លួនដាច់ដោយឡែកពីគេដែលចេះតែពន្យារពេលយូរ គឺជាការរំលោភលើមាត្រា៩ ហើយជាទូទៅត្រូវបានចាត់ទុកថាជាការរំលោភលើមាត្រា៧។[១៦១] សិទ្ធិទទួលបានសន្តិសុខផ្ទាល់ខ្លួន ការពារផលប្រយោជន៍នៅក្នុងបូរណភាពផ្នែករាងកាយនិងផ្លូវចិត្ត ដែលត្រូវបានការពារដោយមាត្រា៧។[១៦២]

[១៦០]. បណ្តឹងលេខ៤៤៩/១៩៩១ រវាង Mojica និងសាធារណៈរដ្ឋដូមីនិចកាំង កថាខណ្ឌទី៥.៤។ បណ្តឹងលេខ១៧៥៣/២០០៨ រវាង Guezout និងប្រទេសអាល់ហ្សេរី កថាខណ្ឌទី៨.៤ និង៨.៧។

[១៦១]. បណ្តឹងលេខ១៧៨២/២០០៨ រវាង Aboufaied និងប្រទេសលីប៊ី កថាខណ្ឌទី៧.៤ និង៧.៦។ បណ្តឹងលេខ៤៤០/១៩៩០ រវាង El-Megreisi និងប្រទេសលីប៊ីអារ៉ាប់ ចាម៉ាហ៊ីរីយ៉ា កថាខណ្ឌទី៥.៤។

[១៦២]. សេចក្តីពន្យល់ទូទៅលេខ២០ កថាខណ្ឌទី២។

៥៧. ការបញ្ជូនជនម្នាក់ត្រឡប់ទៅកាន់ប្រទេសមួយ ដែលមានមូលដ្ឋានយ៉ាងរឹងមាំ ក្នុងការជឿថា ជននោះប្រឈមមុខនឹងហានិភ័យពិតប្រាកដនៃការរំលោភធ្ងន់ធ្ងរទៅលើសេរីភាព ឬសន្តិសុខរបស់មនុស្ស ដូចជា ការឃុំខ្លួនតាមទំនើងចិត្តដែលចេះតែពន្យារពេលយូរ អាចមានន័យថាជាការប្រព្រឹត្តិអមនុស្សធម៌ ដែលត្រូវបានហាមឃាត់ដោយមាត្រា៧ នៃកតិកាសញ្ញានេះ។[១៦៣]

៥៨. កិច្ចការពារមួយចំនួនដែលសំខាន់ដល់ការបង្ការទារុណកម្មក៏ចាំបាច់ផងដែរ ដល់ការការពារមនុស្សនៅក្នុងឃុំ តាមទម្រង់ណាក៏ដោយពីការឃុំខ្លួនតាមទំនើងចិត្ត និងការរំលោភសន្តិសុខផ្ទាល់ខ្លួន។[១៦៤] ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗប៉ុណ្ណោះ។ ជនជាប់ឃុំគួរត្រូវបានដាក់នៅក្នុងកន្លែងដែលត្រូវបានទទួលស្គាល់ជាផ្លូវការថា ជាកន្លែងឃុំខ្លួន។ គួរមានសៀវភៅបញ្ជីផ្លូវការមួយដែលមានឈ្មោះ និងកន្លែងឃុំខ្លួន ពេលវេលានៃការមកដល់និងការចេញទៅវិញ ព្រមទាំងឈ្មោះរបស់អ្នកដែលទទួលខុសត្រូវពីការឃុំខ្លួនពួកគេ ហើយបើកចំហជាស្រេច និងបង្កការងាយស្រួលឲ្យមើលដល់បុគ្គលពាក់ព័ន្ធរួមទាំងសាច់ញាតិរបស់ជនជាប់ឃុំ។[១៦៥] ការចូលជួបជនជាប់ឃុំភ្លាមៗ និងទៀងទាត់ គួរអនុញ្ញាតឲ្យដល់បុគ្គលិកពេទ្យឯករាជ្យ និងមេធាវី ព្រមទាំងដល់សមាជិកគ្រួសារផង ដែលត្រូវស្ថិតក្រោមការត្រួតពិនិត្យសមស្រប ប្រសិនបើគោលបំណងធម្មានុរូបនៃការឃុំ

[១៦៣] តាមរយៈសេចក្តីពន្យល់ទូទៅលេខ៣១ កថាខណ្ឌទី១២។

[១៦៤] សូមមើលសេចក្តីពន្យល់ទូទៅលេខ២០ កថាខណ្ឌទី១១ និងសេចក្តីពន្យល់ទូទៅលេខ២ កថាខណ្ឌទី១៣ របស់គណៈកម្មាធិការប្រឆាំងទារុណកម្ម។

[១៦៥] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអាល់ហ្សេរី ឆ្នាំ២០០៧ កថាខណ្ឌទី១១។

ខ្លួនតម្រូវដូច្នោះ។[១៦៦] ជនជាប់ឃុំ គួរតែត្រូវបានប្រាប់អំពីសិទ្ធិរបស់ពួកគេ តាមភាសាមួយដែលពួកគេយល់បាន។[១៦៧] ការផ្តល់ខិត្តប័ណ្ណព័ត៌មានជាភាសាសមស្រប រួមទាំងអក្សរស្ទាបសម្រាប់ជនពិការផងជារឿយៗ អាចជួយជនជាប់ឃុំក្នុងការទទួលបានព័ត៌មាន។ ជនបរទេសដែលជាប់ឃុំ គួរត្រូវបានប្រាប់អំពីសិទ្ធិរបស់ពួកគេ ក្នុងការទាក់ទងជាមួយអាជ្ញាធរកុងស៊ុលរបស់ខ្លួន ឬក្នុងករណីជនស្វែងរកសិទ្ធិជ្រកកោន ទាក់ទងជាមួយស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន។[១៦៨] យន្តការឯករាជ្យ និងមិនលំអៀងគួរត្រូវបានបង្កើតឡើងសម្រាប់ចុះទៅមើល និងអធិការកិច្ចកន្លែងឃុំខ្លួនទាំងអស់ រួមទាំងស្ថាប័នព្យាបាលជំងឺវិកលចារិកផង។

៥៩. មាត្រា១០នៃកតិកាសញ្ញានេះដែលចែងអំពីលក្ខខណ្ឌនៃការឃុំខ្លួនសម្រាប់ជនដែលត្រូវបានដកហូតសេរីភាព បំពេញបន្ថែមឲ្យមាត្រា ៩ ដែលចែងជាចម្បងអំពីអង្គហេតុនៃការឃុំខ្លួន។ ទន្ទឹមនឹងនោះ សិទ្ធិទទួលបានសន្តិសុខផ្ទាល់ខ្លួនក្នុងមាត្រា៩ កថាខណ្ឌទី១ ពាក់ព័ន្ធនឹងការប្រព្រឹត្តិលើទាំងជនជាប់ឃុំ ទាំងជនមិនជាប់ឃុំ។ ភាពសមស្របនៃលក្ខខណ្ឌដែលកើនឡើងក្នុងការឃុំខ្លួន ចំពោះគោលបំណងនៃការឃុំខ្លួន ជួនកាល គឺជាកត្តាមួយក្នុងការកំណត់ថាតើ

[១៦៦]. សូមមើលកម្រងគោលការណ៍ (កំណត់សំគាល់ក្នុងលេខ១០២ ខាងលើ) គោលការណ៍១៧ ១៩ និង២៤។ សេចក្តីពន្យល់ទូទៅលេខ១០ កថាខណ្ឌទី៨៧ របស់គណៈកម្មាធិការស្តីពីសិទ្ធិកុមារ។

[១៦៧]. សូមមើលកម្រងគោលការណ៍ (កំណត់សំគាល់ក្នុងលេខ១០២ ខាងលើ) គោលការណ៍១៣ និង១៤។ វិធានរបស់អង្គការសហប្រជាជាតិសម្រាប់ការការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព កថាខណ្ឌទី២៤ និង២៥ ដែលត្រូវបានអនុម័តដោយសេចក្តីសម្រេចលេខ៤៥/១១៣ របស់មហាសន្និបាតអង្គការសហប្រជាជាតិ (ស្តីពីការពន្យល់អំពីសិទ្ធិរបស់អនីតិថិជនដែលជាប់ឃុំ)។

[១៦៨]. សូមមើលកម្រងគោលការណ៍ (កំណត់សំគាល់ក្នុងលេខ១០២ ខាងលើ) គោលការណ៍១៦ កថាខណ្ឌទី២។

ការឃុំខ្លួន ធ្វើតាមទំនើងចិត្ត ក្នុងអត្ថន័យនៃមាត្រា៩។[១៦៩] លក្ខខណ្ឌនៃការឃុំខ្លួនខ្លះ (ដូចជា ការបដិសេធពីការទទួលបានជំនួយផ្នែកច្បាប់និងការជួបជាមួយគ្រួសារ)អាចបណ្តាលឲ្យមានការបំពានផ្នែកនីតិវិធីនៃកថាខណ្ឌទី៣ និងទី៤ នៃមាត្រា៩។ មាត្រា១០ កថាខណ្ឌទី២(ខ) ពង្រឹងបន្ថែមដល់អនីតិជន នូវលក្ខខណ្ឌតម្រូវក្នុងមាត្រា៩ កថាខណ្ឌទី៣ ដែលជនជាប់ឃុំបណ្តោះអាសន្ន ត្រូវនាំខ្លួនមកជំនុំជម្រះទោសឲ្យបានឆាប់បំផុត។

៦០. សេរីភាពក្នុងការដើរហើរ ដែលការពារដោយមាត្រា១២ នៃកតិកាសញ្ញា និងសេរីភាពរបស់បុគ្គល ដែលការពារដោយមាត្រា៩ បំពេញឲ្យគ្នាទៅវិញទៅមក។ ការឃុំខ្លួន គឺជាទម្រង់នៃការរឹតត្បិតធ្ងន់ធ្ងរពិសេសមួយនៃសេរីភាពក្នុងការដើរហើរ ប៉ុន្តែក្នុងកាលៈទេសៈខ្លះមាត្រាទាំងពីរ អាចមានតួនាទីរួមគ្នា។[១៧០] ជារឿយៗ ការឃុំខ្លួននៅក្នុងករណីដឹកជញ្ជូនជនទេសន្តរប្រវេសន៍ម្នាក់ ដោយមិនស្ម័គ្រចិត្ត ត្រូវបានប្រើប្រាស់ជាមធ្យោបាយមួយ នៃការអនុវត្តការរឹតត្បិតសេរីភាពក្នុងការដើរហើរ។ មាត្រា៩ ចែងអំពីការប្រើការឃុំខ្លួនបែបនេះ ក្នុងការអនុវត្តការបណ្តេញចេញ ការនិរទេសខ្លួន ឬការធ្វើបត្យាប័ន។

៦១. ចំពោះការជំនុំជម្រះរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីព្រហ្មទណ្ឌ ទំនាក់ទំនងរវាងមាត្រា៩ និងមាត្រា១៤ នៃកតិកាសញ្ញានេះ បានពន្យល់

---

១៦៩. សូមមើលកថាខណ្ឌទី១៤ ១៨ និង២១ ខាងលើ នៃសេចក្តីពន្យល់ទូទៅនេះ។

១៧០. សេចក្តីពន្យល់ទូទៅលេខ២៧ កថាខណ្ឌទី៧។ បណ្តឹងលេខ១១៣៤/២០០២ រវាង Gorji-Dinka និងប្រទេសកាំមីរូន កថាខណ្ឌ៥.៤-៥.៥ (ការឃុំខ្លួនក្នុងផ្ទះ)។ បណ្តឹងលេខ១៣៨/១៩៨១ រវាង Mpandanjila et al និងប្រទេសហ្សាអៀ កថាខណ្ឌទី៨ និង១០។

រួចមកហើយ។[១៧១] មាត្រា៩ ចែងអំពីការដកហូតសេរីភាព។ មានតែការដកហូតមួយចំនួនប៉ុណ្ណោះដែលធ្វើឡើង ដោយទាក់ទងទៅនឹងដំណើរការក្តីរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ក្នុងវិសាលភាពនៃមាត្រា១៤។ លក្ខខណ្ឌតម្រូវផ្នែកនីតិវិធីនៃកថាខណ្ឌ២ ដល់កថាខណ្ឌ៥ នៃមាត្រា៩ ត្រូវយកមកអនុវត្ត ទាក់ទងនឹងដំណើរការក្តីដែលស្ថិតនៅក្នុងវិសាលភាពនៃមាត្រា១៤តែនៅពេលណាដែលការចាប់ខ្លួន ឬការឃុំខ្លួនជាក់ស្តែង កើតឡើង។[១៧២]

**៦២.** មាត្រា២៤ កថាខណ្ឌទី១ នៃកតិកាសញ្ញា ផ្តល់សិទ្ធិឲ្យកុមារគ្រប់រូប "ទទួលបានវិធានការការពារបែបនេះ ទៅតាមការតម្រូវតាមឋានៈរបស់ពួកគេជាអនីតិជននៅក្នុងគ្រួសារ សង្គម និងរដ្ឋ"។ មាត្រានេះតម្រូវឲ្យអនុម័តវិធានការពិសេស ដើម្បីការពារសេរីភាពនិងសន្តិសុខផ្ទាល់ខ្លួនរបស់កុមារគ្រប់រូប បន្ថែមលើវិធានការដែលតម្រូវឡើងជាទូទៅក្នុងមាត្រា៩ សម្រាប់មនុស្សគ្រប់រូប។[១៧៣] កុមារអាចត្រូវបានដកហូតសេរីភាព តែជាមធ្យោបាយចុងក្រោយបំផុតប៉ុណ្ណោះ និងសម្រាប់រយៈពេលខ្លីដែលសមស្របបំផុត។[១៧៤] បន្ថែមលើលក្ខខណ្ឌតម្រូវផ្សេងទៀត ដែលអនុវត្តចំពោះប្រភេទនីមួយៗនៃការដកហូតសេរីភាព ឧត្តមប្រយោជន៍របស់កុមារត្រូវតែជាការពិចារណាដ៏ចំបង

[១៧១]. សូមមើលកថាខណ្ឌទី៣៨ និង៥៣ ខាងលើ នៃសេចក្តីពន្យល់ទូទៅនេះ។

[១៧២]. បណ្តឹងលេខ២៦៣/១៩៨៧ រវាង González del Río និងប្រទេសប៉េរូ កថាខណ្ឌ៥.១។ បណ្តឹងលេខ១៧៥៨/២០០៨ រវាង Jessop និងប្រទេសណូវែលហ្សេឡង់ត៍ កថាខណ្ឌ៧.៩-៧.១០។

[១៧៣]. សេចក្តីពន្យល់ទូទៅលេខ១៧ កថាខណ្ឌទី១ និងសេចក្តីពន្យល់ទូទៅលេខ៣២ កថាខណ្ឌទី៤២ និង៤៤។

[១៧៤]. សេចក្តីសង្កេតសន្និដ្ឋានសំរាប់សាធារណៈរដ្ឋឆែក ឆ្នាំ២០១៣ កថាខណ្ឌទី១៧។ មាត្រា៣៧(ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

ក្នុងគ្រប់សេចក្តីសម្រេច ផ្តួចផ្តើម ឬបន្តការដកហូតសេរីភាពនេះ។[១៧៥] គណៈកម្មាធិការទទួលស្គាល់ថា ជួនកាល ការដកហូតសេរីភាព ដោយឡែកណាមួយនោះ គឺជាឧត្តមប្រយោជន៍របស់កុមារទៅវិញ។ ការដាក់កុមារនៅក្នុងមណ្ឌលថែទាំ ក៏ជាការដកហូតសេរីភាព តាម អត្ថន័យនៃមាត្រា៩ដែរ។[១៧៦] សេចក្តីសម្រេចដកហូតសេរីភាពពី កុមារម្នាក់ ត្រូវស្ថិតក្រោមការពិនិត្យឡើងវិញតាមពេលកំណត់ពីការបន្ត ភាពចាំបាច់ និងភាពសមស្របរបស់ខ្លួន។[១៧៧] កុមារមានសិទ្ធិឲ្យគេ ដឹងឮ ដោយផ្ទាល់ ឬតាមរយៈជំនួយផ្នែកច្បាប់ ឬជំនួយសមស្រប ផ្សេងទៀត ទាក់ទងនឹងការសម្រេចណាមួយអំពីការដកហូតសេរីភាព ហើយនីតិវិធីដែលយកមកប្រើ គួរតែសមស្របសម្រាប់កុមារ។[១៧៨] សិទ្ធិទទួលបានការដោះលែងពីការឃុំខ្លួន ដោយមិនត្រឹមត្រូវតាម ច្បាប់ អាចជាលទ្ធផលមកពីការវិលត្រឡប់ទៅកាន់គ្រួសាររបស់ កុមារនោះវិញ ឬការដាក់កុមារនៅក្នុងទម្រង់ថែទាំតាមជម្រើសផ្សេង ដែលស្របតាមឧត្តមប្រយោជន៍របស់កុមារ ជាជាងគ្រាន់តែដោះ

---

១៧៥. បណ្តឹងលេខ១០៦៩/២០០២ រវាង Bakhtiyari និងប្រទេសអូស្រ្តាលី កថាខ័ណ្ឌទី៩.៧។ សូមមើលមាត្រា ៣(១) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

១៧៦. សូមមើលសេចក្តីពន្យល់ទូទៅលេខ១០ កថាខណ្ឌទី១១ របស់គណៈកម្មាធិការស្តីពីសិទ្ធិកុមារ។ វិធានរបស់ អង្គការសហប្រជាជាតិសម្រាប់ការការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព(១៩៩០) កថាខណ្ឌទី១១(ខ)។ ផ្ទុយទៅវិញ ការត្រួតពិនិត្យធម្មតាលើកុមារដោយឪពុកម្តាយ ឬគ្រួសារ អាចពាក់ព័ន្ធនឹងកំរិតនៃការគ្រប់គ្រងទៅ លើការបម្លាស់ទី ជាពិសេសកុមារតូចៗ ដែលមិនសមស្របសម្រាប់មនុស្សពេញវ័យ ប៉ុន្តែនេះមិនបង្កើតជាការដក ហូតសេរីភាពទេ ហើយលក្ខខណ្ឌតម្រូវធម្មតានៃការស្រង់វត្តមានប្រចាំថ្ងៃនៅសាលា ក៏មិនបង្កើតជាការដកហូត សេរីភាពដែរ។

១៧៧. សូមមើលកថាខណ្ឌទី១២ ខាងលើ នៃសេចក្តីពន្យល់ទូទៅនេះ។ មាត្រា៣៧(ឃ) និងមាត្រា២៥ នៃអនុ សញ្ញាស្តីពីសិទ្ធិកុមារ។

១៧៨. សូមមើលសេចក្តីពន្យល់ទូទៅលេខ៣២ កថាខណ្ឌទី៤២-៤៤ និងសេចក្តីពន្យល់ទូទៅលេខ១២ កថាខណ្ឌទី ៣២-៣៧ របស់គណៈកម្មាធិការស្តីពីសិទ្ធិកុមារ។

លែងធម្មតា ឲ្យកុមារទៅថែទាំខ្លួនឯងនោះ។[១៧៩]

៦៣. យោងតាមស្មារតីនៃមាត្រា២ កថាខណ្ឌទី១ នៃកតិកាសញ្ញានេះ រដ្ឋភាគីមានកាតព្វកិច្ចគោរព និងធានាសិទ្ធិក្រោមមាត្រា៩ ដល់មនុស្សទាំងអស់ដែលអាចស្ថិតនៅក្នុងដែនដី និងក្រោមយុត្តាធិការរបស់ខ្លួន។[១៨០] ដោយសារតែការចាប់ខ្លួន និងការឃុំខ្លួន គឺជាការដាក់ឲ្យមនុស្សម្នាក់ស្ថិតនៅក្នុងការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់រដ្ឋមួយ រដ្ឋភាគីមិនត្រូវចាប់ខ្លួន ឬឃុំខ្លួនមនុស្សតាមទំនើងចិត្ត ឬដោយមិនត្រឹមត្រូវតាមច្បាប់ នៅក្រៅដែនដីរបស់ខ្លួនឡើយ។[១៨១] រដ្ឋភាគីមិនត្រូវដាក់មនុស្សដែលនៅក្រៅដែនដីរបស់ខ្លួន ឲ្យស្ថិតក្នុងការឃុំខ្លួនដាច់ដោយឡែកពីគេរយៈពេលយូរហួសហេតុ ឬដកហូតសិទ្ធិពួកគេពីការទទួលបានការពិនិត្យឡើងវិញ លើភាពត្រឹមត្រូវតាមច្បាប់នៃការឃុំខ្លួនរបស់ពួកគេឡើយ។[១៨២] ទីតាំងនៅក្រៅដែនដីនៃការចាប់ខ្លួន អាចជាកាលៈទេសៈដែលទាក់ទងនឹងការវាយតម្លៃពីភាពបន្ទាន់ ក្រោមកថាខណ្ឌទី៣។

[១៧៩] តាមរយៈគោលការណ៍ណែនាំស្ដីពីការឃុំខ្លួនរបស់ស្នងការជាន់ខ្ពស់ទទួលបន្ទុកជនភៀសខ្លួន(កំណត់សម្គាល់លេខ៤៥ខាងលើ) កថាខណ្ឌទី៥៤ ("នៅពេលណាធ្វើទៅបាន [កុមារដែលគ្មានអ្នកអមជាមួយ ឬបែកបាក់គ្រួសារ] គួរត្រូវបានដោះលែងឲ្យទទួលការថែទាំពីសមាជិកគ្រួសារ ដែលមានលំនៅស្ថានរួចទៅហើយនៅក្នុងប្រទេសជ្រកកោននោះ។ បើសិនជាមិនអាចធ្វើទៅបាន ការរៀបចំឲ្យមានការថែទាំជំនួស ដូចជាការដាក់ក្នុងកន្លែងចិញ្ចឹម ឬផ្ទះរស់នៅ គួរធ្វើឡើងដោយអាជ្ញាធរថែទាំកុមារដែលមានសមត្ថកិច្ច ដោយធានាថាកុមារទទួលបានការត្រួតពិនិត្យសមស្រប")។

[១៨០] សេចក្ដីពន្យល់ទូទៅលេខ៣១ កថាខណ្ឌទី១០។

[១៨១] ដូចខាងលើ។ បណ្ដឹងលេខ 12/52 រវាង Saldías de López និងប្រទេសអ៊ុយរុយហ្គាយ កថាខណ្ឌទី១២.១-១៣។ បណ្ដឹងលេខ R.13/56 រវាងCeliberti de Casariego និងប្រទេសអ៊ុយរុយហ្គាយ កថាខណ្ឌទី១០.១-១១។ បណ្ដឹងលេខ៦២៣/១៩៩៥ et al. រវាង Domukovsky et al.និងប្រទេសចចៀ កថាខណ្ឌទី១៨.២។

[១៨២] សូមមើលសេចក្ដីសង្កេតសន្និដ្ឋានសំរាប់សហរដ្ឋអាមេរិក ឆ្នាំ២០០៦ កថាខណ្ឌទី១២ និង១៨។

៦៤. ពាក់ព័ន្ធនឹងមាត្រា៤ នៃកតិកាសញ្ញានេះ គណៈកម្មាធិការសង្កេតឃើញជាបឋមថា ដូចមាត្រាដទៃទៀតនៃកតិកាសញ្ញាដែរ មាត្រា៩ ក៏យកមកអនុវត្តនៅក្នុងស្ថានភាពនៃជម្លោះប្រដាប់អាវុធដែរ ដែលវិធាននៃច្បាប់មនុស្សធម៌អន្តរជាតិត្រូវបានអនុវត្ត។[១៨៣] ខណៈដែលវិធាននៃច្បាប់មនុស្សធម៌អន្តរជាតិ អាចពាក់ព័ន្ធដល់គោលបំណងនៃការបកស្រាយមាត្រា៩ ផ្នែកទាំងពីរនៃច្បាប់ បំពេញឲ្យគ្នាទៅវិញទៅមក មិនដាច់ដោយឡែកពីគ្នាទេ។[១៨៤] ការឃុំខ្លួនដោយហេតុផលសន្តិសុខដែលអនុញ្ញាតដោយ និងបញ្ញត្តិដោយ និងស្របតាមច្បាប់មនុស្សធម៌អន្តរជាតិ ជាគោលការណ៍ គឺមិនមែនជាការឃុំខ្លួនតាមទំនើងចិត្តទេ។ នៅក្នុងស្ថានភាពមានជម្លោះ ការចូលទៅពិនិត្យកន្លែងឃុំខ្លួនទាំងអស់ ដោយគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ក្លាយជាកិច្ចការពារបន្ថែមយ៉ាងសំខាន់មួយសម្រាប់សិទ្ធិមានសេរីភាព និងសន្តិសុខរបស់មនុស្ស។

៦៥. មាត្រា៩ មិនត្រូវបានដាក់បញ្ចូលក្នុងបញ្ជីនៃសិទ្ធិដែលមិនអាចព្យួរបាន ក្នុងមាត្រា៤ កថាខណ្ឌទី២ នៃកតិកាសញ្ញានោះទេ ប៉ុន្តែមានដែនកំណត់ទៅលើអំណាចរបស់រដ្ឋភាគី ក្នុងការព្យួរសិទ្ធិនេះ។ រដ្ឋភាគីណាដែលបដិប្បញ្ញត្តិចេញពីនីតិវិធីធម្មតាតម្រូវតាមមាត្រា៩ ក្នុងកាលៈទេសៈមានជម្លោះប្រដាប់អាវុធ ឬស្ថានភាពគ្រាអាសន្នដទៃទៀត ត្រូវធានាថា បដិបញ្ញត្តិបែបនេះមិនលើសពីអ្វីដែលបានតម្រូវ

[១៨៣]. សេចក្តីពន្យល់ទូទៅលេខ៣១ កថាខណ្ឌទី១១ និងសេចក្តីពន្យល់ទូទៅលេខ២៩ កថាខណ្ឌទី៣។

[១៨៤]. សេចក្តីពន្យល់ទូទៅលេខ៣១ កថាខណ្ឌទី១១។ សេចក្តីពន្យល់ទូទៅលេខ២៩ កថាខណ្ឌទី៣ ១២និង១៦។

យ៉ាងតឹងរឹងដោយភាពបន្ទាន់នៃស្ថានភាពជាក់ស្តែងនោះឡើយ។[១៨៥] វិធានការបដិបញ្ញត្តិត្រូវមានសង្គតិភាពជាមួយកាតព្វកិច្ចផ្សេងទៀតរបស់រដ្ឋភាគី ក្រោមច្បាប់អន្តរជាតិ រួមទាំងបទប្បញ្ញត្តិនៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលទាក់ទងនឹងការដកហូតសេរីភាព និងការមិនរើសអើង។[១៨៦] ដូច្នេះ ការហាមឃាត់ប្រឆាំងនឹងការចាប់ជាចំណាប់ខ្មាំង ការចាប់ជំរិត ឬការឃុំខ្លួនដោយគ្មានការទទួលស្គាល់ មិនមែនជាកម្មវត្ថុនៃការធ្វើបដិប្បញ្ញត្តិឡើយ។[១៨៧]

៦៦. តាមទស្សនៈរបស់គណៈកម្មាធិការ មានធាតុផ្សំផ្សេងទៀតនៅក្នុងមាត្រា៩ ដែលមិនអាចធ្វើជាកម្មវត្ថុដល់បដិប្បញ្ញត្តិស្របច្បាប់ ក្រោមមាត្រា៤។ ការធានាជាមូលដ្ឋានប្រឆាំងនឹងការឃុំខ្លួនតាមទំនើងចិត្តមិនអាចធ្វើបដិប្បញ្ញត្តិបានទេ សូម្បីតែស្ថានភាពដែលមានចែងក្នុងមាត្រា៤ ក៏មិនអាចធ្វើយុត្តិកម្មដល់ការដកហូតសេរីភាព ដែលមិនសមហេតុផលឬមិនចាំបាច់ ក្រោមកាលៈទេសៈទាំងនោះដែរ។[១៨៨] ទោះជាយ៉ាងណាក្តី អត្ថិភាព និងចរិកលក្ខណៈនៃគ្រាអាសន្នដែលគំរាមកំហែងដល់អាយុជីវិតប្រទេសជាតិអាចពាក់ព័ន្ធនឹងការសម្រេចថាតើការចាប់ខ្លួន ឬការឃុំខ្លួនណាមួយ មានលក្ខណៈតាមទំនើង

[១៨៥]. សេចក្តីពន្យល់ទូទៅលេខ២៩ កថាខណ្ឌទី៤-៥។ នៅពេលដែលមានភាពអាសន្ន ការធ្វើយុត្តិកម្មដល់វិធានការបដិប្បញ្ញត្តិ កើតឡើងចេញពីការចូលរួមរបស់កម្លាំងប្រដាប់អាវុធរបស់រដ្ឋភាគី នៅក្នុងបេសកកម្មរក្សាសន្តិភាពក្រៅប្រទេស វិសាលភាពជាក់ស្តែង និងតាមភូមិសាស្ត្រ នៃវិធានការបដិប្បញ្ញត្តិ ត្រូវតែកម្រិតត្រឹមតែភាពចាំបាច់នៃបេសកកម្មរក្សាសន្តិភាពនោះប៉ុណ្ណោះ។

[១៨៦]. សេចក្តីពន្យល់ទូទៅលេខ២៩ កថាខណ្ឌទី៨-៩។

[១៨៧]. ដូចខាងលើ កថាខណ្ឌទី១៣(ខ)។

[១៨៨]. ដូចខាងលើ កថាខណ្ឌទី៤ និង១១។

ចិត្ត។ បដិប្បញ្ញត្តិដែលមានសុពលភាពពីសិទ្ធិបដិប្បញ្ញត្តិដទៃទៀត ក៏អាចពាក់ព័ន្ធផងដែរ នៅពេលការដកហូតសេរីភាពត្រូវចាត់ទុកថាមានលក្ខណៈតាមទំនើងចិត្ត ដោយសារតែមានជាប់ពាក់ព័ន្ធនឹងសិទ្ធិមួយទៀត ដែលការពារដោយកតិកាសញ្ញានេះ។ ក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធអន្តរជាតិ វិធានសារធាតុ និងនីតិវិធីនៃច្បាប់មនុស្សធម៌អន្តរជាតិនៅតែអាចអនុវត្តបាន និងកំហិតដល់លទ្ធភាពធ្វើបដិប្បញ្ញត្តិ ដូច្នេះវាជួយកាត់បន្ថយហានិភ័យនៃការឃុំខ្លួនតាមទំនើងចិត្ត។[១៨៩] ក្រៅពីបរិបទនេះ លក្ខខណ្ឌតម្រូវនៃភាពចាំបាច់ដ៏តឹងរឹង និងភាពសមាមាត្រ ដាក់កំហិតដល់វិធានការបដិប្បញ្ញត្តិណាមួយ ដែលពាក់ព័ន្ធនឹងការឃុំខ្លួនដោយហេតុផលសន្តិសុខ ដែលត្រូវតែកំរិតរយៈពេល និងអមដោយនីតិវិធី ដើម្បីបង្ការការអនុវត្តតាមទំនើងចិត្ត ដូចដែលបានពន្យល់នៅក្នុងកថាខណ្ឌទី ១៥ ខាងលើនៃសេចក្តីពន្យល់នេះ[១៩០] រួមទាំងការពិនិត្យឡើងវិញដោយតុលាការ នៅក្នុងអត្ថន័យនៃកថាខណ្ឌទី៤៥ ខាងលើ។[១៩១]

**៦៧.** ការធានាផ្នែកនីតិវិធីដែលការពារសេរីភាពរបស់មនុស្សអាចមិនដែលស្ថិតក្រោមវិធានការបដិប្បញ្ញត្តិ ដែលគេចចេញពីការការពារសិទ្ធិដែលមិនអាចព្យួរបាន។[១៩២] ដើម្បីការពារសិទ្ធិដែលមិនអាចព្យួរបាន រួមទាំងសិទ្ធិដែលមានចែងក្នុងមាត្រា៦ និងមាត្រា៧ សិទ្ធិចាត់ការ

---

[១៨៩] ដូចខាងលើ កថាខណ្ឌទី៣។

[១៩០] ដូចខាងលើ កថាខណ្ឌទី៤ ១១ និង១៥។

[១៩១] ដូចខាងលើ កថាខណ្ឌទី១៦។ សូមមើលផងដែរ កថាខ័ណ្ឌទី៦៧ ខាងក្រោម នៃសេចក្តីពន្យល់ទូទៅនេះ។

[១៩២] សេចក្តីពន្យល់ទូទៅលេខ៣២ កថាខណ្ឌទី៦។

តាមនីតិវិធីនៅចំពោះមុខតុលាការ ដើម្បីអាចឲ្យតុលាការធ្វើការសម្រេចដោយគ្មានការពន្យារពេលពីភាពត្រឹមត្រូវតាមច្បាប់នៃការឃុំខ្លួនមិនត្រូវបានកាត់បន្ថយដោយវិធានការបដិប្បញ្ញត្តិឡើយ។[១៩៣]

**៦៨.** ទោះជាការដាក់ខលក្ខខណ្ឌចំពោះប្រការមួយចំនួននៃមាត្រា៩ អាចទទួលយកបាន តែវានឹងមិនស្របតាមកម្មវត្ថុ និងគោលបំណងនៃកតិកាសញ្ញាចំពោះរដ្ឋភាគីនោះឡើយ ក្នុងការដាក់លក្ខខណ្ឌរក្សាសិទ្ធិមិនចូលរួមក្នុងការចាប់ខ្លួន និងការឃុំខ្លួនមនុស្ស។[១៩៤]

~*~

[១៩៣] សេចក្តីពន្យល់ទូទៅលេខ២៩ កថាខណ្ឌទី១៦។

[១៩៤] សេចក្តីពន្យល់ទូទៅលេខ២៤ កថាខណ្ឌទី៨។